# ធម៌សូត្រផ្សេងៗ



ប្រមូលរៀបរៀងដោយឧបាសិកា

**ខៀវ ធុត្ថា**

**ព.ស.២៥៥១ គ.ស.២០០៧**

# ធម៌សូត្រផ្សេងៗ



ប្រមូលរៀបរៀងដោយឧបាសិកា ខៀវ ឧត្តា

**បោះពុម្ពលើកទី ២ ចំនួន ១៥០ ច្បាប់**

**សម្រាប់ជាធម្មទាន**

**ព.ស.២៥៥១** **គ.ស.២០០៧**

# អារម្ភកថា

ដើមហេតុដែលនាងខ្ញុំប្រមូល រៀបរៀង ជាសៀវភៅនេះឡើង ដោយមានគោលគំនិតទាំឡាយដូចតទៅ :

នាងខ្ញុំយល់ឃើញថា អ្នកចង់សិក្សា រៀនសូត្រនូវព្រះធម៌ មានការលំបាក និងអានសៀវភៅច្រើន។ ម្យ៉ាងទៀត មានការសំណូមពរពីលោកតា លោកយាយ ដែលភ្នែកគាត់មិនសូវភ្លឺ ឱ្យជួយសំរួលក្នុងបញ្ហានេះ ។

ដើម្បីជាការរួមចំណែក ក្នុងការលើកស្ទួយដល់វិស័យ អប់រំពុទ្ធ-សាសនា ឱ្យបានស្ថិតស្ថេរ។

គោលបំណងទាំងអស់នេះហើយ ដែលនាំឱ្យកើតជាសៀវភៅ **ធម៌សូត្រផ្សេងៗ** នេះឡើងម្តងទៀត ។

លើកទី ១ នាងខ្ញុំបានបោះពុម្ពម្តងរួចហើយ ដែលមានឈ្មោះថា **បកិណ្ណកៈគិហិបដិបត្តិ** តែដោយលោកអ្នកជាវិញ្ញូជន បានអាន និងពិនិត្យទៅឃើញថា មានខុសនូវអក្ខរាវិរុទ្ធខ្លះៗហើយ នាងខ្ញុំក៏បានបោះពុម្ពសារជាថ្មី និងបន្ថែមគាថាថ្មីៗ ព្រមទាំងសុភាសិតមួយចំនួន ដើម្បីចែកជូនជាធម្មទានដល់ពុទ្ធបរិស័ទ និងឧបាសក ឧបាសិកា ដែលមានបំណងសិក្សានូវធម៌នមស្ការ ព្រះរតនត្រ័យ និងសមាទាននិច្ចសីល (សីល ៥) ឧបោសថសីល (សីល ៨) ព្រមទាំងធម៌សូត្រផ្សេងៗទៀត ។

នាងខ្ញុំសូមអភ័យទោសជាមុន ចំពោះកង្វះខាតផ្សេងៗ ដែលនឹងអាចកើតមានដោយអចេតនា ឬដោយការចេះមិនដល់ ក្នុងការបោះពុម្ពចម្លងនេះ ។

បុណ្យដែលកើតឡើងអំពីធម្មទាននេះនិងបុណ្យដែលធ្វើទាំងប៉ុន្មាន សូមជូនដល់លោកឪពុកឈ្មោះ ខៀវ សារឿន ដែលមានជីវិតរស់នៅសព្វថ្ងៃនេះ និងជូនដល់លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស សូមឱ្យមានអាយុវែង ផុតចាកទុក្ខ បានដល់នូវព្រះនិព្វានកុំបីអាក់ខានឡើយ ។ ជាពិសេស ដោយបុណ្យនៃធម្មទាននេះ សូមឧទ្ទិសចំពោះបុព្វការីជនដែលបានធ្វើមរណកាលទៅ មានអ្នកម្តាយ ប៊ិន សាត ព្រមទាំងបងប្អូន ញាតិមិត្តទាំងអស់ ក្នុងសង្សារវដ្ត។

*សូមអនុមោទនា !!!*

# គុកនិងសោរចោរអ្នកបង្កើត
# ឱ្យសថដើងឆើតកើតមកពីរោគ
# ដំណេកកើតមកពីងងុយងោក
# មនុស្សក្នុងលោកកើតមកពីកម្ម ៗ

# ធម៌សូត្រផ្សេងៗ

**មាតិកាធម៌** **ទំព័រ**


បទសរភញ្ញ ............................................................................. ១

អញ្ជើញពពួកទេវតា ............................................................... ២

បូជាគ្រឿងសក្ការៈ ឥតមានទៀនធូប .................................... ២

ការបូជាផ្កា ............................................................................. ៣

ថ្វាយគ្រឿងសក្ការៈដល់ព្រះរតនត្រ័យ ................................. ៤

ថ្វាយបង្គំព្រះពុទ្ធរតនៈ ............................................................... ៥

ថ្វាយបង្គំព្រះធម្មរតនៈ .............................................................. ១១

ថ្វាយបង្គំព្រះសង្ឃរតនៈ ........................................................ ១៧

ថ្វាយបង្គំព្រះរតនត្រៃដោយសង្ខេប ................................. ២៤

នមស្ការបូជនីយវត្ថុជាទីគោរព ........................................ ២៥

នមស្ការនូវព្រះពុទ្ធបាទ ......................................................... ២៦

នមស្ការព្រះរតនត្រ័យ បណាមគាថា.................................... ២៩

ថ្វាយបង្គំសុំសេចក្ដីសុខ ........................................................ ៣១

វិធីរក្សាសីល ............................................................................. ៣៣

វិធីសមាទាននិច្ចសីល (សីល៥ ) ........................................= ៣៥

នមស្ការសង្ខេប ........................................= ៣៦

វិធីសុំនិច្ចសីលជាបច្ចេកសមាទាន ........................................= ៤០

សិទ្ធិយាចនគាថា ........................................= ៤៦

ធាតុប្បច្ចវេក្ខណៈ ........................................= ៤៧

បដិកូលប្បច្ចវេក្ខណៈ ........................................= ៥០

តង្ខណិកប្បច្ចវេក្ខណៈ ........................................= ៥៣

អតីតប្បច្ចវេក្ខណៈ ........................................= ៥៨

ថ្វាយបង្គំព្រះពុទ្ធ ៥ ព្រះអង្គ ........................................= ៦៦

បរាភវសូត្រ ........................................= ៦៧

ពុទ្ធជយមង្គល ........................................= ៧៦

ជយបរិត្តគាថា ........................................= ៨៤

វិធីសមាទាន ឧបោសថសីល ........................................= ៨៨

អភិណ្ហប្បច្ចវេក្ខណសូត្រ ........................................= ៩៤

ទសជាតិ ........................................= ៩៨

សុភមង្គលគាថា ........................................= ១០១

បត្តិទានគាថា ( ឥមិនា... )........................................= ១០៣

បត្តនាគាថា (ឥមិនា...)........................................... ១០៥
ខមាបនគាថា (យេ កេចិ...)........................................... ១០៧
បត្តិទានគាថា (យំ កិញ្ចិ...)........................................... ១០៨
អនុមោទនារក្ខាយាចនគាថា ........................................... ១១១
បត្តិទានគាថា (យា ទេវតា...)........................................... ១១៤
ផ្សាយមេត្តាចំពោះទិសទាំង ១០ ........................................... ១១៧
រំលឹកព្រះគុណកែវទាំង ៣ ........................................... ១២៣
តេជៈខ្ញុំសាង ........................................... ១២៤
សិក្ខាបទ ៨ ........................................... ១២៦
អភិធម្មបិដក ធម្មសង្គណិ ........................................... ១៣០
វិភង្គ ........................................... ១៣៨
ធាតុកថា ........................................... ១៣៩
បុគ្គលបញ្ញត្តិ ........................................... ១៤២
កថាវត្ថុ ........................................... ១៤៣
យមកៈ ........................................... ១៤៤
បដ្ឋាន ........................................... ១៤៥
បដិច្ចសមុប្បាទ ........................................... ១៤៧

តិរោកុឌ្ឌកណ្ឌគាថា ...................................................= ១៥២

សំវេជនីយគាថា ..........................................................= ១៦១

ភត្តានុមោទនារម្ភគាថា ................................................= ១៦៧

សាមញ្ញានុមោទនាគាថា ...............................................= ១៦៩

អញ្ជើញពួកទេវតា (សគ្គេ...) ....................................=១៧២

សម្ពុទ្ធេ .......................................................................= ១៧៤

ប្រារព្ធមង្គលសូត្រ ........................................................= ១៧៨

មង្គលសូត្រ .................................................................= ១៨២

មហាមេត្រី ..................................................................= ១៩០

ប្រារព្ធរតនសូត្រ ..........................................................= ១៩៦

រតនសូត្រ ....................................................................= ១៩៩

អភយបរិត្តគាថា ..........................................................= ២១៣

អាដានាដិយបរិត្តគាថា .................................................= ២១៨

មង្គលចក្កវាឡ ............................................................= ២២១

ប្រកាសករណីយមេត្តសូត្រ ............................................= ២២៨

ករណីយមេត្តសូត្រ .......................................................= ២២៩

ប្រារព្ធខន្ធបរិត្ត ...........................................................= ២៣៥

ខន្ធបរិត្ត ............ ២៣៦
ប្រារព្ធមោរបរិត្ត ............ ២៤០
មោរបរិត្ត ............ ២៤១
អកុសលកម្មបទ ............ ២៤៦
អង្គនៃកម្មបថ និង សីល ............ ២៤៨
កថាវត្ថុ ............ ២៥៧
គុណនៃឧបាសក ............ ២៥៨
ឧបាសកនិទ្ទេស ............ ២៦១
អរិយទ្រព្យ ៧ ប្រការ ............ ២៦៧
ភាសិតោវាទ សង្ខេប ............ ២៧០
បច្ឆិមពុទ្ធវចនៈ ............ ២៨៤
ពាក្យប្រកាសស្តាប់ព្រះធម៌ទេសនា ............ ២៨៧
ព្រហ្មធំ ............ ២៨៨
ធម៌អដ្ឋង្គិកមគ្គ ............ ២៩០
ធម៌ផ្ចាញ់មារ ............ ២៩១
ធម៌ឧទ្ទិសកុសល ............ ២៩៦
ខមាទោសចំពោះព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ...... ២៩៧

ឧទ្ទិសកុសលទាន ............................................................ = ២៩៩

ធម៌ខន្តី លះទោស : ...................................................... = ៣០០

រំលឹកគុណមាតាបិតា ...................................................... = ៣០២

ទំនួញមាតាបិតា ............................................................... = ៣០៤

ពុទ្ធកិច្ច ៥ យ៉ាង .......................................................... = ៣០៨

កំណើតឆព្វណ្ណរង្សី ........................................................ = ៣១០

អាសនៈព្រះអរហន្ត ៩ ទិស .................................... = ៣១១

សង្វេជនីយដ្ឋានទាំង ៤ តំបន់ .................................. = ៣១៣

ឧទ្ទិសបុណ្យដល់ពពួកញាតិ ............................................ = ៣១៤

# បទសរភញ្ញ

១.សូមថ្វាយបង្គំ ព្រះសម្ពុទ្ធ ប្រសើរបំផុត ក្នុងលោកា
ជាគ្រូនៃមនុស្ស និងទេព្តា ទ្រង់ត្រាស់ទេសនា ប្រដៅសត្វ
ចង្អុលឱ្យដើរ ផ្លូវកណ្តាល មាគ៌ាត្រកាល អាចកម្ចាត់
ទុក្ខភ័យចង្រៃ ឱ្យខ្ចាយបាត់ អាចកាត់សង្សា-រៈទុក្ខបាន។
២.សាសនាព្រះអង្គ នៅសព្វថ្ងៃ សត្វមាននិស្ស័យ ពីបុរាណ
ប្រឹងរៀនប្រឹងស្តាប់ ចេះចាំបាន កាន់តាមលំអាន បានក្តីសុខ
ឥតមានសុខណា ស្មើក្តីស្ងប់ បញ្ចប់ត្រឹមសុខ ឃ្លាតចាកទុក្ខ
តាំងពីលោកនេះ តទៅមុខ ក្តីសុខនឹងមាន ព្រោះធម៌ស្ងប់។
៣.ខ្ញុំសូមបង្គំ ឆ្ពោះព្រះធម៌ ព្រះសង្ឃបវរ ទាំងគ្រប់សព្វ
រួមជាត្រៃរ័ត្ន គួរគោរព ជាម្លប់ត្រជាក់ នៃលោកា
ព្រះរូបព្រះធាតុ នៃព្រះពុទ្ធ វិសុទ្ធតាងអង្គ ព្រះសាស្តា
សូមគុណត្រៃរ័ត្ន ជួយខេមរា ឱ្យបានសុខា តរៀងទៅ។

(ព្រះរាជនិពន្ធដោយសម្តេចព្រះសង្ឃរាជ **ជួន ណាត** ជោតញ្ញាណោ)

# អញ្ជើញពពួកទេវតា

សមន្តា ចក្កវាឡេសុ អត្រាគច្ឆន្តុ ទេវតា
សទ្ធម្មំ មុនិរាជស្ស សុណន្តុ សគ្គមោក្ខទំ។

ទេវតាទាំងឡាយ ក្នុងចក្រវាឡទាំងឡាយ ដោយជុំវិញ សូមអញ្ជើញមកប្រជុំគ្នាក្នុងទីនេះ ចូរស្តាប់នូវព្រះសទ្ធម្មជាធម៌អាចឱ្យនូវសួគ៌ និងព្រះនិព្វាន (របស់ព្រះអនាវរណញ្ញាណ) ជាស្តេចនៃអ្នកប្រាជ្ញ។

# បូជាគ្រឿងសក្ការៈគឺគមានទៀនធូប

សីលំ មេ បទុមំ កត្វា ទីបញ្ច នយនា ទ្វយំ
វចសា ធូបការេន មនសា ច សុគន្ធិកំ។

ខ្ញុំសូមឱនសិរសា ធ្វើជាផ្កាឈូកឧត្តម
និងភ្នែកទាំងពីរផ្សំ ទុកជាគ្រឿងប្រទីបថ្លៃ

ព្រមទាំងសុវាចា ខ្ញុំសូមធ្វើជាធូបប្រពៃ
ចិត្តនឹកព្រះរតនត្រ័យ ទុកជាក្លិនក្រអូបហោង។

# ការបូជាផ្កា

(ចូរឧបាសក ឧបាសិកាទាំងឡាយ តាំងសទ្ធាឱ្យខ្ជាប់ខ្ជួន ចំពោះគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ក្នុងចិត្តជាមុន រួចហើយសឹមសូត្រថា)

**ឥមានិ បុប្ផានិ សុវណ្ណគន្ធសម្បន្នានិ សទីបធូបានិ ពុទ្ធស្ស ធម្មស្ស សង្ឃស្ស អភិបូជយាមិ**

ប្រែថា: ខ្ញុំព្រះករុណាសូមបូជានូវផ្កាឈើទាំងឡាយនេះ ដែលប្រកបហើយដោយពណ៌ និងក្លិន ព្រមទាំងប្រទីប និងធូបទាំងឡាយ ចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ។

ឱកាស ពុទ្ធបូជា មហាតេជោ ធម្មបូជា មហា-
បញ្ញោ សង្ឃបូជា មហាធនំ កុសលចេតនានំ
បច្ចយនិព្វានំ សម្បជ្ជយោ ហោន្តុ។

## ថ្វាយគ្រឿងសក្ការៈដល់ព្រះរតនត្រ័យ

ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ
សង្ឃំ អភិបូជយាមិ មាតាបិតាទីនំ គុណ-
វន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ
សុខាយ។

ប្រែថា៖ ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះពុទ្ធ
ព្រះធម៌ ព្រះសង្ឃជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយ
មានទៀន និងធូបជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បី

ជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាយូរអង្វែងទៅហោង។

## ថ្វាយបង្គំព្រះពុទ្ធរតនៈ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

ប្រែថា: វីកិរិយានមស្ការថ្វាយបង្គំ នៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះ-អរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គឥតមានគ្រូអាចារ្យណា ប្រដៅព្រះអង្គឡើយ។

**យោ សន្និសន្នោ វរពោធិមូលេ មារំ ស-សេនំ មហតឹ វិជេយ្យោ សម្ពោធិមាគច្ឆិ អនន្ត-ញ្ញាណោ លោកុត្តមោ តំ បនមាមិ ពុទ្ធំ។**

ប្រែថា៖ ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើននូវព្រះអនាបានស្សតិកម្មដ្ឋាន លើរតនបល្ល័ង្ក ក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជ ព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វ-លោក ខ្ញុំព្រះករុណាសូមក្រាប ថ្វាយបង្គំនូវព្រះសម្មា-សម្ពុទ្ធអង្គនោះ ដោយគោរព។

ពុទ្ធំ ជីវិតំ យាវ និព្វានំ សរណំ គច្ឆាមិ

ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹង ទីរលឹក លុះអស់ជីវិតដរាបដល់ព្រះនិព្វាន។

យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា។

ប្រែថា: ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធ និព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងភទ្រកប្បនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ គ្រប់កាលទាំងពួង។

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ។

ប្រែថា: ឥតិបិ សោ ភគវា អរហំ ព្រះដ៏មាន

ព្រះភាគអង្គនោះទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេស ព្រមទាំងវាសនា គឺកាយបយោគ និងវចីបយោគ សម្មាសម្ពុទ្ធោ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ វិជ្ជាចរណ-សម្បន្នោ ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូរណ៍ដោយវិជ្ជា ៣ និង វិជ្ជា ៨ និងចរណៈ ១៥ សុគតោ ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរស្ថានគឺអមតមហានិព្វាន លោកវិទូ ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់ នូវត្រៃលោក

អនុត្តរោ ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន បុរិសទម្មសារថិ ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន សត្ថាទេវមនុស្សានំ ទ្រង់ព្រះនាមថា សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ ពុទ្ធោ ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញ៉ាំងអ្នកដទៃឱ្យត្រាស់ដឹងផង ភគវា ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ចាក់ចោលហើយ គឺថា ព្រះអង្គមិនត្រឡប់កើតទៀតឡើយ។

## ប្រកាសប្តេជ្ញាខ្លួនដោយពាក្យសច្ចៈថា

នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ។

ប្រែថាៈ នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹង ទីរលឹកនៃខ្ញុំព្រះករុណាមិនមានឡើយ ពុទ្ធោ មេ សរណំ វរំ មានតែព្រះពុទ្ធជាម្ចាស់ ជាទីពឹង ទីរលឹក ដ៏ប្រសើរ របស់ខ្ញុំព្រះករុណា ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ សូមសិរីសួស្តីជ័យមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ។

## សូមខមាទោសចំពោះព្រះពុទ្ធជាម្ចាស់ថា

ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ពុទ្ធេ

យោ ខលិតោ ទោសោ ពុទ្ធេ ខមតុ តំ មមំ។

ប្រែថា: ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវល្អងធូលីព្រះបាទ នៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរ ខ្ពង់ខ្ពស់ដោយអវយវៈ ដ៏ឧត្តមគឺត្បូង ពុទ្ធេ យោ ខលិតោ ទោសោ ទោសឯណា ដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះពុទ្ធជាម្ចាស់ ពុទ្ធោ ខមតុ តំ មមំ សូមព្រះពុទ្ធជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា។

## ថ្វាយបង្គំព្រះធម្មរតនៈ

អដ្ឋង្គិការិយបថោ ជនានំ មោក្ខប្បវេសាយ ឧជូ ច មគ្គោ ធម្មោ អយំ សន្តិករោ បណីតោ និយ្យានិកោ តំ បនមាមិ ធម្មំ។

ប្រែថា: ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរ នៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញ៉ាំងជន ដែលប្រាថ្នានូវព្រះនិព្វាន ឱ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះ ជាធម៌ធ្វើឱ្យត្រជាក់ រម្ងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញ៉ាំងសត្វ ឱ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះ ដោយគោរព។

ធម្មំ ជីវិតំ យាវ និព្វានំ សរណំ គច្ឆាមិ

ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរលឹក លុះអស់ជីវិតដរាបដល់ព្រះនិព្វាន។

យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ

សព្វទា។

ប្រែថា៖ ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធនឹងមានមក ក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណាដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ថានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះ គ្រប់កាលទាំងពួង។

> យាវជីវម្បិ ចេ ពាលោ បណ្ឌិតំ បយិរុបាសតិ ន សោ ធម្មំ វិជានាតិ ទព្វិ សូបរសំ យថា = ពាលខ្លៅចូលនៅផង បណ្ឌិតលុះត្រាអស់ជីវិតលង់អនេក មិនដឹងរសធម៌អាថ៌ជាឯក ដូចជាវែកមិនដឹងរសសម្ល។

## ឱនកាយហើយតាំងចិត្តរលឹកដល់ធម្មគុណថា

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ

អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ។

ប្រែថាៈ ស្វាក្ខាតោ ភគវតា ធម្មោ ព្រះបរិយ-ត្តិធម៌គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងហើយដោយល្អ ធម្មោ ព្រះនព្វលោកុ-ត្តរធម៌មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១ សន្ទិដ្ឋិកោ ជាធម៌ គឺព្រះអរិយបុគ្គលទាំងពួងដឹងពិតឃើញពិត ដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹងដោយស្តាប់ដោយជឿបុគ្គលដទៃនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង អកាលិកោ ជាធម៌ឱ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានយឺនយូរឡើយ ឯហិបស្សិកោ ជាធម៌គួរដល់ឯហិបស្សវិធី គឺថា បើ

ព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឱ្យចូលមកមើលបាន ឱបនយិកោ ជាធម៌គឺព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន។

## ប្រកាសប្តេជ្ញាខ្លួនដោយពាក្យសច្ចៈថា

នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ។

ប្រែថា: នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរលឹកនៃខ្ញុំព្រះករុណាមិនមានឡើយ ធម្មោ មេ សរណំ វរំ មានតែព្រះធម៌ជាម្ចាស់ ជាទីពឹងទីរលឹក ដ៏

ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជ័យមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ។

## សូមខមាទោសចំពោះព្រះធម៌ជាម្ចាស់

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ។**

ប្រែថា: **ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរ មានពីរប្រការ គឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តមគឺត្បូង **ធម្មេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយក្នុងព្រះធម៌ជាម្ចាស់ **ធម្មោ ខមតុ តំ មមំ** សូមព្រះធម៌ជាម្ចាស់ អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា។

# ថ្វាយបង្គំព្រះសង្ឃរតនៈ

សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ សន្តិ-
ន្ទ្រិយោ សព្វមលប្បហីនោ គុណេហិនេកេហិ
សមិទ្ធិបត្តោ អនាសវោ តំ បនមាមិ សង្ឃំ។

ប្រែថា: ព្រះអរិយសង្ឃឯណាដ៏បរិសុទ្ធវិសេសជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយ៍រម្ងាប់ហើយ មានមន្ទិលគឺរាគាទិក្កិលេសទាំងពួង បន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយ នូវកិរិយាសម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌ មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះអរិយសង្ឃនោះ ដោយគោរព។

**សង្ឃំ ជីវិតំ យាវ និព្វានំ សរណំ គច្ឆាមិ**

ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹង ទីរលឹក លុះអស់ជីវិត ដរាបដល់ព្រះនិព្វាន។

**យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា។**

ប្រែថាៈ ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផលកន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃនឹងបានសម្រេចមគ្គ និងផល ក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផលក្នុងកាលជាបច្ចុប្បន្ននេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយ

បង្គំ នូវព្រះសង្ឃទាំងឡាយនោះ គ្រប់កាលទាំងពួង។

## ឱនកាយវាចាហើយ
## តាំងចិត្តរលឹកដល់សង្ឃគុណថា

សុបដិបន្នោ ភគវតោ សាវកសង្ឃោ
ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ
ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ
សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ
យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា
ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ
បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករ-
ណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ។

ប្រែថា: សុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លង ព្រះនព្វលោកុត្តរធម៌ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមបដិបទា ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាឋានក្សេមផុត ចាកទុក្ខទាំងពួង សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា យទិទំ ចត្តារិ បុរិសយុគានិ ព្រះសង្ឃឯណា បើ

រាប់ជាគូនៃបុរសទាំងឡាយមាន ៤ គូ គឺព្រះសង្ឃ ដែលបានសម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិ-ផលជាគូ ១ សកទាគាមិមគ្គ និងសកទាគាមិផលជាគូ១ អនាគាមិមគ្គ និងអនាគាមិផលជាគូ ១ អរហត្តមគ្គ និង អរហត្តផលជាគូ ១ អដ្ឋ បុរិសបុគ្គលា បើរាប់រៀង ជាបុរសបុគ្គលមាន ៨ គឺ ព្រះសង្ឃដែលបានសម្រេច នូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១ ឯស ភគវតោ សាវកសង្ឃោ ព្រះសង្ឃទាំងនុ៎ះ ជាសង្ឃសាវ័កនៃ ព្រះដ៏មានព្រះភាគ អាហុនេយ្យោ លោកគួរទទួល នូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយ នាំមកអំពីចម្ងាយបង្អោនចូលមកបូជា បាហុ-

នេយ្យោ លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែង ដើម្បីញាតិ និងមិត្រដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា ទក្ខិណេយ្យោ លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្ម និងផលនៃកម្មហើយបូជា អញ្ជលិករណីយោ លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន។

## ប្រកាសប្តេជ្ញាខ្លួនដោយពាក្យសច្ចៈថា

នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ។

ប្រែថា: នត្ថិ មេ សរណំ អញ្ញំ វត្ថុដទៃជាទីពឹងទីរលឹកនៃខ្ញុំព្រះករុណាមិនមានឡើយ សង្ឃោ មេ សរណំ វរំ មានតែព្រះសង្ឃជាម្ចាស់ជាទីពឹងទីរលឹក ដ៏ប្រសើររបស់ខ្ញុំព្រះករុណា ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ សូមសិរីសួស្តីជ័យមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ។

## ខមាទោសចំពោះព្រះសង្ឃ

ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ សង្ឃេ យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ។

ប្រែថា: ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះ

សង្ឃដ៏ប្រសើរមានពីរប្រការ គឺសម្មតិសង្ឃ និងអរិយសង្ឃ ដោយអវយវៈដ៏ឧត្តមគឺត្បូង **សង្ឃេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ ហើយក្នុងព្រះសង្ឃជាម្ចាស់ **សង្ឃោ ខមតុ តំ មមំ** សូមព្រះសង្ឃជាម្ចាស់ អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា។

## ថ្វាយបង្គំព្រះរតនត្រៃដោយសង្ខេប

កែវមួយគឺព្រះពុទ្ធ វិសេសសុទ្ធអង្គឯណា
ដែលមនុស្ស និងទេវតា តែងបូជាដោយនិរន្តរ៍
កែវមួយ គឺព្រះធម៌ ថ្លៃបវរវិសេសលន់
មានគុណជាអនន្ត ប្រាសនិរាសចាកកិលេស
កែវមួយគឺព្រះសង្ឃ លោកទ្រទ្រង់សីលវិសេស
ឥតទោសគឺកិលេស ជាស្រែបុណ្យសត្វទាំងឡាយ
អានុភាពនៃត្រ័យរ័ត្ន សុំកម្ចាត់នូវអន្តរាយ
នៃខ្ញុំអ្នកថ្វាត់ថ្វាយ បង្គំដោយក្តីគោរព។

# នមស្ការបូជនីយវត្ថុជាទីគោរព

វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេសុ បតិដ្ឋិតំ សារីរិកធាតុមហាពោធឹ ពុទ្ធរូបំ សកលំ សទា ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះចេតិយទាំងអស់ ដែលប្រតិស្ឋានល្អហើយក្នុងទីទាំងពួង នូវព្រះមហាពោធិព្រឹក្ស និងព្រះសារីរិកធាតុផង នូវព្រះពុទ្ធរូបទាំងអស់ផង ក្នុងកាលទាំងពួង។

## ប្រែមួយបែបទៀត

ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតីយ៍
ព្រមទាំងព្រះសារី- រិកធាតុនៃព្រះពុទ្ធ
និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត
លំឱនចិត្តបរិសុទ្ធ លើកកំបង់អញ្ជលី
និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី

ដែលស្ថិតនៅគ្រប់ទី ឋាននានានោះទាំងអស់  
ដោយតេជៈនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់  
ដែលតែងតែរំលស់ រំដោះទុក្ខភ័យអន្តរាយ  
សូមឱ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ  
សត្រូវទោះជិតឆ្ងាយ សូមឱ្យក្លាយមកជាមិត្រ  
សូមទាន់ព្រះអរិយ- មេត្តេយ្យថ្លៃវិសិដ្ឋ  
សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង។

> មហុត្តម្បិ ចេវញ្ញូ បណ្ឌិតំ បយិរុបាសតិ ខិប្បំ ធម្មំ វិជានាតិ ជិវ្ហា សូបរសំ យថា = ជាតិប្រាជ្ញនៅជិតបណ្ឌិត គឺប្រាជ្ញតែមួយរំពេច ក៏អាចចេះធម៌ អាថ៌ ដូចអណ្តាតដឹងរសនៃអាហារជូរចត់ខារហឹរប្រៃក្តីណា ក៏អាចដឹងបាន។

# នមស្ការនូវព្រះពុទ្ធបាទ

វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ តិលោកកេតុំ  
តិភវេកនាថំ យោ លោកសេដ្ឋោ សកលំ

កិលេសំ ឆេត្វាន ពោធេសិ ជនំ អនន្តំ។

ប្រែថា: ព្រះសម្មាសម្ពុទ្ធឯណា ព្រះអង្គប្រសើរ ក្នុងលោក ទ្រង់កាត់បង់នូវកិលេសទាំងអស់បានហើយ ញ៉ាំងជនជាអនន្ត ឱ្យត្រាស់ដឹងហើយ ខ្ញុំសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គឆ្លងផុតអំពីច្រាំងនៃភពហើយ ព្រះអង្គជាទង់ជ័យនៃត្រៃលោក មានតែព្រះអង្គមួយ ជាទីពឹងនៃសព្វសត្វក្នុងត្រៃភព។

យំ នម្មទាយ នទិយា បុលិនេ ច តីរេ យំ សច្ចពន្ធគិរិកេ សុមនាចលគ្គេ យំ តត្ថ យោនក-បុរេ មុនិនោ ច បាទំ តំ បាទលញ្ឆនមហំ សិរសា នមាមិ ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើផ្នូរខ្សាច់ទៀបឆ្នេរនៃស្ទឹងឈ្មោះនម្មទា ស្នាមព្រះព្រះបាទឯណា (ដែលព្រះសម្ពុទ្ធ

ទ្រង់ប្រតិស្ឋានទុក) លើភ្នំសច្ចព័ន្ធ និងលើភ្នំសុមនកូដ ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) ក្នុងយោនកបុរី ខ្ញុំសូមក្រាបថ្វាយបង្គំ ដោយត្បូងចំពោះទៅព្រះបាទ និងស្នាមព្រះបាទទាំងនោះ នៃព្រះសក្យមុនី។

**សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ យោនកបុរេ នម្មទាយ នទិយា បញ្ចបាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ។**

ខ្ញុំសូមនមស្ការអំពីចម្ងាយ នូវស្ថានដែលមានព្រះបាទដ៏ប្រសើរ ៥ កន្លែងគឺស្ថានលើភ្នំសុវណ្ណមាលិក ១ លើភ្នំសុវណ្ណបព៌ត ១ លើភ្នំសុមនកូដ ១ ក្នុងយោនក-បុរី ១ ក្បែរស្ទឹងនម្មទា ១។

| | |
|---|---|
| កុំស្តាប់ហួសឮ | កុំមើលហួសឃើញ |
| កុំតឹងមុនទាញ | កុំជំនាញមុនចេះ។ |

# នមស្ការព្រះរតនត្រ័យ បណាមគាថា

យោ កប្បកោដីហិបិ អប្បមេយ្យំ

កាលំ ករោន្តោ អតិទុក្ករានិ ខេទំ

គតោ លោកហិតាយ នាថោ

នមោ មហាការុណិកស្ស តស្ស

ព្រះពុទ្ធ ជាទីពឹង ជាពុំនឹង សព្វសត្តា

ព្រះអង្គ កាលប្រាថ្នា ធ្វើកសាង អស់កាលយូរ។

រាប់ដោយ កោដិកប្បា ច្រើនគណនា ហួសគិតគូ

បានត្រាស់ ជាសព្វញ្ញូ ត្រាស់ជា គ្រូលើភពឋាន។

ធ្វើកម្ម ជាកម្រ មនុស្សនិករ ត្រាប់ពុំបាន

តោកយ៉ាក លំបាកប្រាណ ព្រោះប្រយោជន៍ ដល់សព្វសត្វ។

ខ្ញុំសូម ឱនសិរសា ចិត្តប្រាថ្នា បង្គំថ្វាត់

ព្រះពុទ្ធ ករុណាសត្វ នោះជាទី ពឹងសព្វកាល។

អសម្ពុធំ ពុទ្ធនិសេវិតំ យំ
ភវាភវំ គច្ឆតិ ជីវលោកោ
នមោ អវិជ្ជាទិក្កិលេសជាលំ
វិទ្ធំសិនោ ធម្មវរស្ស តស្ស។

សត្វតែង កើតស្លាប់បង់ ព្រោះចំណង់ កម្មជាគោល
ឱ្យវិល វល់អន្ទោល ក្នុងភពតូច និងភពធំ។
ហេតុតែ មិនដឹងធម៌ ជាម្ចាស់ល្អ ស្អាតសុខុម
ព្រះពុទ្ធ តែងសេពសម ចិត្តខ្ញុំ សូមនមស្ការ។
នូវធម៌ ប្រពៃពិត វិសេសសុទ្ធ នោះឯងណា
កាត់បង់ នូវអវិជ្ជា គឺបណ្តេញ កិលេសហើយ។

គុណោហិ យោ សីលសមាធិបញ្ញា
វិមុត្តិញ្ញាណប្បភូតីហិ យុត្តោ
ខេត្តញ្ញូនានំ កុសលត្ថិកានំ

## តមរិយសង្ឃំ សិរសា នមាមិ

ព្រះសង្ឃ អង្គសាវ័ក មានសំវរៈ សទ្ធាទ្រង់
កបដោយ គុណសីលត្រង់ និងសមាធិ បញ្ញា។
និងវិមុត្តិញ្ញាណ កិលេសគ្មាន ក្នុងអាត្មា
ជាបុញ្ញក្ខេត្តា ជនត្រូវការ ជាកុសល
ខ្ញុំសូម ឱនសិរសី ដល់ព្រះ អរិយបុគ្គល
ជាបុត្រ ព្រះទសពល ជាមង្គល ដល់សព្វសត្វ។

## ថ្វាយបង្គំសុំសេចក្ដីសុខ

ឥច្ចេវមច្ចន្ត នមស្សនេយ្យំ
នមស្សមានោ រតនត្តយំ យំ
បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ
តស្សានុភាវេន ហតន្តរាយោ

ខ្ញុំសូម នមស្ការ លើកហត្ថា ឱនសិរសី
បង្គំគុណ ទាំង ៣ ខ្ពស់លើសលប់ ត្រៃលោកា
សូមបុណ្យ កងកុសល ឱ្យបានដល់ យើងខ្ញុំណា
ពេញពោរ ស្មើធារា ដូចជលសារ ធំទូលាយ។
សូមឱ្យ កម្ចាត់បង់ អពមង្គល ទាំងឡាយ
ឱ្យចៀស ចេញចាកឆ្ងាយ ក្តីអន្តរាយ កុំបីមាន
ដោយកំលាំង អានុភាព បុញ្ញលាភ ជាប្រធាន
កងបុណ្យ រាសីមាន សូមបានក្សាន្ត កុំមានមោះ។
ដោយគុណ នមស្ការ ត្រៃរតនា ប្រសើរខ្ពស់
សូមអានិសង្សនោះ ដាក់ដល់ថាន និព្វានហោង។

# វិធីរក្សាសីល

នៅក្នុងព្រះអដ្ឋកថា បរមត្ថជោតិកា លោកសំដែងថាៈ សិក្ខាបទទាំងឡាយ មានបាណាតិបាតា វេរមណីសិក្ខាបទជាដើម សាមណេរសមាទាន ក្នុងសំណាក់នៃភិក្ខុប៉ុណ្ណោះ ក៏ឈ្មោះថា សមាទាន, ចំណែកឧបាសក ឧបាសិកា តាំងចិត្តសមាទានដោយខ្លួនឯងក៏បាន សមាទានក្នុងសំណាក់នៃអ្នកដទៃក៏បាន។ តែយកល្អ គួរសមាទានក្នុងសំណាក់អ្នកដទៃ មានភិក្ខុសាមណេរជាដើម ព្រោះប្រយោជន៍ដើម្បីបានធ្វើបុណ្យកុសលផ្សេងៗ ថែមទៀត។

នៅក្នុងសម្មោហវិនោទនី អដ្ឋកថា អភិធម្មបិដក (វិភង្គ) បញ្ជាក់ថា :

បើពោលដោយការសមាទាន, សេចក្តីថា កាលបុគ្គលគ្រាន់តែតាំងចិត្តអធិដ្ឋានថា “បញ្ច សីលានិ អធិដ្ឋាមិ = អាត្មាអញអធិដ្ឋាននូវសីលទាំងឡាយ ៥” ដូច្នេះ ដោយខ្លួនឯងតែម្តងទៅ ដោយការបញ្ចេញវាចាសមាទានកាន់យកនូវសិក្ខាបទទាំងឡាយ ដោយឡែកៗពីគ្នា ក៏ឈ្មោះថា ជាអ្នកសមាទាន។ រីឯបុគ្គល កាលចូលទៅអង្គុយក្នុងសំណាក់នៃអ្នកដទៃ ហើយបញ្ចេញវាចាសមាទានថា “បញ្ច សីលានិ សមាទិយាមិ = ខ្ញុំសូមសមាទាននូវសីលទាំងឡាយ ៥ ” ដោយការសមាទាននូវសិក្ខាបទទាំងឡាយ ដោយឡែកៗ ពីគ្នា ក៏ឈ្មោះថាជាអ្នកសមាទានដែរ។ នៅក្នុងបរមត្ថទីបនី អដ្ឋកថា ខុទ្ទកនិកាយ ឥតិវុត្តកៈ សំដែងថាៈ

សមាទានតោ អញ្ញស្ស គរុដ្ឋានីយស្ស សន្តិកេ

**តំ អលភន្តេន សយមេវ បញ្ច សីលានិ ឯកជ្ឈំ បាដិយេក្កំ វា សមាទិយន្តេន សមាទិន្នានិ ហោន្តិ។**

បើពោលដោយការសមាទាន, សេចក្ដីថា បុគ្គលកាលរកមិនបាននូវអ្នកជាទីគោរពនោះ គឺថា មិនបានចូលទៅក្នុងសំណាក់នៃអ្នកដទៃ ដែលជាទីគោរព ហើយតាំងចិត្តសមាទាននូវសីលទាំងឡាយ ៥ ដោយខ្លួនឯងទោះជាឯកជ្ឈៈ (រួមគ្នា) ក្ដី បច្ចេកៈ (ផ្សេងៗគ្នា) ក្ដី ក៏ឈ្មោះថា ជាអ្នកសមាទានហើយដោយពិត។/

## វិធីសមាទាននិច្ចសីល (សីល ៥)

ពុទ្ធបរិស័ទ ដែលបានដល់ព្រះត្រៃសរណគមន៍ ហើយមាននាមថា ជាឧបាសក-ឧបាសិកា កាលបើសមាទាននិច្ចសីល គឺសីល ៥ (ជាបច្ចេកសមាទាន) អំពីបុគ្គលដទៃ គឺភិក្ខុសាមណេរជាដើម គប្បីស្ងួធ្យ

នមស្ការរំឭកគុណព្រះរតនត្រ័យដោយសង្ខេបថា ៖

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

“សូត្រ ៣ ចប់” ប្រែដូចនមស្ការពិស្តារនៅខាងដើមដែរ។

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថាទេវមនុស្សានំ ពុទ្ធោ ភគវាតិ តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ។

ប្រែ តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ ព្រះករុណាសូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គប្រកបព្រមហើយដោយគុណ មានគុណថា

អរហំ ជាដើមនោះ ដោយសិរសា គឺត្បូង តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ។

ក្រាបថ្វាយបង្គំម្តង

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ។

ប្រែ តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ ជាម្ចាស់

ដ៏ប្រកបព្រមហើយដោយគុណ មានគុណថា ស្វាក្ខាតោ ជាដើមនោះ ដោយសិរសា គឺត្បូង តព្វ ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះធម៌ជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ។

សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ

អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ តំ សុបដិបន្នា-
ទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ តញ្ច សង្ឃំ
ឥមេហិ សក្ការេហិ អភិបូជយាមិ។

ប្រែៈ តំ សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ
សិរសា នមាមិ ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះ
សង្ឃជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណ មានគុណថា
សុបដិបន្នោ ជាដើមនោះ ដោយសិរសា គឺត្បូង តញ្ច
សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ ខ្ញុំព្រះ-
ករុណាសូមបូជាចំពោះនូវព្រះសង្ឃជាម្ចាស់នោះ ដោយ
គ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ។

ក្រាបថ្វាយបង្គំម្តង

# វិធីសុំនិច្ចសីលជាបច្ចេកសមាទាន

ម្នាក់ឯងថា អហំ / ពីរនាក់ថា មយំ

ឱកាស { អហំ / មយំ } ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ

តិសរណេន សហ បញ្ចសីលានិ យាចា { ម្នាក់ឯងថា មិ / ពីរនាក់ថា ម }

{ ទុតិ / តតិ } យម្បិ { អហំ / មយំ } ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ

តិសរណេន សហ បញ្ចសីលានិ យាចា { មិ / ម }

សូមគោរពបពិត្រព្រះករុណាដ៏ចម្រើន

{ ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ } សូមនូវសីលទាំងឡាយ

៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗ គ្នា។ បពិត្រព្រះករុណាដ៏ចម្រើន

ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ } សូមនូវសីលទាំងឡាយ

៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា ជាគំរប់ពីរដងផង ជាគំរប់បីដងផង។

" ការទទួលសីល គប្បីថាតាមលោកឱ្យច្បាស់ៗ កុំថាខ្សឹបៗ "

## ចាំសូត្រថាតាមលោក

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹង ទីរលឹក។

ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹង ទីរលឹក។

## សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវ ព្រះសង្ឃជាទីពឹង ទីរលឹក។

ទុតិយម្បិ
ពុទ្ធំ
ធម្មំ
សង្ឃំ
សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់

នូវព្រះ
ពុទ្ធ
ធម៌
ជាទីពឹង ទីរលឹក ជាគំរប់ពីរដងផង ។

៣

តតិយម្បិ
ពុទ្ធំ
ធម្មំ
សង្ឃំ
សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់

នូវព្រះ
ពុទ្ធ
ធម៌
សង្ឃ
ជាទីពឹង ទីរលឹក ជាគំរប់ពីរដងផង ។

លោកថា តិសរណគ្គហណំ បរិបុណ្ណំ កិរិយា កាន់យកនូវព្រះត្រៃសរណគមន៍ ចប់បរិបូណ៌តែប៉ុណ្ណេះ (យើងគប្បីទទួលថា **អាម ភន្តេ** = ករុណាលោកម្ចាស់)។

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិត ឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ។

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនា ជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យ ដោយកាយ ឬដោយវាចា។

**កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនា ជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។

មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក។

សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ។

យំ កិញ្ចិ រតនំ លោកេ វិជ្ជតិ វិវិធំ បុថុរតនំ ពុទ្ធសមំ នត្ថិ តស្មា សោត្ថី ភវន្តុ តេ ។

រតនៈឯណាមួយក្នុងលោក មានច្រើនបែប ច្រើនយ៉ាង (រតនៈទាំងនោះ) ពុំស្មើនឹងព្រះពុទ្ធរតនៈឡើយ ព្រោះហេតុនោះ សូមសិរីសួស្តីទាំងឡាយ កើតមានដល់អ្នក។

**យំ កិញ្ចិ រតនំ លោកេ វិជ្ជតិ វិវិធំ បុថុរតនំ ធម្មសមំ នត្ថិ តស្មា សោត្ថី ភវន្តុ តេ។**

រតនៈឯណាមួយក្នុងលោក មានច្រើនបែប ច្រើនយ៉ាង (រតនៈទាំងនោះ) ពុំស្មើនឹងព្រះធម្មរតនៈឡើយ ព្រោះហេតុនោះ សូមសិរីសួស្តីទាំងឡាយ កើតមានដល់អ្នក។

**យំ កិញ្ចិ រតនំ លោកេ វិជ្ជតិ វិវិធំ បុថុរតនំ សង្ឃសមំ នត្ថិ តស្មា សោត្ថី ភវន្តុ តេ។**

រតនៈឯណាមួយក្នុងលោក មានច្រើនបែប ច្រើនយ៉ាង (រតនៈទាំងនោះ) ពុំស្មើនឹងព្រះសង្ឃរតនៈឡើយ ព្រោះហេតុនោះ សូមសិរីសួស្តីទាំងឡាយ កើតមានដល់អ្នក។

# សិទ្ធិយាចនគាថា

សិទ្ធមត្ថុ សិទ្ធមត្ថុ សិទ្ធមត្ថុ ឥទំ ផលំ ឯតស្មឹ រតនត្តយស្មឹ សម្បសាទនចេតសោ សូមផលនៃចិត្ត ដែលជ្រះថ្លា ក្នុងព្រះរតនត្រ័យនោះ ផលនេះ ចូរជា ផលសម្រេច ចូរជាផលសម្រេច ចូរជាផលសម្រេច។

| | |
|---|---|
| បើកភ្នែកកាលណាកិលេសកើត | ទោសៈជើងឆើតអើតខាងស្អប់ |
| រាគៈជើងឯកប៉ែកខាងគាប់ | មោហៈជើងជាប់លេខខាងល្ងង់ |
| យោ នរោ វីនរៈអ្នកចូរប្រឹង | កិលេសអស់ហ្នឹងនាំលិចលង់ |
| គេទៅឋានសួគ៌ឱ្យរហង់ | អ្នកផុងអបាយភូមិសមដែរឬ ? |

# ពិចារណានូវគ្រឿងឧបភោគ-បរិភោគ ឱ្យឃើញត្រឹមតែធាតុ

## **ធាតុប្បច្ចវេក្ខណៈ** បាលី-ប្រែ

ធាតុប្បច្ចវេក្ខណៈនោះ គឺត្រូវពិចារណា ក្នុងពេលដែលទទួលនូវបច្ច័យ៤ ឱ្យឃើញថា ជាធាតុ។ កាលដែលទទួលនូវចីវរប្បច្ច័យ ឱ្យពិចារណាដូច្នេះថា :

យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ ចីវរំ តទុបភុញ្ជកោ ច បុគ្គលោ ធាតុ-មត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ។

សំពត់ចីវរឯណានេះ សំពត់ចីវរនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គលគឺអាត្មា ដែលជាអ្នកប្រើប្រាស់សំពត់ចីវរនោះក្តីក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ

មានសភាពសោះសូន្យទទេ។

កាលដែលទទួលនូវបិណ្ឌបាតបច្ច័យ ឱ្យពិចារណាដូច្នេះថា:

យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ បិណ្ឌបាតោ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ។

ចង្ហាន់បិណ្ឌបាតឯណានេះ ចង្ហាន់បិណ្ឌបាតនេះគ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យទុកជាបុគ្គលគឺអាត្មា ដែលជាអ្នកបរិភោគចង្ហាន់បិណ្ឌបាតនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ។

កាលដែលទទួលនូវសេនាសនបច្ច័យ ឱ្យពិចារណាដូច្នេះថា:

យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ សេនាសនំ តទុបភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ។

ទីសេនាសនៈឯណានេះ ទីសេនាសនៈនេះគ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មា ដែលជាអ្នកបរិភោគប្រើប្រាស់ ទីសេនាសនៈនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ។

កាលដែលទទួលនូវគិលានប្បច្ច័យ ឱ្យពិចារណាដូច្នេះថា:

យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ គិលានប្បច្ចយភេសជ្ជបរិក្ខារោ តទុប-ភុញ្ជកោ ច បុគ្គលោ ធាតុមត្តកោ និស្សត្តោ

និជ្ជីវោ សុញ្ញោ។

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺឯណានេះ គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជម្ងឺនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគគ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ។

# បដិកូលប្បច្ចវេក្ខណៈ

បដិកូលប្បច្ចវេក្ខណៈ គឺត្រូវពិចារណាក្នុងខណៈដែលប្រារព្ធនឹងបរិភោគនូវបច្ច័យ ៤ ឱ្យឃើញថាជា

របស់បដិកូល គួរខ្ពើមរអើម ។ កាលដែលប្រារព្ធនឹងប្រើប្រាស់នូវចីវរប្បច្ច័យ ឱ្យពិចារណាដូច្នេះថា :

សព្វានិ បនិមានិ ចីវរានិ អជិគុច្ឆនីយានិ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយានិ ជាយន្តិ។

សំពត់ចីវរទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក។

កាលដែលប្រារព្ធនឹងបរិភោគនូវបិណ្ឌបាតប្បច្ច័យ ឱ្យពិចារណាដូច្នេះថា :

សព្វោ បនាយំ បិណ្ឌបាតោ អជិគុច្ឆនីយោ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ។

ចង្ហាន់បិណ្ឌបាតទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះ

កាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក។

កាលដែលប្រាជ្ញនឹងប្រើប្រាស់ នូវសេនាសនៈ- ប្បច្ច័យ ឱ្យពិចារណាដូច្នេះថា:

**សព្វានិ បនិមានិ សេនាសនានិ អជិគុច្ឆនី- យានិ ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយានិ ជាយន្តិ។**

ទីសេនាសនៈទាំងឡាយទាំងពួងនេះ ជារបស់មិន គួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះ កាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក។

កាលដែលប្រាជ្ញនឹងបរិភោគនូវគិលានប្បច្ច័យ ឱ្យ ពិចារណាដូច្នេះថា:

**សព្វោ បនាយំ គិលានប្បច្ចយភេសជ្ជ- បរិក្ខារោ អជិគុច្ឆនីយោ ឥមំ បូតិកាយំ បត្វា**

អតិរិយ ជិគុច្ឆនីយោ ជាយតិ។

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក។

## តង្ខណិកប្បច្ចវេក្ខណៈ

តង្ខណិកប្បច្ចវេក្ខណៈនោះ គឺគប្បីពិចារណាក្នុងខណៈដែលបរិភោគនូវបច្ច័យ ៤ ។

កាលដែលប្រើប្រាស់នូវចីវរប្បច្ច័យ ឱ្យពិចារណាថា:

បដិសង្ខា យោនិសោ ចីវរំ បដិសេវាមិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ

**បដិឃាតាយ យាវទេវ ហិរិកោបិនប្បដិច្ឆាទនត្ថំ។**

(សីលវន្ត = បុរសមានសីលជាធម្មតា, សីលវតី = ស្ត្រីមានសីលជាធម្មតា) គប្បីពិចារណាដោយឧបាយថា :

អញអាស្រ័យសេព គឺប្រើប្រាស់នូវសំពត់ចីវរកំណត់ទុកដើម្បីការពារនូវត្រជាក់ ដើម្បីនឹងការពារនូវសម្ផស្សរបោម មូស ខ្យល់ កំដៅថ្ងៃ និងពស់តូចពស់ធំទាំងឡាយ កំណត់ទុកដើម្បីនឹងបិទបាំងនូវអវៈយវៈដែលធ្វើនូវសេចក្ដីខ្មាសឱ្យកម្រើក។

កាលដែលបរិភោគ នូវបិណ្ឌបាតបច្ច័យ គប្បីពិចារណាដូច្នេះថា :

**បដិសង្ខា យោនិសោ បិណ្ឌបាតំ បដិសេវាមិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា**

យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គ-ហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ។

សីលវន្ត-សីលវតី គប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេព គឺបរិភោគចង្ហាន់បិណ្ឌបាត ដើម្បីនឹងលេងដូចក្មេងអ្នកស្រុកក៏ទេ ដើម្បីនឹងឱ្យកើតបុរិស-មានៈស្រវឹងដូចអ្នកប្រដាល់ក៏ទេ ដើម្បីនឹងប្រដាប់តាក់តែងរាងកាយដូចស្ត្រីក្នុងបុរីក៏ទេ ដើម្បីនឹងធ្វើឱ្យផូរផង់សម្បុរដូចអ្នកលេងរបាំក៏ទេ បរិភោគកំណត់ទុកដើម្បីនឹងឱ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញ៉ាំងជីវិតិន្ទ្រិយ ឱ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចារី អញនឹងកម្ចាត់បង់នូវវេទនា

ចាស់ គឺសេចក្តីឃ្លានដែលមានហើយផង និងញុំាងវេទនាថ្មី គឺឆ្អែតហួសប្រមាណ មិនឱ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តីមិនមានទោសមានមិនច្រអូសកាយ មិនច្រអូសចិត្ត ជាដើមក្តី កិរិយានៅសប្បាយក្នុងឥរិយាបថទាំង ៤ ក្តី នឹងមានដល់អញដោយបានបរិភោគនូវចង្ហាន់បិណ្ឌបាតនេះ។

កាលដែលបរិភោគប្រើប្រាស់ នូវសេនាសនប្បច្ច័យឱ្យពិចារណាដូច្នេះថា:

បដិសង្ខា យោនិសោ សេនាសនំ បដិ-សេវាមិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរិ-សបសម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុ-បរិស្សយវិនោទនំ បដិសល្លានារាមត្ថំ។

សីលវន្ត-សីលវតី គប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេព គឺបរិភោគប្រើប្រាស់នូវសេនាសនៈ កំណត់ទុកដើម្បីនឹងការពារនូវត្រជាក់ ដើម្បីការពារនូវកំដៅ ដើម្បីការពារនូវសម្ផស្សរបោម មូស ខ្យល់ កំដៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ កំណត់ទុកដើម្បីនឹងបន្ទោបង់នូវក្រវល់ក្រវាយ ដែលកើតឡើងអំពីរដូវ ហើយអភិរម្យសម្ងំនៅក្នុងកម្មដ្ឋាន។

កាលដែលបរិភោគនូវគិលានប្បច្ច័យ ឱ្យពិចារណាដូច្នេះថា :

បដិសង្ខា យោនិសោ គិលានប្បច្ចយ-ភេសជ្ជបរិក្ខារំ បដិសេវាមិ យាវទេវ ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យា-បជ្ឈបរមតាយាតិ។

សីលវន្ត សីលវតី គប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេព គឺបរិភោគនូវគ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ កំណត់ទុកដើម្បីនឹងការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា។

# អតីតប្បច្ចវេក្ខណៈ

អតីតប្បច្ចវេក្ខណៈនោះ គឺឱ្យពិចារណានូវបច្ច័យ៤ ក្នុងអតីតកាល គឺកាលដែលបរិភោគរួចហើយ ដែលត្រូវពិចារណាបានក្នុងថ្ងៃនោះ គឺក្នុងវេលាថ្ងៃ ១ យប់ ១ កុំឱ្យអរុណរះឡើងទាន់ ហើយក្នុងបច្ចវេក្ខណៈមួយៗ ពិចារណា ១ ចប់ ឬ ២ ចប់ ៣ ចប់ ឬច្រើន ជាងនេះ

ទៅទៀតក៏បាន។

អជ្ជ មយា អបច្ចវេក្ខិត្វា យំ ចីវរំ បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិ-ឃាតាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោបិនប្បដិច្ឆាទនត្ថំ។

សំពត់ចីវរឯណា ដែលអញមិនបានពិចារណាហើយ ប្រើប្រាស់ហើយក្នុងថ្ងៃនេះ សំពត់ចីវរនោះ អញប្រើប្រាស់ កំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារ នូវកំដៅ ដើម្បីនឹងការពារនូវសម្ផស្ស របោម មូស ខ្យល់ កំដៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ កំណត់ទុកដើម្បីនឹង បិទបាំងនូវអវយវៈដែលធ្វើនូវសេចក្តីខ្មាសឱ្យកម្រើកបាន។

អជ្ជ មយា អបច្ចវេក្ខិត្វា យោ បិណ្ឌបាតោ បរិភុត្តោ សោ នេវ ទវាយ ន មទាយ ន

មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោចាតិ ។

ចង្ហាន់បិណ្ឌបាតឯណា ដែលអញមិនបានពិចារណាហើយ បរិភោគហើយក្នុងថ្ងៃនេះ ចង្ហាន់បិណ្ឌបាតនោះ អញបរិភោគកំណត់ទុក ដើម្បីនឹងលេង ដូចក្មេងអ្នកស្រុកក៏ទេ ដើម្បីនឹងឱ្យកើតបុរិសមានៈស្រវឹង ដូចអ្នកប្រដាល់ក៏ទេ ដើម្បីនឹងប្រដាប់តាក់តែងរាងកាយ ដូចស្ត្រីក្នុងបុរីក៏ទេ ដើម្បីនឹងធ្វើឱ្យផូរផង់ សម្បុរដូចអ្នកលេងរបាំក៏ទេ បរិភោគកំណត់ទុកដើម្បីនឹងឱ្យតាំងនៅនៃកាយនេះ

ដើម្បីនឹងញ៉ាំងជីវិតិន្ទ្រីយ៍ ឱ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចារី អញនឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានដែលមានហើយផង នឹងញ៉ាំងវេទនាថ្មី គឺឆ្អែតហួសប្រមាណ មិនឱ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តីមិនមានទោស មានមិនច្រអូសកាយ មិនច្រអូសចិត្ត ជាដើមក្តី កិរិយានៅសប្បាយក្នុងឥរិយាបថទាំង ៤ ក្តី នឹងមានដល់អញ ដោយបានបរិភោគនូវចង្ហាន់បិណ្ឌបាតនេះ។

អជ្ជ មយា អបច្ចវេក្ខិត្វា យំ សេនាសនំ បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរឹ-សបសម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុ-បរិស្សយ វិនោទនំ បដិសល្លានារាមត្ថំ។

ទីសេនាសនៈឯណា ដែលអញមិនបានពិចារណាហើយ បរិភោគប្រើប្រាស់ហើយក្នុងថ្ងៃនេះ ទីសេនាសនៈនោះ អញបរិភោគកំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកម្តៅ ដើម្បីនឹងការពារនូវសម្ផស្ស របោមមូស ខ្យល់ កំដៅថ្ងៃ និងពស់តូចពស់ធំទាំងឡាយ កំណត់ទុក ដើម្បីនឹងបន្ទោបង់នូវក្រវល់ក្រវាយ ដែលកើតអំពីរដូវ ហើយអភិរម្យសម្ងំនៅក្នុងកម្មដ្ឋាន។

អជ្ជ មយា អបច្ចវេក្ខិត្វា យោ គិលានប្បច្ចយភេសជ្ជបរិក្ខារោ បរិភុត្តោ សោ យាវទេវ ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយាតិ។

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់

អ្នកជំងឺឯណា ដែលអញមិនបានពិចារណាហើយ បរិភោគហើយក្នុងថ្ងៃនេះ គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនោះ អញបរិភោគកំណត់ទុកដើម្បីនឹងការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា។

**ចំណាំ :** បើកាលដែលទទួល និងកាលដែលប្រារព្ធដើម្បីបរិភោគ និងកាលដែលបរិភោគនោះ បានពិចារណាដោយធាតុប្បច្ចវេក្ខណៈ ដោយបដិកូលប្បច្ចវេក្ខណៈ ដោយតង្ខណិកប្បវេក្ខណៈ រួចសព្វគ្រប់ហើយ និងមិនបាច់ពិចារណា ក្នុងអតីតប្បច្ចវេក្ខណៈទៀត ក៏បានដែរ។

| | |
|---|---|
| រៀនធម៌ច្រើនណាស់ | ខ្លួនរឹតតែចាស់ប៉ះញើកៗ |
| បុណ្យរិតតែដាបបាបរឹតតែបើក | ចិត្តដើររវើកជាងក្តាមសមុទ្រ។ |

# ធម៌សូត្រម៉ោង ៣ កន្លះជិតភ្លឺ

១_នមោ តស្ស...
២_ពុទ្ធំ ជីវិតំ...
៣_ឥតិបិសោ ភគវា...
៤_ធម្មំ ជីវិតំ...
៥_ស្វាក្ខាតោ...
៦_សង្ឃំ ជីវិតំ...
៧_សុបដិបន្នោ ភគវតោ...
៨_កែវមួយ គឺព្រះពុទ្ធ...
៩_វន្ទាមិ ចេតិយំ...
១០_វន្ទាមិ ពុទ្ធំ....
១១_យោ កប្បកោដី...
១២_ឥច្ចេវមច្ចន្ត...
១៣_បរាភវសូត្រ...
១៤_ពុទ្ធជយមង្គល...
១៥_មហាការុណិកោ...
១៦_វិធីសមាទានឧបោសថសីល...
១៧_ហន្ទ មយំ អភិណ្ហប្បច្ចវេក្ខណៈ
១៨_ទសជាតិ...
១៩_ហោតុ សព្វំ...
២០_ឥទំ វត នោ...
២១_ឥមិនា...
២២_យំ កិញ្ចិ... + អាកាសដ្ឋា...
២៣_យា ទេវតា...
២៤_សព្វេ បុរត្ថិមា...
២៥_សុខោ ពុទ្ធា...
២៦_ភន្តេ ភគវា...
២៧_តេជៈខ្ញុំសាង...
២៨_ទីមួយ សីលបាណា...

អហំ វីខ្ញុំសូមបន្ទន់ ឱនកាយអភិវន្ទគោរពក្រែង
ចំពោះអ្នកសិក្សាគ្រប់កន្លែង សូមថ្លែងអំណរដ៏ថ្លាថ្លៃ ។
វីផលដែលខ្ញុំបានរិះគិត ត្រិះរិះពិនិត្យក្នុងហឫទ័យ
ខ្ញុំសូមបង្គំឱនសិរសី លើកដៃប្រណម្យសូមប្រាថ្នា ។
ទោសកាមទាំងឡាយសូមឆ្ងាយបង់ យល់ល្អត្រូវត្រង់ដោយបញ្ញា
ឃើញទោសកាមគុណដូចសច្ចា កុំបីយល់ថាទោសជាគុណ ។
សូមបានក្រេបផឹកទឹកអម្រិត ត្រជាក់ពេកពិតប្រសើរលន់
ភពបីវែងទុក្ខក្រៃពេកពន់ សូមបុណ្យនាំចេញដូចប្រាថ្នា ។
បើមិនទាន់ដល់អមតៈឋាន នោះខ្ញុំសូមមានចិត្តចេតនា
ប្រោះព្រំដោយក្លិននៃកុសលា ដូចក្លិនបុប្ផាពិដោរឈ្ងប់ ។
បើខ្ញុំនៅត្រាច់អន្ទោលទៅ គឺនៅមិនទាន់ប្រាសចាកភព
នោះខ្ញុំសូមបានរួមប្រសព្វ អំពីប្រភពអ្នកមានសីល ។
សូមមានវាចាសុភាសិត ផ្អែមដូចអម្រិតប្រាសមន្ទិល
គ្រប់ជាតិខ្ញុំសូមជាប់នូវសីល ជាសីលដូរជីវិតពិតឥតស្តាយ ។
ដោយផលធម្មទានជាកំណត់ សច្ចាគ្រប់បទកុំបីណាយ
សូមស្ថិតនៅនិត្យនឹងចិត្តកាយ កុំបីក្លាយជាប្រការដទៃ ។
វីផលធម្មទានមានឥទ្ធិពល សូមបុណ្យបានដល់បុព្វការី
ឧបជ្ឈាយាចារ្យបងប្រុសស្រី ដែលជាប់និស្ស័យគ្រប់ជាន់ជាតិ។
មួយអន្លើដោយសត្វគ្រប់ៗឋាន ព្រមទាំងគ្រប់ប្រាណសន្តានញាតិ

ដែលជាប់និស្ស័យជាទាយាទ ដែលឃ្លាតព្រោះចាញ់មច្ចុមារ ។
សូមអញ្ជើញលោកមកទទួលផល ធម្មទានកុសលដ៏ថ្លៃថ្លា
ក្ដីសុខចំរើនគ្រប់ប្រការ ស្រេចតាមប្រាថ្នានៃលោកចុះ ។

# ថ្វាយបង្គំព្រះពុទ្ធ ៥ ព្រះអង្គ

ខ្ញុំសូមវន្ទា នូវព្រះឈ្នះមារ ទាំងប្រាំព្រះអង្គ
ដោយនូវអញ្ជលី ទាំងពីរក្រពុំ ដ៏យ៉ាងសមរម្យ
ទីឋាននេះណា។

ព្រះកុក្កសន្ធោ ព្រះកោនាគមនោ ព្រះកស្សបោ
ព្រះសមណគោ- តមបរមពុទ្ធោ ព្រះមេត្តេយ្យោ
ពោធិសត្វថ្លៃ។

ព្រមទាំងព្រះធម៌ ជ្រាលជ្រៅបវរ ល្អប្រសើរក្រៃ
៨ ម៉ឺន ៤ ពាន់ ធម្មក្ខន្ធនេះន័យ របស់ព្រះជិនស្រី
ទីនៃរាល់អង្គ។

ព្រមទាំងព្រះសង្ឃ ប្រសើរសីលទ្រង់ ជាបុត្រព្រះពុទ្ធ

លះកាត់តណ្ហា ប្រសើរបំផុត ខ្ញុំសូមលំអុត
កាយវាចាចិត្ត។
ដោយតេជះខ្ញុំ លើកហត្ថប្រណម្យ ដាក់លើសិរសា
សូមកម្ចាត់បង់ សត្រូវនានា ទុក្ខសោករោគា
វិនាសទៅហោង។

# បរាភវសូត្រ

**ឯវម្មេ សុតំ** (សូត្រនេះឈ្មោះបរាភវសូត្រ) គឺខ្ញុំឈ្មោះអានន្ទបានស្តាប់មកហើយយ៉ាងនេះថា ៖

**ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ។**

សម័យមួយព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។

**អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ។**

លំដាប់នោះឯង ទេវតាអង្គ ១ កាលដែលវេលារាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏ល្អញ៉ាំងវត្តជេតពនជុំវិញទាំងអស់ ឱ្យភ្លឺស្វាងហើយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងទីណា ក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំចំពោះអង្គ ព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ។

**ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ ។**

កាលទេវតានោះឈរក្នុងទីដ៏សមគួរហើយ ទើប

ក្រាបទូលព្រះដ៏មានព្រះភាគ ដោយពាក្យ ជាគាថា (យ៉ាងនេះ) ថា:

**បរាភវន្តំ បុរិសំ មយំ បុច្ឆាម គោតមំ ភវន្តំ បុដ្ឋុមាគម្ម កឹ បរាភវតោ មុខំ**

យើងខ្ញុំទាំងឡាយ មកដើម្បីទូលសួរបុរសបុគ្គល អ្នកមានសេចក្តីវិនាស ចំពោះព្រះគោតមដ៏មានជោគ ហេតុដូចម្តេច ដែលជាប្រធានរបស់បុគ្គល អ្នកមានសេចក្តីវិនាស។

(ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា:)

**១-សុវិជានោ ភវំ ហោតិ សុវិជានោ បរាភវោ ធម្មកាមោ ភវំ ហោតិ ធម្មទេស្សី បរាភវោ។**

បុគ្គលអ្នកមានសេចក្តីចម្រើន គេក៏ងាយដឹង បុគ្គលអ្នកមានសេចក្តីវិនាស គេក៏ងាយដឹងដែរ (ដូចជា) បុគ្គល

អ្នកស្រឡាញ់ធម៌ ជាអ្នកមានសេចក្តីចម្រើន បុគ្គលអ្នកស្អប់ធម៌ ជាអ្នកមានសេចក្តីវិនាស។

**២_អសន្តស្ស បិយា ហោន្តិ សន្តេន កុរុតេ បិយំ អសតំ ធម្មំ រោចេតិ តំ បរាភវតោ មុខំ។**

បុគ្គលអ្នកមានសេចក្តីស្រឡាញ់ តែពួកមនុស្សអសប្បុរស មិនធ្វើសេចក្តីស្រឡាញ់រាប់អាន ចំពោះជនដែលជាសប្បុរស ចូលចិត្តតែនឹងធម៌របស់ពួកអសប្បុរស ហេតុនោះ ជាប្រធានរបស់បុគ្គលអ្នកមានសេចក្តីវិនាស។

**៣_និទ្ទាសីលី សភាសីលី អនុដ្ឋាតា ច យោ នរោ អលសោ កោធបញ្ញាណោ តំ បរាភវតោ មុខំ**

បុគ្គលដែលដេកច្រើន ហៃប្រជុំគ្នានិយាយលេង មិនមានសេចក្តីប្រឹងប្រែង ខ្ជិលច្រអូស ឆាប់ខឹងឱ្យគេឃើញប្រាកដ ហេតុនោះជាប្រធាន របស់បុគ្គលអ្នក

មានសេចក្ដីវិនាស។

៤.យោ មាតរំ បិតរំ វា ជិណ្ណកំ គតយោព្វនំ

បហុសន្តោ ន ភរតិ តំ បរាភវតោ មុខំ។

បុគ្គលអ្នកមានទ្រព្យច្រើន មិនចិញ្ចឹមមាតាផង បិតាផង ដែលមានវ័យចាស់ហើយ ហេតុនោះជាប្រធានរបស់បុគ្គលអ្នកមានសេចក្ដីវិនាស។

៥.យោ សមណំ ព្រាហ្មណំ វា អញ្ញំ វាបិ វនិព្វកំ

មុសាវាទេន វញ្ចេតិ តំ បរាភតោ មុខំ។

បុគ្គលដែលបញ្ឆោតសមណៈក្ដី ព្រាហ្មណ៍ក្ដី ឬក៏ស្មូមយាចកដទៃក្រៅពីនោះក្ដី ដោយពាក្យមុសាវាទ ហេតុនោះ ជាប្រធានរបស់បុគ្គលអ្នកមានសេចក្ដីវិនាស។

៦.បហុតវិត្តោ បុរិសោ សហិរញ្ញោ សភោជនោ

ឯកោ ភុញ្ជតិ សាទូនិ តំ បរាភវតោ មុខំ ។

បុរសអ្នកមានទ្រព្យច្រើន មានមាសប្រាក់ មានភោជនាហារ (ហើយ) លបលាក់ស៊ីរបស់ដែលមានរសឆ្ងាញ់ពិសារទាំងឡាយតែម្នាក់ឯង ហេតុនោះជាប្រធានរបស់បុគ្គលអ្នកមានសេចក្ដីវិនាស ។

៧_ជាតិត្ថទ្ធោ ធនត្ថទ្ធោ គោត្តត្ថទ្ធោ ច យោ នរោ សញ្ញាតឹ អតិមញ្ញេតិ តំ បរាភវតោ មុខំ

នរជនដែលប្រកាន់ជាតិ ប្រកាន់ទ្រព្យ ប្រកាន់ត្រកូល ហើយមើលងាយញាតិសន្តានរបស់ខ្លួន ហេតុនោះជាប្រធានរបស់បុគ្គលអ្នកមានសេចក្ដីវិនាស ។

៨_ឥត្ថិធុត្តោ សុរាធុត្តោ អក្ខធុត្តោ ច យោ នរោ លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ។

នរជនដែលលេងស្រ្តីក្តី លេងសុរាក្តី លេងល្បែងភ្នាល់ក្តី តែងធ្វើរបស់ដែលបានហើយៗ ឱ្យខូចខាត

ហេតុនោះ ជាប្រធានរបស់បុគ្គល អ្នកមានសេចក្ដីវិនាស។

**៩_សេហិ ទារេហិ អសន្តុដ្ឋោ វេសិយាសុ បទុស្សតិ**
**ទុស្សតិ បរទារេសុ តំ បរាភវតោ មុខំ។**

បុរសមិនត្រេកអរ នឹងពួកស្ត្រីជាប្រពន្ធរបស់ខ្លួន ហើយទៅប្រទុស្ត គឺត្រូវការនឹងពួកស្រីផ្កាមាស ឬខូចកាច និងពួកស្ត្រីជាប្រពន្ធរបស់ជនដទៃ ហេតុនោះ ជាប្រធានរបស់បុគ្គលអ្នកមានសេចក្ដីវិនាស។

**១០_អតីតយោព្វនោ បោសោ អានេតិ តិម្ពរុត្ថនី**
**តស្សា ឥស្សា ន សុបតិ តំ បរាភវតោ មុខំ។**

បុរសអ្នកមានវ័យចាស់ហួស ហើយទៅនាំយកស្ត្រីក្រមុំដែលមានថានៈក្រពុំ ដូចជាតិម្ពរុផលមកធ្វើជាភរិយា រមែងដេកមិនលក់ ព្រោះតែសេចក្ដីប្រច័ណ្ឌ

ទៅរកភរិយាក្មេងនោះ ហេតុនោះ ជាប្រធានរបស់បុគ្គលអ្នកមានសេចក្តីវិនាស។

១១_ឥត្ថឹ សោណ្ឌឹ វិកិរណឹ បុរិសំ វាបិ តាទិសំ ឥស្សរិយស្មឹ ឋបេតិ តំ បរាភវតោ មុខំ។

បុរសតាំងស្ត្រី អ្នកលេងស៊ីផឹកខ្ជះខ្ជាយ ឬក៏ស្ត្រីតាំងបុរសដូច្នោះ ក្នុងតំណែងជាធំ (ជាមេផ្ទះ) ហេតុនោះជាប្រធានរបស់បុគ្គលអ្នកមានសេចក្តីវិនាស។

១២_អប្បភោគោ មហាតណ្ហោ ខត្តិយេ ជាយតេ កុលេ សោ ច រជ្ជំ បត្ថយតិ តំ បរាភវតោ មុខំ។

នរជនឯណាកើតក្នុងត្រកូលក្សត្រ ជាអ្នកខ្សត់ខ្សោយភោគសម្បត្តិ តែមានសេចក្តីប្រាថ្នាធំ នរជននោះឯងចង់សោយរាជ្យជាស្តេច ហេតុនោះ ជាប្រធានរបស់បុគ្គលអ្នកមានសេចក្តីវិនាស។

ឯតេ បរាភវេ លោកេ បណ្ឌិតោ សមវេក្ខិយ អរិយទស្សនសម្បន្នោ សលោកំ ភជតេ សិវំ។

នរជនណាមួយជាអ្នកប្រាជ្ញ សម្បូរដោយប្រាជ្ញាជាគ្រឿងយល់ឃើញដ៏ប្រសើរ បានពិចារណាឃើញច្បាស់នូវហេតុទាំង ១២ ប្រការនេះ ថាជាហេតុនាំឱ្យវិនាសក្នុងលោក (ហើយបានវៀរចាកហេតុទាំងនោះចេញ) នរជននោះឯង តែងបានភពប្រសព្វជួបប្រទះនឹងលោកដែលជាទីក្សេមក្សាន្ត(ឥតមានឧបទ្រពឡើយ)។

**នរជនណាធ្វើទាន ទាននឹងជួយនរជននោះ**

# ពុទ្ធជយមង្គល

១-ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ

គ្រីមេខលំ ឧទិតឃោរសសេនមារំ

ទានាទិធម្មវិធិនា ជិតវា មុនិន្ទោ

តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទលោកាចារ្យ ផ្ចាញ់ក្រុងមារចិត្តមោហន្ធ

និមិត្តដៃ ១ ពាន់ កាន់សាស្ត្រាវុធនានា។

ជិះគ្រីមេខលជាតិ កោញ្ជនាទ ខ្ចរពសុធា

ព្រមដោយមារសេនា ពន្លឹកលន់កងស័ព្ទស៊ាន។

ដោយធម្ម- ពិធី ទានបារមី ជាប្រធាន

ក្រុងមារចាញ់ទ្រង់ញាណ ប្រណម្យកាយថ្វាយវន្ទា។

វីជយមង្គល ចូរមានដល់អ្នករាល់គ្នា

ដោយតេជៈជយា ព្រះឈ្នះមារ គ្រានោះហោង។

២_មារាតិរេកមភិយុជ្ឈិតសព្វរត្តឹ
ឃោរម្បនាឡវកមក្ខមថទ្ធយក្ខំ
ខន្តី សុទន្តវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិននាយកៈ ផ្ចាញ់អាឡវយក្ខឃោរឃៅ
រឹងរូសមិនតាំងនៅ ក្នុងខន្តី គុណសត្យា។
រហូតដល់រាត្រី ព្រះជិនស្រីទ្រង់ យុទ្ធនា
គ្រៃលែងក្រុងមារា ក្នុងបឋម សម្ពោធិ។
ដោយព្រះពិធីញាណ ទ្រង់ទូន្មាន ដោយខន្តី
ញុំាំងចិត្ត អសុរី ឱ្យបង់ ព្យសន៍ ចុះវន្ទា
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ព្រះឈ្នះអាឡវយក្ខហោង។

៣_នាឡាគិរឹ គជវរំ អតិមិត្តភូតំ

ទាវគ្គិចក្កមសនីវ សុទារុណន្តំ
មេត្តម្ពុសេកវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនជិនស្រី ផ្ចាញ់ដំរីឈ្មោះនាឡា
គិរី វរៈ គជា ដ៏ហានក្លាចុះព្រេងព្រេច។
សាហាវឆាវឆេះក្រៃ ដូចភ្លើងព្រៃឆេះកំទេច
មុតដូច ចក្រក្រុតពេជ្រ ខ្លាំងដូចកាំ អសនី។
ដោយព្រះពិធីស្រប់ ស្រោចទឹកអប់គឺបារមី
មេត្តាព្រះជិនស្រី ញាំងដំរី ឱ្យជ្រះថ្លា។
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ព្រះឈ្នះនាឡាគីរី។

៤_ឧក្ខិត្តខគ្គមតិហត្ថសុទារុណន្តំ
ធាវន្តិ យោជនបថង្គុលិមាលវន្តំ

ឥទ្ធីភិសង្ខតមនោ ជិតវា មុនិន្ទោ

តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនលោកត្រៃ មានព្រះទ័យធ្វើបាដិហារ្យ

ផ្ចាញ់ចោរអង្គុលិមាល៍ មានកម្រងគឺម្រាមដៃ

នៃមនុស្សដែលគាត់កាត់ មកដោតចាក់ជាមាល័យ

អង់អាចអំណាចក្រៃ ដ៏មានដៃស្ទាត់ប្រហារ។

កាន់ដាវ ងារគ្រឹ ដេញព្រះមុនីសាស្តាចារ្យ

ចម្ងាយផ្លូវកន្តារ កណ្តាលព្រៃបីយោជនា

វីជយមង្គល ចូរមានដល់អ្នករាល់គ្នា

ដោយតេជះជយា ព្រះឈ្នះអង្គុលិមាល៍។

៥-កត្វាន កដ្ឋមុទរំ ឥវ គព្ភិនីយា

ចិញ្ចាយ ទុដ្ឋវចនំ ជនកាយមជ្ឈេ

សន្តេន សោមវិធិនា ជិតវា មុនិន្ទោ

តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទមានព្រះភាគ ផ្ចាញ់ទ្រុស្តពាក្យនាងចិញ្ចា
អំពើធ្វើដូចជា ស្រីមានគភ៌ចាស់ចើសពោះ។
យកឈើធ្វើជាកូន ព័ទ្ធពោះខ្លួនពោលទ្រគោះ
ព្រះពុទ្ធឈ្នះកាលនោះ ដោយសមាចារពិធី។
រម្ងាប់ពាក្យចណ្ឌាល នាកណ្តាលជនប្រុសស្រី
ចិញ្ចា ចាញ់បារមី គឺសច្ចំ ពាក្យសត្យា
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ព្រះសាស្តាឈ្នះចិញ្ចា។

៦_សច្ចំ វិហាយមតិសច្ចកវាទកេតុំ
វាទាភិរោបិតមនំ អតិអន្ធភូតំ
បញ្ញាបទីបជលិតោ ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនអ្នកប្រាជ្ញ រុងរឿងស្វាចដោយបញ្ញា
ផ្ចាញ់សច្ចកៈ ជា និគ្រន្ថ ក្រៅពុទ្ធវិន័យ។
អធ្យាស្រ័យលះបង់ ពាក្យសត្យត្រង់តាមគាប់ចៃ
សរសើរខ្លួនឯងក្រៃ លើកកំពស់ដូចដងទង់។
បង្កើតម្បូរ ងងឹត ដោយពោលឥតពាក្យទៀងត្រង់
ព្រះទ្រង់កម្ចាត់បង់ ដោយប្រទីប គឺបញ្ញា។
វិជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ឈ្នះ សច្ចកៈ និគ្រន្ថ។

៧_នន្ទោបនន្ទភុជគំ វិពុធំ មហិទ្ធឹ
បុត្តេន ថេរភុជគេន ទមាបយន្តោ
ឥទ្ធូបទេសវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនទ្រង់ញាណ ញុំាងមោគ្គល្លានមានអំណាច

ឱ្យប្លែងជានាគរាជ ទៅទូន្មាន ព្យសន៍ ភុជង្គ។
ឈ្មោះ នន្ទោបនន្ទ ចិត្តមោហន្ធ រឿង ឫទ្ធិវង់
ទិដ្ឋិ កាចទ្រនង់ ទ្រង់ផ្ចាញ់ដោយពិធីឈាន។
គឺឱ្យ ឧបទេស ឫទ្ធិវិសេស ដល់មោគ្គល្លាន
ឫទ្ធិនាគអន្តរធាន ឱនចុះចាញ់ព្រះចេស្តា។
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ព្រះភគវាឈ្នះនាគហោង។

៨_ទុគ្គាហទិដ្ឋិភុជគេន សុទដ្ឋហត្ថំ
ព្រហ្មំ វិសុទ្ធិ ជុតិមិទ្ធិ ពកាភិធានំ
ញាណាគទេន វិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនគោតម ផ្ចាញ់មហាព្រហ្មឈ្មោះពកា
សំគាល់ថាអាត្មា រុងរឿងដោយគុណបរិសុទ្ធ។

ដៃកាន់អាសិរ្ពិស	គឺចិត្តទ្រឹស្ត ដ៏មោះមុត
កាន់ខុសផ្លូវសម្ពុទ្ធ	មិនលើកលាកលះបង់ប្រាណ។
ទ្រង់ឈ្នះដោយពិធី	ឱសថវិសេសសម្រាន្ត
ផ្សំត្រូវគាប់សន្តាន	គឺព្រះញាណប្រោសទេសនា។
វិជយមង្គល	ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា	ឈ្នះព្រហ្មាឥតមានហ្មង។

ឯតាបិ ពុទ្ធជយមង្គលអដ្ឋគាថា
យោ វាចនោ ទិនទិនេ សរតេ មតន្ទី
ហិត្វានេក វិវិធានិ ចុបទ្ទវានិ
មោក្ខំ សុខំ អធិកមេយ្យ នរោ សបញ្ញោ
យោ នរោ ជនឯណា កបបញ្ញាប្រាសក្តិខ្ជិល

ឧស្សាហ៍សាងទានសីល	ស្វត្ររំឮកព្រះធម៌ថ្ងៃ។
គាថាប្រាំបីបទ នេះកំណត់	ឈ្មោះពុទ្ធជ័យ

ខំសូត្រសព្វៗថ្ងៃ　　កើតមង្គល ជានិរន្តរ៍។
សោ នរោ វីជននោះ　　បានរំដោះរោគអាសន្ន
ឧបទ្រព អនេកលន់　　មានប្រការផ្សេងៗផង។
នឹងដល់ធម៌ក្សេមក្សាន្ត　　គឺនិព្វាន សុខកន្លង
លែងទុក្ខទាំងបួនកង　　ដោយពុទ្ធជយមង្គលនេះ។

# ជយបរិត្តគាថា

មហាការុណិកោ នាថោ ហិតាយ សព្វបាណិនំ
បូរេត្វា បារមី សព្វា　　បត្តោ សម្ពោធិមុត្តមំ។

ព្រះសម្មាសម្ពុទ្ធជាទីពឹងនៃសត្វលោក ទ្រង់ប្រកបដោយមហាករុណាព្រះអង្គបំពេញនូវបារមីទាំងឡាយទាំងពួងដើម្បីប្រយោជន៍ដល់សត្វទាំងអស់ហើយទ្រង់បាននូវសម្ពោធិញ្ញាណដ៏ឧត្តមហើយ។

ឯតេន សច្ចវជ្ជេន ហោតុ តេ ជយមង្គលំ

ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមជយមង្គលកើតមានដល់អ្នក។

ជយន្តោ ពោធិយា មូលេ សក្យានំ នន្ទិវឌ្ឍនោ
ឯវំ ត្វំ វិជយោ ហោហិ ជយស្សុ ជយមង្គលេ
អបរាជិតបល្លង្កេ សីសេ បថវិបោក្ខរេ
អភិសេកេ សព្វពុទ្ធានំ អគ្គប្បត្តោ បមោទតិ

ព្រះសម្មាសម្ពុទ្ធទ្រង់ញ៉ាំងសេចក្តីត្រេកអរនៃសក្យៈទាំងឡាយ ឱ្យចម្រើន ព្រះអង្គទ្រង់ឈ្នះមារហើយ បានដល់នូវភាពជាបុគ្គលប្រសើរបំផុត ទ្រង់រីករាយ (ចំពោះធម៌ដែលព្រះអង្គត្រាស់ដឹង) លើអបរាជិតបល្ល័ង្ក ជាជ័យមង្គលទៀបគល់ពោធិព្រឹក្សត្រង់ផ្ចិតផែនដី ដូចជាស្លឹកឈូក ជាទីអភិសេកនៃព្រះពុទ្ធគ្រប់ព្រះអង្គ (យ៉ាងណាមិញ) សូមឱ្យអ្នក

ជាបុគ្គលមានជ័យជំនះឈ្នះ (អស់សត្រូវ) យ៉ាងនោះឯង។

**សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ**
**សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ**

(ពេលណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ពេលនោះ) ឈ្មោះថា ជានក្ខត្តឫក្សល្អ ជាមង្គលល្អ ជាពេលភ្លឺស្វាងល្អ ជាពេលនៃអរុណរះល្អ ជាខណៈល្អ ជាយាមល្អ (ទានដែលបុគ្គលបានបូជាហើយ) ដល់ព្រហ្មចារិបុគ្គលទាំងឡាយ (ក្នុងពេលនោះ) ឈ្មោះថាជាគ្រឿងបូជាល្អ។

**បទក្ខិណំ កាយកម្មំ វាចាកម្មំ បទក្ខិណំ**
**បទក្ខិណំ មនោកម្មំ បណិធី តេ បទក្ខិណា**

(ក្នុងថ្ងៃនោះ) កាយកម្ម ក៏ឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន វចីកម្ម ក៏ឈ្មោះថា នាំឱ្យមានសេចក្តី

ចម្រើន មនោកម្ម ក៏ឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន សេចក្តីប្រាថ្នាទាំងឡាយរបស់អ្នកទាំងនោះ ក៏ឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន។

**បទក្ខិណានិ កត្វាន លភន្តត្ថេ បទក្ខិណេ**

បុគ្គលដែលបានធ្វើនូវកាយកម្ម វចីកម្ម មនោកម្ម គួរដល់សេចក្តីចម្រើន (យ៉ាងនេះ)ហើយ ក៏រមែងបាននូវប្រយោជន៍ដ៏ចម្រើនទាំងឡាយ។

| | | | |
|---|---|---|---|
| បើទីពឹងកាយ | រោគតាមឱ្យគិត | ងាកទៅពឹងចិត្ត | សុទ្ធតែកិលេស |
| វិលមកពឹងខន្ធ | បញ្ញាចាក់ស្រេះ | ចុះបើយ៉ាងនេះ | ពឹងអ្វីទៅខ្ញុំ។ |

# វិធីសមាទានឧបោសថសីល

លុះដល់ព្រឹកឡើង ជាថ្ងៃឧបោសថកាល ត្រូវសុំនិងរក្សានូវឧបោសថសីល គប្បីភ្ញាក់ពីព្រលឹម តែបើឃើញថានឹងសមាទាននូវឧបោថសីល ពីព្រលឹមនោះមិនទាន់ទេ ក៏គប្បីកំណត់នូវឧបោសថកាល គឺកាលជាទីរក្សានូវឧបោសថសីល ក្នុង ១ ថ្ងៃ ១ យប់នោះ ដោយបញ្ចេញវាចាអធិដ្ឋានថាៈ

អជ្ជ ឧបោសថោ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ

(ឧបាសកថា) ឧបោសថិកោ ⎫
 ⎬ ភវិស្សាមិ ថ្ងៃនេះជា
(ឧបាសិកាថា) ឧបោសថិកា ⎭

ថ្ងៃត្រូវរក្សានូវឧបោសថសីល អាត្មាអញនឹងជាអ្នករក្សា នូវឧបោសថសីល អស់ថ្ងៃនេះ និងយប់នេះ។

ម្នាក់ឯងថា អហំ ⎫
ឧកាស ⎬ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ
ពីរនាក់ថា មយំ ⎭

ម្នាក់ឯងថា មិ
អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចា អនុគ្គហំ កត្វា សីលំ
ពីរនាក់ថា ម

ម្នាក់ឯងថា មេ ទុតិ អហំ
ទេថ ភន្តេ យម្បិ ភន្តេ វិសុំ វិសុំ
ពីរនាក់ថា នោ តតិ មយំ

រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ

ម្នាក់ឯងថា មិ ម្នាក់ឯងថា មេ
យាចា អនុគ្គហំ កត្វា សីលំ ទេថ ភន្តេ
ពីរនាក់ថា ម ពីរនាក់ថា នោ

ម្នាក់ឯងថា ខ្ញុំព្រះករុណា
សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន
ពីរនាក់ថា ខ្ញុំព្រះករុណាទាំងឡាយ

សូមនូវឧបោសថសីល

ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍

ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗ គ្នា បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្ដីអនុគ្រោះ

ឱ្យនូវសីលដល់ { ម្នាក់ឯងថា ខ្ញុំព្រះករុណា / ពីរនាក់ថា ខ្ញុំព្រះករុណាទាំងឡាយ }

បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា (ខ្ញុំព្រះករុណាទាំងឡាយ) សូមនូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា ជាគំរប់ពីរដងផង ជាគំរប់បីដងផង បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្ដីអនុគ្រោះ ឱ្យសីលដល់ខ្ញុំព្រះករុណា (ខ្ញុំព្រះករុណាទាំងឡាយ)។

សូមសូត្រ នមោ ៣ ចប់ ហើយប្រែផង

# (ឧបោសថសីល)

បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ

អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ

ប្រែដូចក្នុងនិច្ចសីលដែរ

អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ

ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនា ជាហេតុវៀរចាកកិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម។

មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ

សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ។

ប្រែដូចក្នុងនិច្ចសីលដែរ

**វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនា ជាហេតុវៀរចាក កិរិយាបរិភោគនូវភោជនាហារ ក្នុងកាលខុស។

**នច្ចគីតវាទិតវិសូកទស្សន- មាលាគន្ធវិលេបន- ធារណមណ្ឌនវិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខា-បទ គឺចេតនាជាហេតុវៀរចាកកិរិយារាំ និងច្រៀង និងប្រគំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ និងកិរិយាទ្រទ្រង់ និងប្រដាប់តាក់តែងស្អិតស្អាងរាងកាយដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ។

**ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ

គឺចេតនា ជាហេតុវៀចាកទីសេនាសនៈ ដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ។

**អ្នកសមាទាន សូត្រកំណត់ឧបោសថកាលថា៖**

ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីល ដ៏ប្រកបព្រមដោយអង្គ ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់បញ្ញត្តទុកហើយនេះ ដើម្បីនឹងរក្សាឱ្យបរិបូណ៌ប្រពៃ អស់កាលកំណត់ថ្ងៃនេះ និងយប់នេះ សូមកុសលចូលជាឧបនិស្ស័យ ធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វានព្វដ៏អនាគតកាល ទៅឯមុខនោះហោង។

(បន្ទាប់មកចាំស្ដាប់លោកសំដែងអំពីអានិសង្សនៃសីល)

# អភិណ្ហប្បច្ចវេក្ខណសូត្រ

ហន្ទ មយំ អភិណ្ហប្បច្ចវេក្ខណំ ភណាមសេ

ជរា ធម្មោម្ហិ យើងមានសេចក្តីចាស់ជរាជាធម្មតា។

ជរំ អនតីតោ យើងមិនកន្លងរំលងសេចក្តីចាស់ជរាទៅបាន។

ព្យាធិ ធម្មោម្ហិ យើងមានសេចក្តីឈឺថ្កាត់ជាធម្មតា។

ព្យាធឹ អនតីតោ យើងមិនកន្លងរំលងសេចក្តីឈឺថ្កាត់ទៅបាន។

មរណធម្មោម្ហិ យើងមានសេចក្តីស្លាប់ ជាធម្មតា ។

មរណំ អនតីតោ យើងមិនកន្លងរំលងសេចក្តីស្លាប់ទៅបាន។

សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ យើងគង់មានសេចក្តីព្រាត់ប្រាសចាកចោល របស់ជាទីស្រឡាញ់ពេញចិត្តគ្រប់យ៉ាងទាំងអស់។

អហំ វីអាត្មាអញ កម្មស្សកោ មានកម្មជារបស់

ខ្លួន កម្មទាយាទោ ជាអ្នកទទួលផលរបស់កម្ម។ កម្ម-យោនី ជាអ្នកមានកម្មនាំមកកើត។ កម្មពន្ធុ ជាអ្នកមានកម្មជាផៅពង្ស។ កម្មប្បដិសរណោ ជាអ្នកមានកម្មជាទីពឹងទីអាស្រ័យ។ យំ កម្មំ ករិស្សាមិ យើងបានធ្វើកម្មអ្វីទុក។ កល្យាណំ វា បាបកំ វា ជាបុណ្យឬជាបាប។ តស្ស ទាយាទោ ភវិស្សាមិ យើងត្រូវទទួលផលរបស់កម្មនោះ។ អភិណ្ហំ បច្ចវេក្ខិតព្វំ គប្បីពិចារណាឱ្យឃើញរឿយៗ ដូច្នេះ។

អចិរំ វត យំ កាយោ ឱកាយយើងអើយ កើតមកហើយមិនយូរមែនពិត។ បឋវី អធិសេស្សតិ នឹងដេកសង្កត់លើផែនដី ។ ឆុទ្ធោ អបេតវិញ្ញាណោ មានវិញ្ញាណក្ខន្ធប្រាសចេញហើយ ជារបស់សូន្យទទេ។

និវត្តំវ កលិង្គរំ ឧបមាដូចជាអង្កត់អុស ពុំមាន ប្រយោជន៍មែនពិត។

អនិច្ចា វត សង្ខារា ឱសង្ខារធម៌ទាំងឡាយ អើយ កើតមកហើយមិនទៀងមែនពិត។ ឧប្បាទ-វយធម្មិនោ មានសភាពកើតឡើងហើយ មានសេចក្តី សាបសូន្យទៅជាធម្មតា។ ឧប្បជ្ជិត្វា និរុជ្ឈន្តិ បង្កើត ឡើងហើយ មានសេចក្តីរលត់ទៅជាធម្មតា។ តេសំ វូបសមោ សុខោ ព្រះនិព្វានជាទីរលត់ភ្លើងទុក្ខ ភ្លើង កិលេសជាបរមសុខយ៉ាងក្រៃពេក។

នាមរូបំ អនិច្ចំ នាម និងរូបនៃសត្វទាំងឡាយ ដែលកើតមកហើយក្នុងសង្សារវដ្តនេះ មិនទៀងទាត់ ឋិតថេរប្រែប្រួលវិប្បរិតទៅផ្សេងៗ។ និច្ចំ វត និព្វានំ

មានតែព្រះនិព្វាន ទើបបានឈ្មោះថាទៀងប្រាកដមែន។ នាមរូបំ ទុក្ខំ នាម និងរូបនៃសត្វទាំងឡាយ ដែលកើតមកហើយក្នុងសង្សារវដ្តនេះ រមែងសោយទុក្ខជាធម្មតា។ សុខំ វត និព្វានំ មានតែព្រះនិព្វាន ទើបបានឈ្មោះថា សុខប្រាកដមែន។ នាមរូបំ អនត្តា នាម និងរូបនៃសត្វទាំងឡាយ ដែលកើតមកហើយក្នុងសង្សារវដ្តនេះ មិនមែនជារបស់អាត្មា និងរកខ្លឹមសារគ្មាន។ សារំ វត និព្វានំ មានតែព្រះនិព្វាន ទើបបានឈ្មោះថា មានខ្លឹមសារប្រាកដមែន។ អធុវំ ខោ មេ ជីវិតំ ជីវិតនៃយើងនេះមិនទៀងពិត ច្រើនតែវិប្បរិតទៅផ្សេងៗ។ ធុវំ មរណំ ឯកំសិកំ សេចក្តីស្លាប់របស់យើងទៀង មិនឃ្លៀងឃ្លាត។ អវស្សំ មយា

មរិតព្វំ យើងតែងតែនឹងស្លាប់ដោយពិត។ មរណ-បរិយោសានំ មេ ជីវិតំ ជីវិតនៃយើងនេះ តែងមានសេចក្តីស្លាប់ជាទីបំផុត។ មរណបដិពទ្ធំ មេ ជីវិតំ ជីវិតនៃយើងនេះជាប់ជំពាក់ទៅដោយសេចក្តីស្លាប់។

# ឧសជាតិ

១-តេមិយោ ពោធិសត្តោ នាម ភគវា ចិត្តំ វត្តកំ អារម្មណំ ត្វំបិ ពុទ្ធោ មេ ភវិស្សតិ កុសលធម្មោ មេ សម្មាសម្ពុទ្ធោ ឥតិបិសោ ភគវា

នេក្ខម្ម បារមី

នេក្ខម្ម ឧបបារមី

នេក្ខម្ម បរមត្ថបារមី សម្បន្នោ សោ ភគវា

**២_មហាជនកោ**
- **វីរិយ** បារមី
- **វីរិយ** ឧបបារមី
- **វីរិយ** បរមត្ថបារមី សម្បន្នោ សោ ភគវា

**៣_សុវណ្ណសាមោ**
- **មេត្តា** បារមី
- **មេត្តា** ឧបបារមី
- **មេត្តា** បរមត្ថបារមី សម្បន្នោ សោ ភគវា

**៤_និម្មរាជា**
- **អធិដ្ឋាន** បារមី
- **អធិដ្ឋាន** ឧបបារមី
- **អធិដ្ឋាន** បរមត្ថបារមី សម្បន្នោ សោ ភគវា

**៥_មហោសថោ**
- **បញ្ញា** បារមី
- **បញ្ញា** ឧបបារមី
- **បញ្ញា** បរមត្ថបារមី សម្បន្នោ សោ ភគវា

៦_ភូរិទត្តោ
- សីល បារមី
- សីល ឧបបារមី
- សីល បរមត្ថបារមី សម្បន្នោ សោ ភគវា

៧_ចន្ទកុមារោ
- ខន្តិ បារមី
- ខន្តិ ឧបបារមី
- ខន្តិ បរមត្ថបារមី សម្បន្នោ សោ ភគវា

៨_ព្រហ្មនារទោ
- ឧបេក្ខា បារមី
- ឧបេក្ខា ឧបបារមី
- ឧបេក្ខាបរមត្ថបារមី សម្បន្នោ សោ ភគវា

៩_វិធូរោ
- សច្ចៈ បារមី
- សច្ចៈ ឧបបារមី
- សច្ចៈ បរមត្ថបារមី សម្បន្នោ សោ ភគវា

១០_វេស្សន្តរោ { ទាន បារមី
ទាន ឧបបារមី
ទាន បរមត្ថបារមី សម្បន្នោ សោ ភគវា }

សិទ្ធត្ថោ { ទស បារមី
ទស ឧបបារមី
ទស បរមត្ថបារមី សម្បន្នោ សោ ភគវា }

សមត្តឹស បរមត្ថបារមី សម្បន្នោ សោ ភគវា ។

# សុភមង្គលគាថា

ហោតុ សព្វំ សុមង្គលំ សុមង្គល គឺសេចក្ដីចម្រើនដ៏ល្អគ្រប់យ៉ាងចូរមានដល់ខ្ញុំ រក្ខន្តុ សព្វទេវតា ទេវតាទាំងពួងទាំងឡាយ ចូររក្សានូវខ្ញុំ សព្វពុទ្ធានុ-ភាវេន ដោយអានុភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ សព្វ-

ធម្មានុភាវេន ដោយអានុភាពនៃព្រះធម៌ទាំងពួង សព្វ-
សង្ឃានុភាវេន ដោយអានុភាពនៃព្រះសង្ឃទាំងពួង
សោត្ថិ ហោតុ និរន្តរំ សូមសិរីសួស្តី ចូរមានដល់ខ្ញុំ
ឱ្យបានគ្រប់ពេល កុំបីមានចន្លោះឡើយ។

ឥទំ វត នោ បុញ្ញំ អាសវក្ខយាវហំ ហោតុ
អនាគតេ កាលេ វីបុណ្យនៃយើងខ្ញុំទាំងឡាយនេះឯង
សូមជាបច្ច័យឱ្យបានសម្រេចនូវព្រះនិព្វាន ឮដ៏អនាគត-
កាលទៅឯមុខនោះហោង។

ឥទំ វត នោ ទានំ អាសវក្ខយាវហំ ហោតុ
អនាគតេ កាលេ វីទាននៃយើងខ្ញុំទាំងឡាយនេះឯង
សូមជាបច្ច័យឱ្យបានសម្រេចនូវព្រះនិព្វាន ឮដ៏អនាគត-
កាល ទៅឯមុខនោះហោង។

ឥទំ វត នោ សីលំ អាសវក្ខយាវហំ ហោតុ អនាគតេ កាលេ វីសីលនៃយើងខ្ញុំទាំងឡាយនេះឯង សូមជាបច្ច័យឱ្យបានសម្រេចនូវព្រះនិព្វាន ព្វដ៏អនាគត-កាល ទៅឯមុខនោះហោង។

# បត្ថិធានគាថា

ឥមិនា បុញ្ញកម្មេន ដោយបុញ្ញកម្មនេះ ឧប-ជ្ឈាយា គុណុត្តរា ឧបជ្ឈាយ៍ទាំងឡាយមានគុណដ៏ខ្ពង់ខ្ពស់ក្តី អាចរិយូបការា ច អាចារ្យទាំងឡាយមានឧបការក្តី មាតាបិតា បិយា មមំ មាតា និងបិតាជាទីស្រឡាញ់នៃខ្ញុំក្តី សុរិយោ ចន្ទិមា រាជា ព្រះអាទិត្យ ព្រះចន្ទ និងព្រះរាជាក្តី គុណវន្តា នរាបិ ច

មួយវិញទៀត ជនទាំងឡាយដែលជាអ្នកមានគុណក្តី ព្រហ្មា មារា ច ឥន្ទ្រា ច ពួកព្រហ្មក្តី មារក្តី ព្រះឥន្ទ្រទាំងឡាយក្តី លោកបាលា ច ទេវតា ទេវតាទាំងឡាយ ជាអ្នករក្សានូវលោកក្តី យមោ មិត្តា មនុស្សា ច យមរាជក្តី ពួកមនុស្សជាទីរាប់អានគ្នាក្តី មជ្ឈត្តា វេរិកាបិ ច មួយវិញទៀត សត្វទាំងឡាយដែលមានចិត្តជាឧបេក្ខាក្តី មានពៀរនឹងគ្នាក្តី សព្វេ សត្តា សុខី ហោន្តុ សព្វសត្វទាំងឡាយចូរឱ្យបាននូវសេចក្តីសុខ បុញ្ញានិ បកតានិ មេ បុណ្យទាំងឡាយដែលខ្ញុំបានធ្វើហើយ សុខញ្ច តិវិធំ ទេន្តុ សូមឱ្យបាននូវសេចក្តីសុខទាំង ៣ ប្រការ (គឺសុខក្នុងមនុស្ស ១ ទេវតា ១ និងព្រះនិព្វាន ១) ខិប្បំ បាបេថ វោមតំ

អ្នកទាំងឡាយ ចូរដល់នូវព្រះនិព្វាន ឈ្មោះអមតៈ ដោយឆាប់រួសរាន់ទាន់ចិត្ត។

# បត្ថនាគាថា

ឥមិនា បុញ្ញកម្មេន ដោយបុញ្ញកម្មនេះផង ឥមិនា ឧទ្ទិសេន ច ដោយពាក្យឧទ្ទិសនេះផង ខិប្បាហំ សុលភេ ចេវ តណ្ហុប្បាទានឆេទនំ ខ្ញុំគប្បីបានដោយងាយនូវការកាត់ផ្តាច់តណ្ហា និងឧបាទានដោយឆាប់រួសរាន់ យេ សន្តានេ ហីនា ធម្មា ធម៌ទាំងឡាយណាដែលថោកទាប មានក្នុងសន្តាន (នៃខ្ញុំ) យាវ និព្វានតោ មមំ នស្សន្តុ សព្វទាយេវ ធម៌ថោកទាបទាំងនោះ ចូរវិនាសទៅ (ចាកសន្តាន) នៃខ្ញុំសព្វៗ កាល ដរាបដល់ព្រះនិព្វាន យត្ថ ជាតោ

ភវាភវេ ខ្ញុំកើតហើយក្នុងភពតូច និងភពធំណា១ ឧជុចិត្តោ សតិប្បញ្ញោ សល្លេខោ វីរិយោម្ហិ វា សូមឱ្យជាអ្នកមានចិត្តត្រង់មានស្មារតី និងប្រាជ្ញា ទាំងសូមឱ្យមានចិត្តផ្លូវផង់ និងសេចក្ដីព្យាយាមផង (ក្នុងភពនោះ១) មារា លភន្តុ នោកាសំ កាតុញ្ច វីរិយេសុ មេ មារទាំងឡាយចូរកុំបាននូវឱកាស ដើម្បីធ្វើ (នូវសេចក្ដីអន្តរាយ) ក្នុងព្យាយាមទាំងឡាយនៃខ្ញុំ ពុទ្ធោ ទីបវរោ នាថោ ព្រះពុទ្ធដូចជាប្រទីប ដ៏ប្រសើរ ព្រះអង្គជាទីពឹង (របស់ខ្ញុំ)។ ធម្មោ នាថោ វរុត្តមោ ព្រះធម៌ដ៏ឧត្តមបវរជាទីពឹង (របស់ខ្ញុំ) នាថោ បច្ចេកពុទ្ធោ ច ព្រះបច្ចេកពុទ្ធក៏ជាទីពឹងរបស់ខ្ញុំ សង្ឃោ នាថោត្តរោ មមំ ព្រះសង្ឃជាទីពឹងដ៏ប្រសើរ

របស់ខ្ញុំ តែសោត្ថមានុភាវេន ដោយឧត្តមានុភាព នៃព្រះពុទ្ធ ព្រះធម៌ ព្រះបច្ចេកពុទ្ធ និងព្រះសង្ឃ ទាំងឡាយនោះ មារោកាសំ លភន្តុ មា មារចូរកុំ បាននូវឱកាសឡើយ។

# ខមាបនគាថា

យេ កេចិ ខុទ្ទកា បាណា មហន្តាបិ មយា ហតា សត្វទាំងឡាយណាមួយ ជាសត្វតូចក្តី ធំក្តី ដែលខ្ញុំសម្លាប់ហើយ យេ បាណេកេ បមាទេន កាយវាចាមនេហិ វា ទោះសត្វទាំងឡាយណាពួក ខ្លះ (ដែលខ្ញុំបៀតបៀនហើយ) ដោយកាយវាចាចិត្ត ព្រោះសេចក្តីប្រមាទ បុញ្ញំ មេ អនុមោទន្តុ (សត្វ ទាំងនោះ) ចូរអនុមោទនាត្រេកអរចំពោះបុណ្យរបស់ខ្ញុំ

គណ្ហន្តុ ផលមុត្តមំ ចូរទទួលយកនូវផលដ៏ឧត្តមចុះ វេរិនោ ចេ បមុញ្ចន្តុ បើ (សត្វទាំងឡាយណា) មានពៀរនឹងគ្នា (សត្វទាំងឡាយ)នោះ ចូររួចរដោះចាកពៀរនោះទៅ សព្វទោសំ ខមន្តុ មេ សូមសត្វទាំងឡាយ អត់នូវទោសទាំងពួងដល់ខ្ញុំ។

## បត្ថិនានគាថា

យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម អំពើជាកុសលឯណាមួយ ដែលខ្ញុំគប្បីធ្វើ កាយេន វាចា មនសា ដោយទ្វារទាំងបី គឺកាយ វាចា ចិត្ត តិទសេ សុគតំ កតំ អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំឱ្យទៅកើតក្នុងស្ថានត្រៃត្រិង្សសួគ៌បាន យេ សត្តា សញ្ញិនោ

អត្ថិ សត្វទាំងឡាយឯណា គឺមនុស្ស ឬទេវតា ឬព្រហ្ម ដែលជាសត្វមានសញ្ញាក្តី យេ ច សត្តា អសញ្ញិនោ សត្វទាំងឡាយឯណា ជាអសញ្ញីសត្វ គឺសត្វដែលឥត សញ្ញាក្តី កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ សត្វទាំងឡាយទាំងអស់នោះចូរឱ្យបាននូវចំណែក ផលនៃបុណ្យហើយចូរសោយនូវផលនៃបុណ្យ ដែល ខ្ញុំបានធ្វើហើយ បានឧទ្ទិសផ្សាយឱ្យទៅនេះចុះ យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា បុណ្យដែលខ្ញុំ បានធ្វើហើយនោះ បើសត្វទាំងឡាយឯណា បានដឹង ច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឱ្យបានសោយ នូវផលនៃបុណ្យដែលខ្ញុំបានឧទ្ទិសឱ្យទៅនោះចុះ យេ ច តត្ថ ន ជានន្តិ ម្យ៉ាងទៀត បណ្តាអស់សត្វទាំង នោះ បើសត្វទាំងឡាយឯណា មិនបានដឹងនូវបុណ្យ

ដែលខ្ញុំបានធ្វើហើយនោះ ទេវា គន្ធា និវេទយុំ សូមទេវតាទាំងឡាយ អញ្ជើញទៅឱ្យដំណឹងដល់សត្វទាំងឡាយនោះឱ្យបានដឹងផងថា ជនឯណោះគេបានបានធ្វើបុណ្យហើយ គេឧទ្ទិសផ្សាយផលបុណ្យនោះមកដល់អ្នកទាំងឡាយៗ ចូរអនុមោទនាត្រេកអរនឹងជីវន្តាហារហេតុកា សត្វទាំងឡាយឯណាក្នុងលោកទាំងអស់ ដែលអាស្រ័យនូវអាហារ ហើយរស់នៅ មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ សត្វទាំងឡាយទាំងអស់នោះចូរឱ្យបាននូវភោជនជាទីគាប់ចិត្ត ដែលសម្រេចដោយបុញ្ញឫទ្ធិ តាមចិត្តខ្ញុំដែលឧទ្ទិសផ្សាយទៅឱ្យនេះចុះ។

# អនុមោទនារក្ខាយាចនគាថា

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ សាសនំ ទេវតាទាំងឡាយ ស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយមានឥទ្ធានុភាពច្រើនក្តី សូមអនុមោ-ទនានូវបុណ្យនៃយើងទាំងឡាយ សូមរក្សានូវព្រះពុទ្ធ-សាសនា (ឱ្យបានចម្រើន) អស់កាលជាយូរអង្វែងទៅ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ រាជានោ ទេវតាទាំងឡាយស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយមានឥទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវបុណ្យនៃយើងទាំងឡាយ សូមរក្សានូវព្រះមហាក្សត្រ (ឱ្យបានចម្រើន) អស់កាលជាយូរអង្វែងទៅ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ អាចារិយោ ទេវតាទាំងឡាយស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយមានឥទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវបុណ្យនៃយើងទាំងឡាយ សូមរក្សានូវលោកគ្រូអាចារ្យទាំងឡាយ (ឱ្យបានចម្រើន)អស់កាលជាយូរអង្វែងទៅ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ មាតាបិតរោ ទេវតាទាំងឡាយស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយមានឥទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវបុណ្យនៃយើងទាំងឡាយ សូមរក្សានូវ

មាតាបិតានៃយើងទាំងឡាយ (ឱ្យបានចម្រើន) អស់កាលជាយូរអង្វែងទៅ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ ញាតយោ

ទេវតាទាំងឡាយស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយមានឥទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវបុណ្យនៃយើងទាំងឡាយ សូមរក្សានូវញាតិទាំងឡាយ (ឱ្យបានចម្រើន) អស់កាលជាយូរអង្វែងទៅ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ បាណិនោ

ទេវតាទាំងឡាយស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយ មានឥទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវបុណ្យនៃយើងទាំងឡាយ សូមរក្សានូវសត្វទាំងឡាយ

(ឱ្យបានចម្រើន) អស់កាលជាយូរអង្វែងទៅ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ នោ សទា ទេវតាទាំងឡាយស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយមានឥទ្ធានុភាពច្រើនក្តី សូមអនុមោទនានូវបុណ្យនៃយើងទាំងឡាយ សូមរក្សានូវយើងទាំងឡាយ (ឱ្យបានចម្រើន)អស់កាលជាយូរអង្វែងទៅ។

## បត្ថិនានគាថា

យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ ទេវតាទាំងឡាយឯណា មានប្រក្រតីនៅក្នុងទីវត្តជាទីនៅនៃសង្ឃឰដ៏ខឿនព្រះស្តូប ឰដ៏ខឿនព្រះពោធិព្រឹក្ស ក្នុងទីនោះៗ តា

ធម្មទានេន ភន្តេ បូជិតា ទេវតាទាំងឡាយនោះ ជាបុគ្គល គឺយើងទាំងឡាយបូជាហើយ ដោយធម្មទាន សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ ចូរធ្វើនូវសួស្តី ក្នុងមណ្ឌលនៃវត្តជាទីនៅនៃសង្ឃនេះ ថេរា ច មជ្ឈិមា នវកា ច ភិក្ខវោ ភិក្ខុទាំងឡាយជាថេរៈក្តី ជាកណ្តាលក្តី ទើបនឹងបួសថ្មីក្តី សារាមិកា ទានបតី ឧបាសកា ឧបាសក និងឧបាសិកាទាំងឡាយដែលជាម្ចាស់នៃទាន ព្រមទាំងអារាមិកជនគឺញោមវត្តក្តី គាមា ច ទេសា និគមា ច ឥស្សរា ជនទាំងឡាយដែលជាអ្នកស្រុកក្តី ជាអ្នកប្រទេសក្តី ជាអ្នកនិគមក្តី ដែលជាឥស្សរៈជាធំក្តី សប្បាណភូតា សុខិតា ភវន្តុ តេ សត្វទាំងឡាយនោះៗ ចូរឱ្យបាននូវសេចក្តីសុខ ជលាពុជា យេបិ

ច អណ្ឌសម្ភវា សំសេទជាតា អថវោ បបាតិកា មួយវិញទៀត សត្វទាំងឡាយឯណា ដែលជាជលាពុជៈកំណើតក្តី ដែលជាអណ្ឌជៈកំណើតក្តី ដែលជាសំសេទជៈកំណើតក្តី ដែលជាឱបបាតិកៈកំណើតក្តី និយ្យានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ សត្វទាំងឡាយទាំងអស់នោះ កាលបើបានអាស្រ័យនូវធម៌ដ៏ប្រសើរ ជានិយ្យានិកធម៌ហើយ ចូរធ្វើនូវធម៌ ជាគ្រឿងអស់ទៅនៃទុក្ខចុះ ឋាតុ ចិរំ សតំ ធម្មោ សូមឱ្យធម៌របស់សប្បុរសទាំងឡាយ ឋិតនៅអស់កាលយូរអង្វែងទៅ ធម្មធរា ច បុគ្គលា បុគ្គលអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ (ចូរឋិតនៅអស់កាលយូរអង្វែងទៅ) សង្ឃោ ហោតុ សមគ្គោវ សូមព្រះសង្ឃព្រមព្រៀងគ្នា អត្ថាយ ច ហិតាយ ច ដើម្បីសេចក្តីចម្រើនផង

ដើម្បីសេចក្តីសម្រេចផលប្រយោជន៍ផង អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ សូមព្រះសទ្ធម្មរក្សា នូវយើងទាំងឡាយ សូមរក្សានូវអ្នកដែលប្រព្រឹត្តធម៌ទាំងឡាយទាំងអស់ផង វុឌ្ឍឹ សម្បាបុណេយ្យាម ធម្មារិយប្បវេទិតេ សូមឱ្យយើងទាំងឡាយបានដល់នូវសេចក្តីចម្រើន ក្នុងធម៌ដែលព្រះអរិយៈទាំងឡាយលោកសំដែងហើយ។

## ផ្សាយមេត្តាចំពោះទិសទាំង ១០

សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ)ក្នុងទិសបូព៌ា សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ។

សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា

សុខី ហោន្តុ សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសអាគ្នេយ៍ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ។

សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ)ក្នុងទិសទក្សិណ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ។

សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសនិរតី សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ។

សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសបច្ចិម សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ។

សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា

សុខី ហោន្តុ សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសពាយ័ព្យ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ។

សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសឧត្តរ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ។

សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសឦសាន សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ។

សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសខាងក្រោម សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ។

សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី

ហោន្តុ សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសខាងលើ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ។

សព្វេ សត្តា អវេរា ហោន្តុ សូមឱ្យសត្វទាំង-ឡាយទាំងពួង កុំមានពៀរនឹងគ្នា។ សុខិតា ហោន្តុ សូមឱ្យបាននូវសេចក្តីសុខ និទ្ទុក្ខា ហោន្តុ សូមកុំឱ្យមានទុក្ខ អព្យាបជ្ឈា ហោន្តុ សូមកុំឱ្យបៀតបៀនដល់គ្នានឹងគ្នា អនីឃា ហោន្តុ សូមកុំឱ្យមានសេចក្តីព្រួយលំបាក ទីឃាយុកា ហោន្តុ សូមឱ្យមានអាយុវែង អរោគា ហោន្តុ សូមកុំឱ្យមានរោគ សម្បត្តិហិ សមិជ្ឈន្តុ សូមឱ្យសម្រេច ដោយសម្បត្តិគ្រប់យ៉ាង សុខី អត្តានំ បរិហរន្តុ សូមឱ្យរក្សានូវខ្លួនជាសុខស្រួលចុះ ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច

និព្ភយា សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ មួយវិញទៀត សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវសេចក្តីទុក្ខ សូមឱ្យជាសត្វបាត់សេចក្តីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយនូវសេចក្តីសោក សូមឱ្យជាសត្វបាត់សេចក្តីសោកទៅ។

សុខោ ពុទ្ធានមុប្បាទោ កិរិយាកើតឡើង នៃព្រះពុទ្ធទាំងឡាយជាទីនាំមកនូវសេចក្តីសុខ។ សុខា សទ្ធម្មទេសនា កិរិយាសំដែងឡើងនូវព្រះសទ្ធម្ម គឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ជាទីនាំមកនូវសេចក្តីសុខ។ សុខោ សង្ឃស្ស សាមគ្គី សេចក្តីព្រមព្រៀងគ្នានៃព្រះសង្ឃ ជាទីនាំមកនូវសេចក្តីសុខ។

សមគ្គានំ តបោ សុខោ តបៈគុណនៃព្រះសង្ឃទាំងឡាយ អ្នកព្រមព្រៀងគ្នា ជាទីនាំមកនូវសេចក្តីសុខ។ ទិវា តបតិ អាទិច្ចោ ព្រះអាទិត្យរុងរឿងបានតែក្នុងវេលាថ្ងៃ។ រត្តិមា ភាតី ចន្ទិមា ព្រះចន្ទរុងរឿងបានតែក្នុងវេលាយប់។ សន្នទ្ធោ ខត្តិយោ តបតិ ព្រះមហាក្សត្រ លុះតែទ្រង់គ្រឿងប្រដាប់ សម្រាប់រាជ្យទើបរុងរឿងបាន។ ឈាយ តបតិ ព្រាហ្មណោ ព្រាហ្មណ៍លុះតែចម្រើននូវឈាន ទើបរុងរឿងបាន។ អថ សព្វមហោរត្តឹ ពុទ្ធោ តបតិ តេជសា ឯព្រះបរមគ្រូ ព្រះអង្គរុងរឿងដោយតេជៈទាំងថ្ងៃ ទាំងយប់។ ឯតេន សច្ចវជ្ជេន សុវត្ថិ ហោន្តុ សព្វទា សេចក្តីសុខសួស្តី សូមកើតមានក្នុងកាលទាំងពួង ដោយកិរិយាពោលពាក្យសច្ចៈនេះ។

# រំលឹកព្រះគុណកែវទាំង ៣

ភន្តេ ភគវា សុចិរំ បរិនិព្វុតោ ព្រះមានបុណ្យជាម្ចាស់ដ៏ចម្រើន ព្រះអង្គទ្រង់យាងចូលបរិនិព្វានជាយូរអង្វែងហើយ ព្រះគុណអើយ យើងខ្ញុំសូមតាំងសត្យារំលឹកដល់ព្រះគុណកែវទាំង ៣ ថាៈ

ពុទ្ធោ មេ នាថោ ព្រះពុទ្ធជាម្ចាស់ជាទីពឹងនៃខ្ញុំ។

ធម្មោ មេ នាថោ ព្រះធម៌ជាម្ចាស់ជាទីពឹងនៃខ្ញុំ។

សង្ឃោ មេ នាថោ ព្រះសង្ឃជាម្ចាស់ជាទីពឹងនៃខ្ញុំ។ ហើយយើងខ្ញុំ សូមឱនកាយវាចាចិត្ត ក្រាបប្រណិបត្តិថ្វាយបង្គំ។

# តេជះខ្ញុំសាង

តេជះខ្ញុំសាង សំអិតសំអាង ឱនកាយវាចា
សុំសុខសោភាព រួចពីទុក្ខា ឆ្លងដល់ត្រើយមហា
ពោលគឺនិព្វាន។

គ្រប់ជាន់គ្រប់ជាតិ កុំឱ្យខ្ញុំឃ្លាត ពីសីល និងទាន
គំនិតខ្ញុំកើត កំណើតខ្ញុំមាន មគ្គផលជាស្ពាន
ដល់ស្ថានថ្លៃថ្លា។

សូមជូនមគ្គផល ចំពោះទៅដល់ មាតាបិតា
គុណគ្រូឧប- ជ្ឈាយាចារ្យ គុណញាតិកា
ប្រាំពីរសន្តាន។

ជីដូនជីតា រស់នៅក្តីណា លោកម្ចាស់ចែកឋាន
ខ្ញុំជូនមគ្គផល កុសលថ្កើងថ្កាន សូមសុខក្សេមក្សាន្ត
ដល់ស្ថានផុតទុក្ខ។

ខ្ញុំសូមប្រាថ្នា សច្ចះវាចា តទៅខាងមុខ
សូមមានបញ្ញា ភ្លឺថ្លាបានសុខ សូមឆ្លងផុតទុក្ខ

ដល់ព្រះនិព្វាន។

ខ្ញុំសូមសច្ចា ប្រាថ្នាតាំង មានប្រាជ្ញាខ្លាំង
មោះមុតថ្លា សម្រេចនិព្វាន ក្នុងសាសនា
នៃព្រះសិរិអារ្យ ខាងមុខហោង។

ខ្ញុំសូមប្រាថ្នា កើតជាតិណាៗ សូមជួបព្រះពុទ្ធ
សូមមានបញ្ញា ដូចព្រះសារីបុត្រ ចាក់ឆ្លុះមោះមុត
ដូចព្រះនាគសេន។

សូមឱ្យអង់អាច មានឫទ្ធិអំណាច ដូចព្រះមោគ្គល្លាន
ត្រង់ពាក្យមិនចេះ និងពាក្យថាគ្មាន កុំបីកើតមាន
ដល់ខ្ញុំឡើយណា។

សូមបានសម្រេច ឱ្យបានកាត់ផ្តាច់ វាលវដ្តសង្សារ
សូមឱ្យជ្រាបច្បាស់ ព្រះធម៌ពិស្តារ ឆ្លងផុតសង្សារ
ដល់និព្វានហោង។

សាសនាព្រះសម្ពុទ្ធ ជាចំហុតត្រៃលោកា
ចូលផុតអស់វស្សា ជាគម្រប់គ្រប់ ៥០០០

បពិត្រព្រះភគវា ខ្ញុំសទ្ធាសូមថ្វាយខ្លួន
ទីពឹងឱ្យមាំមួន មិនកន្លះទៅខាងណា
ដើម្បីនឹងចម្រើន ឱ្យបានច្រើននូវផលា
កម្មដ្ឋានវិបស្សនា សូមមេត្តាប្រោសខ្ញុំផង។

# សិក្ខាបទ ៨

ទី ១_សីលបាណា យើងរាល់គ្នាត្រូវចាំស្ទាត់ វៀរចាកសំលាប់សត្វ ដោយខ្លួនឯង ឬប្រើគេ។

ទី ២_សីលអទិន្នា ទ្រង់ហាមថា កុំងាកវេរ វាំពៃលួចទ្រព្យគេ ដោយនូវកាយ ឬវាចា។

ទី ៣_សីលកាមេ អស់យើងគេរាល់កាយា កុំត្រេកទៅប្រាថ្នា លួចកូនប្ដីប្រពន្ធគេ។

ទី ៤_សីលមុសា ទ្រង់ហាមថា កុំវៀចវេរ កុហក

បញ្ឆោតគេ ឱ្យខូចខាតទ្រព្យសម្បត្តិ។

ទី៥_សីលសុរា ទ្រង់ទេសនាហាមបញ្ញត្ត មិនឱ្យពុទ្ធ-បរិស័ទផឹកសុរា និងមេរ័យ។

(ចប់សិក្ខាបទប្រាំ)

ទី៦_សីលវិកាល ហាមកុំអាលបរិភោគ្គា ក្នុងពេលជ្រេស្ងួរិយា រហូតដល់អរុណរះ។

ទី៧_សីលនច្ចគី ព្រះមុនីទ្រង់ឱ្យលះ ឱ្យវៀរចាកស្រឡះចេញពីគ្រឿងដែលជាល្បែង។

ទី៨_សីលឧច្ចា ព្រះសាស្តាទ្រង់សំដែងហាមត្រង់ទីកន្លែងដេកអង្គុយហួសប្រមាណ។

*គឺពួកទ្រនាប់នោះ ចូរចាំចុះគ្រប់ៗប្រាណ ត្រែខ្ពស់ហួសប្រមាណ ប្រាំបីធ្លាប់ព្រះសុគត។

*ហាមមិនឱ្យស្នាក់អាស្រ័យ អស់យប់ថ្ងៃមួយប្រាកដ ឱ្យខំភាវនាបទកម្មដ្ឋានវិបស្សនា។

*ហេតុនេះ លោកទាំងឡាយស្តាប់បរិយាយ ព្រះសាស្តានេះហើយព្រះទេសនាទ្រង់ត្រាស់ថាដើមកុសល។

*ប្រសិនបើ លោកណាបានរក្សា នឹងបានផលប្រសើរ ឥតផ្ទឹមដល់ រួចចាកទុក្ខផងទាំងឡាយ។

*ហើយនឹងបានដល់ឋានព្រះនិព្វានប្រសើរសាយជាទីសុខសប្បាយ ឥតមានទុក្ខជិតដល់ឡើយ។

(ចប់សិក្ខាបទប្រាំបី)

ចប់ធម៌សូត្រម៉ោង ៣ កន្លះជិតភ្លឺ

# ធម៌សូត្រ ម៉ោង ៩ ព្រឹក

១.ឥមេហិ ទីបធូបា...
២.នមោ តស្ស...
៣.យោ សន្និសិន្នោ...
៤.ពុទ្ធំ ជីវិតំ...
៥.យេ ច ពុទ្ធា...
៦.ឥតិបិ សោ ភគវា...
៧.នត្ថិ មេ សរណំ...
៨.ឧត្តមង្គេន...
៩.អដ្ឋង្គិការិយបថោ...
១០.ធម្មំ ជីវិតំ...
១១.យេ ច ធម្មា...
១២.ស្វាក្ខាតោ...
១៣.នត្ថិ មេ សរណំ+ អវិជ្ជាយត្ងេវ..
១៤.ឧត្តមង្គេន...
១៥.សង្ឃោ វិសុទ្ធោ...
១៦.សង្ឃំ ជីវិតំ...
១៧.យេ ច សង្ឃា...
១៨.សុបដិបន្នោ ភគវតោ...
១៩.នត្ថិ មេ សរណំ...
២០.ឧត្តមង្គេន...
២១.កែវមួយ គឺព្រះពុទ្ធ...
២២.វន្ទាមិ ចេតិយំ...
២៣.វន្ទាមិ ពុទ្ធំ...
២៤.យោ កប្បកោដី...
២៥.ឥច្ចេវមច្ចន្ត...
២៦.បរាភវសូត្រ...
២៧.ពុទ្ធជយមង្គល...
២៨.មហាការុណិកោ...
២៩.នមោ តស្ស +កុសលា...
៣០.តទនន្តរំ.វិភង្គ+ ធាតុកថា+ បុគ្គល-
បញ្ញត្តិ+ កថាវត្ថុ+ យមក + មហាបដ្ឋាន
៣១.អវិជ្ជាបច្ចយា...
៣២. តិរោកុឌ្ឌេសុ...
៣៣.មេត្តញ្ច...+ន គាមធម្មោ...
៣៥.យថា...+យំ កិញ្ចិ...

# ធម៌ពិស្តារដែលព្រះសង្ឃត្រូវស្វាធ្យាយ

# អភិធម្មបិដក ធម្មសង្គណី

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស សូមនមស្ការ ចំពោះព្រះដ៏មានព្រះភាគ ជាអរហន្ត សម្មាសម្ពុទ្ធព្រះអង្គនោះ (ដោយគោរព)។

## មាតិកា [១]

កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា ពួកធម៌ជាកុសល ពួកធម៌ជាអកុសល ពួកធម៌ជាអព្យាក្រឹត។

សុខាយ វេទនាយ សម្បយុត្តា ធម្មា ទុក្ខាយ វេទនាយ សម្បយុត្តា ធម្មា អទុក្ខមសុខាយ

---

១_សេចក្តីប្រែបានចម្លងតាមព្រះត្រៃបិដក លេខ ៧៨ ។

វេទនាយ សម្បយុត្តា ធម្មា ពួកធម៌ប្រកបដោយ សុខវេទនា ពួកធម៌ប្រកបដោយទុក្ខវេទនា ពួកធម៌ ប្រកបដោយវេទនា មិនជាទុក្ខ មិនជាសុខ។

វិបាកា ធម្មា វិបាកធម្មធម្មា នេវ វិបាកន-វិបាកធម្មធម្មា ពួកធម៌ជាវិបាក ពួកធម៌មានវិបាកជា ប្រក្រតី ពួកធម៌មិនមែនជាវិបាក ទាំងមិនមែនមាន វិបាកជាប្រក្រតី។

ឧបាទិន្នុបាទានិយា ធម្មា អនុបាទិន្នុបាទា-និយា ធម្មា អនុបាទិន្នានុបាទានិយា ធម្មា ពួកធម៌ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់ យក ហើយទាំងជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម មិន កាន់យកទេ តែជាប្រយោជន៍ដល់ឧបាទាន ពួកធម៌

មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម មិនទាន់កាន់យកទេ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន។

សង្កិលិដ្ឋសង្កិលេសិកា ធម្មា អសង្កិលិដ្ឋ-សង្កិលេសិកា ធម្មា អសង្កិលិដ្ឋាសង្កិលេសិកា ធម្មា ពួកធម៌ដែលសៅហ្មង ទាំងគួរដើម្បីដល់នូវសេចក្តីសៅហ្មង ពួកធម៌ដែលមិនសៅហ្មង តែគួរដើម្បីដល់នូវសេចក្តីសៅហ្មង ពួកធម៌ដែលមិនសៅហ្មង ទាំងមិនគួរដើម្បីដល់នូវសេចក្តីសៅហ្មង

សវិតក្កសវិចារា ធម្មា អវិតក្កវិចារមត្តា ធម្មា អវិតក្កាវិចារា ធម្មា ពួកធម៌ប្រកបដោយវិតក្កៈ ទាំងប្រកបដោយវិចារៈ ពួកធម៌គ្មានវិតក្កៈ មានត្រឹមតែវិចារៈ ពួកធម៌គ្មានវិតក្កៈ ទាំងគ្មានវិចារៈ។

បីតិសហគតា ធម្មា សុខសហគតា ធម្មា

ឧបេក្ខាសហគតា ធម្មា ពួកធម៌ប្រកបដោយបីតិ ពួកធម៌ប្រកបដោយសុខៈ ពួកធម៌ប្រកបដោយឧបេក្ខា

ទស្សនេន បហាតព្វា ធម្មា ភាវនាយ បហាតព្វា ធម្មា នេវ ទស្សនេន ភាវនាយ បហាតព្វា ធម្មា ពួកធម៌ដែលមិនត្រូវលះដោយទស្សនៈ ទាំងមិនត្រូវលះដោយភាវនា។

ទស្សនេន បហាតព្វហេតុកា ធម្មា ភាវនាយ បហាតព្វហេតុកា ធម្មា នេវទស្សនេន ភាវនាយ បហាតព្វហេតុកា ធម្មា ពួកធម៌មានហេតុដែលត្រូវលះដោយទស្សនៈ ពួកធម៌មានហេតុ ដែលត្រូវលះដោយភាវនា ពួកធម៌មានហេតុដែលត្រូវលះដោយទស្សនៈ ទាំងមិនត្រូវលះដោយភាវនា។

អាចយគាមិនោ ធម្មា អបចយគាមិនោ ធម្មា

នេវាចយគាមិនោ នាបចយគាមិនោ ធម្មា ពួកធម៌ ដល់នូវការសន្សំកពូនឡើង (ដោយកម្មក្កិលេស) ពួកធម៌មិនដល់នូវការសន្សំកពូនឡើង ពួកធម៌មិនមែនជាដល់នូវការសន្សំពូនឡើង ទាំងមិនមែនជាមិនដល់នូវការសន្សំកពូនឡើង។

សេក្ខា ធម្មា អសេក្ខា ធម្មា នេវ សេក្ខា-នាសេក្ខា ធម្មា ពួកធម៌ជារបស់សេក្ខបុគ្គល ពួកធម៌ជារបស់អសេក្ខបុគ្គល ពួកធម៌មិនមែនជារបស់អសេក្ខ-បុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល។

បរិត្តា ធម្មា មហគ្គតា ធម្មា អប្បមាណា ធម្មា ពួកធម៌មានសភាពតូចឆ្មារ ពួកធម៌ដល់នូវសភាពធំ ពួកធម៌ប្រមាណមិនបាន។

បរិត្តារម្មណា ធម្មា មហគ្គតារម្មណា ធម្មា

អប្បមាណារម្មណា ធម្មា ពួកធម៌មានអារម្មណ៍តូចឆ្មារ ពួកធម៌មានអារម្មណ៍ដល់នូវសភាពធំ ពួកធម៌មានអារម្មណ៍ប្រមាណមិនបាន។

ហីនា ធម្មា មជ្ឈិមា ធម្មា បណីតា ធម្មា ពួកធម៌ថោកទាប ពួកធម៌យ៉ាងកណ្តាល ពួកធម៌ដ៏ឧត្តម

មិច្ឆត្តនិយតា ធម្មា សម្មត្តនិយតា ធម្មា អនិយតា ធម្មា ពួកធម៌មានសភាពខុស និងទៀង ពួកធម៌មានសភាពត្រូវ និងទៀង ពួកធម៌មិនទៀង។

មគ្គារម្មណា ធម្មា មគ្គហេតុកា ធម្មា មគ្គាធិបតិនោ ធម្មា ពួកធម៌មានមគ្គជាអារម្មណ៍ ពួកធម៌មានមគ្គជាហេតុ ពួកធម៌មានមគ្គហេតុជាអធិបតី។

ឧប្បន្នា ធម្មា អនុប្បន្នា ធម្មា ឧប្បាទិនោ ធម្មា ពួកធម៌កើតឡើងហើយ ពួកធម៌មិនទាន់កើតឡើង

ពួកធម៌ប្រុងនឹងកើតឡើង។

អតីតា ធម្មា អនាគតា ធម្មា បច្ចុប្បន្នា ធម្មា ពួកធម៌ជាអតីតៈ ពួកធម៌ជាអនាគត ពួកធម៌ជាបច្ចុប្បន្ន

អតីតារម្មណា ធម្មា អនាគតារម្មណា ធម្មា បច្ចុប្បន្នារម្មណា ធម្មា ពួកធម៌មានអារម្មណ៍ជាអតីតៈ ពួកធម៌មានអារម្មណ៍ជាអនាគត ពួកធម៌មានអារម្មណ៍ជាបច្ចុប្បន្ន។

អជ្ឈត្តា ធម្មា ពហិទ្ធា ធម្មា អជ្ឈត្តពហិទ្ធា ធម្មា ពួកធម៌ជាខាងក្នុង ពួកធម៌ជាខាងក្រៅ ពួកធម៌ជាខាងក្នុង និងខាងក្រៅ។

អជ្ឈត្តារម្មណា ធម្មា ពហិទ្ធារម្មណា ធម្មា

អជ្ឈត្តពហិទ្ធារម្មណា ធម្មា ពួកធម៌មានអារម្មណ៍ខាងក្នុង ពួកធម៌មានអារម្មណ៍ខាងក្រៅ ពួក

ធម៌មានអារម្មណ៍ខាងក្នុង និងខាងក្រៅ។

សនិទស្សនសប្បដិឃា ធម្មា អនិទស្សន-សប្បដិឃា ធម្មា អនិទស្សនាប្បដិឃា ធម្មា ពួកធម៌ប្រកបដោយការឃើញ[២] ទាំងប្រកបដោយការប៉ះពាល់ ពួកធម៌ប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ពួកធម៌មិនមានប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់។

ពាវីសតិ តិកមាតិកា ចប់តិកមាតិកា ២២។

ធម្មសង្គណិប្បករណំ នាម សមត្តំ ធម្មសង្គ-ណិប្បករណ៍ ចប់តែប៉ុណ្ណេះ។

---

[២] -ការឃើញ សំដៅយកសោតាបត្តិមគ្គ។

# វិភង្គ

## ក្នុងអដ្ឋកថា

(តទនន្តរំ វិភង្គប្បករណំ នាមេតំ លំដាប់អំពីធម្មសង្គណិប្បករណ៍នោះមក យើងនឹងស្វាធ្យាយនូវវិភង្គប្បករណ៍ដូចតទៅនេះ)

ខន្ធវិភង្គោ អាយតនវិភង្គោ ធាតុវិភង្គោ សច្ចវិភង្គោ ឥន្ទ្រិយវិភង្គោ បច្ចយាការវិភង្គោ សតិប្បដ្ឋានវិភង្គោ សម្មប្បធានវិភង្គោ ឥទ្ធិបាទ-វិភង្គោ ពោជ្ឈង្គវិភង្គោ មគ្គវិភង្គោ ឈាន-វិភង្គោ អប្បមញ្ញាវិភង្គោ សិក្ខាបទវិភង្គោ បដិសម្ភិទាវិភង្គោ ញាណវិភង្គោ ខុទ្ទកវត្ថុ-វិភង្គោ ធម្មហទយវិភង្គោ។

(វិភង្គ ១៨) គឺ ខន្ធវិភង្គ អាយតនវិភង្គ ធាតុវិភង្គ សច្ចវិភង្គ ឥន្ទ្រិយវិភង្គ បច្ចយាការវិភង្គ សតិប្បដ្ឋានវិភង្គ សម្មប្បធានវិភង្គ ឥទ្ធិបាទវិភង្គ ពោជ្ឈង្គវិភង្គ មគ្គវិភង្គ ឈានវិភង្គ អប្បមញ្ញាវិភង្គ សិក្ខាបទវិភង្គ បដិសម្ភិទាវិភង្គ ញាណវិភង្គ ខុទ្ទកវត្ថុវិភង្គ ធម្មហទយវិភង្គ។

(**អដ្ឋារសវិធេន វិភត្តំ វិភង្គប្បករណំ នាម សមត្តំ** វិភង្គប្បករណ៍ ចែកចេញដោយវិភង្គ ១៨ ប្រការ ចប់តែប៉ុណ្ណេះ)។

# ធាតុកថា

## ក្នុងអដ្ឋកថា

(តទនន្តរំ ធាតុកថាបករណំ នាមេតំ លំដាប់អំពីវិភង្គប្បករណ៍នោះមក យើងនឹងស្វាធ្យាយនូវធាតុកថាបករណ៍ដូចតទៅនេះ )

សង្គហោ អសង្គហោ (ធាតុ ១៨ គឺ) ការសង្គ្រោះ និងការមិនសង្គ្រោះ ១។

សង្គហិតេន អសង្គហិតំ ការមិនសង្គ្រោះ មួយអន្លើដោយការសង្គ្រោះ ១។

អសង្គហិតេន សង្គហិតំ ការសង្គ្រោះមួយអន្លើដោយការមិនសង្គ្រោះ ១។

សង្គហិតេន សង្គហិតំ ការសង្គ្រោះ មួយអន្លើដោយការសង្គ្រោះ ១។

អសង្គហិតេន អសង្គហិតំ ការមិនសង្គ្រោះ មួយអន្លើដោយការមិនសង្គ្រោះ ១។

សម្បយោគោ វិប្បយោគោ ការសមប្រកប និងការប្រាសចេញ ១។

សម្បយុត្តេន វិប្បយុត្តំ ការប្រាសចេញមួយ

អន្ទើដោយការសមប្រកបមួយ ១។

វិប្បយុត្តេន សម្បយុត្តំ ការសមប្រកបមួយ អន្ទើដោយការប្រាសចេញ ១។

សម្បយុត្តេន សម្បយុត្តំ ការសមប្រកបមួយ អន្ទើដោយការសមប្រកប ១។

វិប្បយុត្តេន វិប្បយុត្តំ ការប្រាសចេញ មួយអន្ទើដោយការប្រាសចេញ ១។

សង្គហិតេន សម្បយុត្តំ វិប្បយុត្តំ ការសមប្រកប និងការប្រាសចេញ មួយអន្ទើដោយការសង្គ្រោះ ១។

សម្បយុត្តេន សង្គហិតំ អសង្គហិតំ ការសង្គ្រោះ និងការមិនសង្គ្រោះ មួយអន្ទើដោយការសមប្រកប ១។

អសង្គហិតេន សម្បយុត្តំ វិប្បយុត្តំ ការសមប្រកបនិងការប្រាសចេញមួយអន្ទើដោយការមិនសង្គ្រោះ១។

វិប្បយុត្តេន សង្គហិតំ អសង្គហិតន្តិ ការសង្គ្រោះ និងការមិនសង្គ្រោះ មួយអន្លើដោយការប្រាសចេញ ១១។

(ចុទ្ទសវិធេន វិភត្តំ ធាតុកថាបករណំ នាមសមត្តំ ធាតុកថាបករណ៍ ចែកចេញដោយធាតុ ១៤ ប្រការចប់តែប៉ុណ្ណេះ)។

# បុគ្គលប្បញ្ញត្តិ

## ក្នុងអដ្ឋកថា

(តទនន្តរំ បុគ្គលប្បញ្ញត្តិប្បករណំ នាមេសា លំដាប់អំពីធាតុកថាបករណ៍នោះមក យើងនឹងស្វាធ្យាយនូវបុគ្គលប្បញ្ញត្តិប្បករណ៍ដូចតទៅនេះ)

ខន្ធប្បញ្ញត្តិ អាយតនប្បញ្ញត្តិ ធាតុប្បញ្ញត្តិ សច្ចប្បញ្ញត្តិ ឥន្ទ្រិយប្បញ្ញត្តិ បុគ្គលប្បញ្ញត្តីតិ

(បញ្ញត្តិ ៦ គឺ) ខន្ធប្បញ្ញត្តិ អាយតនប្បញ្ញត្តិ ធាតុប្បញ្ញត្តិ សច្ចប្បញ្ញត្តិ ឥន្ទ្រិយប្បញ្ញត្តិ បុគ្គលប្បញ្ញត្តិ។

(ឆវិធេន វិភត្តំ បុគ្គលប្បញ្ញត្តិប្បករណំ នាម សមត្តំ បុគ្គលប្បញ្ញត្តិប្បករណ៍ ចែកចេញដោយបញ្ញត្តិ ៦ ប្រការចប់តែប៉ុណ្ណោះ)។

## កថាវត្ថុ

### ក្នុងអដ្ឋកថា

(តទនន្តរំ កថាវត្ថុប្បករណំ នាមេតំ លំដាប់អំពីបុគ្គលប្បញ្ញត្តិប្បករណ៍នោះមក យើងនឹងស្វាធ្យាយនូវកថាវត្ថុប្បករណ៍ដូចតទៅនេះ)

សកវាទិបញ្ចសុត្តសតានិ បរវាទិបញ្ចសុត្ត-សតានីតិ សុត្តសហស្សំ សមោធានេត្វាន វិភត្តំ កថាវត្ថុប្បករណំ នាម សមត្តំ កថាវត្ថុប្បករណ៍

ដែលប្រជុំចែកជាមួយពាន់សូត្រ គឺប្រាំរយសូត្ររបស់សកវាទី ប្រាំរយសូត្ររបស់បរវាទី ចប់តែប៉ុណ្ណេះ។

# យមកៈ

## ក្នុងអដ្ឋកថា

(តទនន្តរំ យមកប្បករណំ នាមេតំ លំដាប់អំពីកថាវត្ថុប្បករណ៍នោះមក យើងនឹងស្វាធ្យាយ នូវយមកប្បករណ៍ដូចតទៅនេះ)

មូលយមកំ ខន្ធយមកំ អាយតនយមកំ ធាតុយមកំ សច្ចយមកំ សង្ខារយមកំ អនុសយយមកំ ចិត្តយមកំ ធម្មយមកំ ឥន្ទ្រិយយមកន្តិ (យមកៈ១០) គឺមូលយមកៈ ខន្ធយមកៈ អាយតនយមកៈ ធាតុយមកៈ សច្ចយមកៈ សង្ខារយមកៈ អនុសយយមកៈ ចិត្តយមកៈ ធម្មយមកៈ ឥន្ទ្រិយយមកៈ

(ទសវិធេន វិភត្តំ យមកប្បករណំ នាម សមត្តំ យមកប្បករណ៍ ចែកចេញដោយ យមកៈ ១០ ប្រការ ចប់តែប៉ុណ្ណេះ)។

# បដ្ឋាន

## ក្នុងអដ្ឋកថា

(តទនន្តរំ មហាបដ្ឋានប្បករណំ នាមេតំ លំដាប់អំពីយមកប្បករណ៍នោះមក យើងនឹងស្វាធ្យាយនូវមហាបដ្ឋានប្បករណ៍ដូចតទៅនេះ)

ហេតុប្បច្ចយោ អារម្មណប្បច្ចយោ អធិបតិប្បច្ចយោ អនន្តរប្បច្ចយោ សមនន្តរប្បច្ចយោ សហជាតប្បច្ចយោ អញ្ញមញ្ញប្បច្ចយោ និស្សយប្បច្ចយោ ឧបនិស្សយប្បច្ចយោ បុរេជាតប្ប-

ច្ចយោ បច្ឆាជាតប្បច្ចយោ អាសេវនប្បច្ចយោ កម្មប្បច្ចយោ វិបាកប្បច្ចយោ អាហារប្បច្ចយោ ឥន្ទ្រិយប្បច្ចយោ ឈានប្បច្ចយោ មគ្គប្បច្ចយោ សម្បយុត្តប្បច្ចយោ វិប្បយុត្តប្បច្ចយោ អត្ថិប្ប-ច្ចយោ នត្ថិប្បច្ចយោ វិគតប្បច្ចយោ អវិគតប្ប-ច្ចយោតិ (បច្ច័យ ២៤ គឺ) ហេតុប្បច្ច័យ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ សហ-ជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧប-និស្សយប្បច្ច័យ បុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ អាសេវនប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារ-ប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិ-ប្បច្ច័យ វិគតប្បច្ច័យ អវិគតប្បច្ច័យ។

(បច្ចយវសេន តា ចតុវីសតិវិធេន វិភត្តំ មហាបដ្ឋានប្បករណំ នាម សមត្តំ មហាបដ្ឋាន-ប្បករណ៍ចែកចេញជាធម៌ ២៤ ប្រការ ដោយអំណាច នៃបច្ច័យ ចប់តែប៉ុណ្ណេះ)។

# បដិច្ចសមុប្បាទ

អវិជ្ជាបច្ចយា សង្ខារា សង្ខារទាំងឡាយ (កើតមាន) ព្រោះបច្ច័យ គឺអវិជ្ជា ពោលគឺសេចក្ដីល្ងង់។

សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណ (កើតមាន) ព្រោះបច្ច័យ គឺសង្ខារ។

វិញ្ញាណប្បច្ចយា នាមរូបំ នាម និងរូប (កើតមាន) ព្រោះបច្ច័យ គឺវិញ្ញាណ។

នាមរូបប្បច្ចយា សឡាយតនំ អាយតនៈ ៦

(កើតមាន) ព្រោះបច្ច័យ គឺនាម និងរូប។

សឡាយតនប្បច្ចយា ផស្សោ សម្ផស្ស (កើតមាន) ព្រោះបច្ច័យ គឺអាយតនៈ ៦។

ផស្សប្បច្ចយា វេទនា វេទនា (កើតមាន) ព្រោះបច្ច័យ គឺសម្ផស្ស។

វេទនាបច្ចយា តណ្ហា តណ្ហា (កើតមាន) ព្រោះបច្ច័យ គឺវេទនា។

តណ្ហាបច្ចយា ឧបាទានំ ឧបាទាន (កើតមាន) ព្រោះបច្ច័យ គឺតណ្ហា។

ឧបាទានប្បច្ចយា ភវោ ភព (កើតមាន) ព្រោះបច្ច័យ គឺឧបាទាន។

ភវប្បច្ចយា ជាតិ ជាតិ (កើតមាន) ព្រោះបច្ច័យ គឺភព។

ជាតិប្បច្ចយា ជរាមរណំ ជរា និងមរណៈ (កើតមាន) ព្រោះបច្ច័យ គឺជាតិ។

សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភ-វន្តិ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីព្រួយ សេចក្តីតូចចិត្ត និងសេចក្តីចង្អៀតចង្អល់ទាំងឡាយ ក៏រមែងកើតមាន (ព្រោះជាតិជាបច្ច័យដែរ)។

ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ កិរិយាកើតមាន នៃទុក្ខទាំងអស់នេះ មានដោយប្រការដូច្នេះ។

អវិជ្ជាយត្វេវ អសេសវិរាគនិរោធា សង្ខារ-និរោធោ កិរិយារលត់នៃសង្ខារ ព្រោះកិរិយារលត់ដោយអរិយមគ្គ ឥតមានសេសសល់ នៃអវិជ្ជាមែនពិត។

សង្ខារនិរោធា វិញ្ញាណនិរោធោ កិរិយារលត់

នៃវិញ្ញាណ ព្រោះរលត់នៃសង្ខារ។

វិញ្ញាណនិរោធា នាមរូបនិរោធោ កិរិយារលត់នៃនាម និងរូប ព្រោះរលត់នៃវិញ្ញាណ។

នាមរូបនិរោធា សឡាយតននិរោធោ កិរិយារលត់នៃអាយតនៈ ៦ ព្រោះរលត់នៃនាម និងរូប។

សឡាយតននិរោធា ផស្សនិរោធោ កិរិយារលត់នៃសម្ផស្ស ព្រោះរលត់នៃអាយតនៈ ៦។

ផស្សនិរោធា វេទនានិរោធោ កិរិយារលត់នៃវេទនា ព្រោះរលត់នៃសម្ផស្ស។

វេទនានិរោធា តណ្ហានិរោធោ កិរិយារលត់នៃតណ្ហា ព្រោះរលត់នៃវេទនា។

តណ្ហានិរោធា ឧបាទាននិរោធោ កិរិយារលត់នៃឧបាទាន ព្រោះរលត់នៃតណ្ហា។

ឧបាទាននិរោធា ភវនិរោធោ កិរិយារលត់នៃភព ព្រោះរលត់នៃឧបាទាន។

ភវនិរោធា ជាតិនិរោធោ កិរិយារលត់នៃជាតិ ព្រោះរលត់នៃភព។

ជាតិនិរោធា ជរាមរណំ ជរា និង មរណៈ (រលត់) ព្រោះកិរិយារលត់នៃជាតិ។

សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ សេចក្តីសោក សោចក្តីខ្សឹកខ្សួល សេចក្តីព្រួយ សេចក្តីតូចចិត្ត និងសេចក្តីចង្អៀតចង្អល់ទាំងឡាយ ក៏រមែងរលត់ទៅ (ព្រោះកិរិយារលត់ទៅនៃជាតិដែរ)។

ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ កិរិយារលត់ទៅនៃកងទុក្ខទាំងអស់នេះ មានដោយប្រការដូច្នេះ។

# តិរោកុឌ្ឍកណ្ឌគាថា

តិរោកុឌ្ឌេសុ តិដ្ឋន្តិ សន្ធិសិង្ឃាដកេសុ ច
ទ្វារពាហាសុ តិដ្ឋន្តិ អាគន្ត្វាន សកំ ឃរំ

ពួកប្រេតទាំងឡាយមកហើយ កាន់ផ្ទះនៃញាតិ ដោយគិតថា ផ្ទះរបស់ខ្លួន រមែងឈរនៅជិតខាងក្រៅជញ្ជាំងផ្ទះទាំងឡាយខ្លះ នាផ្លូវបែកជា ៤ និងផ្លូវបែកជា ៣ ទាំងឡាយខ្លះ ជិតទ្វារក្រុង និងទ្វារផ្ទះទាំងឡាយខ្លះ។

បហុតេ អន្នបានម្ហិ ខជ្ជភោជេ ឧបដ្ឋិតេ

នាកាលបាយ និងទឹក និងបង្អែម និងចំអាប ដ៏ល្មមគ្រាន់ គឺពួកញាតិចូលទៅតាំងទុកហើយ។

ន តេសំ កោចិ សរតិ សត្តានំ កម្មប្បច្ចយា

ញាតិណាមួយ មិននឹកដល់ប្រេតទាំងឡាយនោះ ព្រោះកម្មរបស់សត្វទាំងឡាយជាបច្ច័យ។

ឯវំ ទទន្តិ ញាតីនំ យេ ហោន្តិ អនុកម្បកា
សុចឹ បណីតំ កាលេន កប្បិយំ បានភោជនំ

ញាតិទាំងឡាយឯណា តែងអនុគ្រោះ ញាតិទាំងឡាយនោះ រមែងឧទ្ទិសឱ្យនូវទឹក និងភោជនដ៏ហ្មត់ចត់ ដ៏ប្រសើរ ជារបស់គួរតាមកាលដល់ញាតិទាំងឡាយ ជាអ្នកលះលោកនេះទៅហើយនោះ យ៉ាងនេះថា

ឥទំ វោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ

ទាននេះ ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយចូរជាអ្នកដល់នូវសេចក្តីសុខ។

តេ ច តត្ថ សមាគន្ត្វា ញាតិបេតា សមាគតា

ក៏ប្រេតជាញាតិទាំងឡាយនោះ មកប្រជុំគ្នាហើយ ក្នុងស្ថានដែលឱ្យទាននោះ ជាអ្នកមកហើយដោយបំណងល្អ។

បហុតេ អន្នបានម្ហិ សក្កច្ចំ អនុមោទរេ

កាលបើថ្វាយបាយ និងទឹកដ៏ល្អមគ្រាន់ ក៏គប្បីអនុមោទនាដោយគោរពថា

ចិរំ ជីវន្តុ នោ ញាតី យេសំ ហេតុលភាមសេ

យើងទាំងឡាយ បានសម្បត្តិនេះ ព្រោះហេតុនៃញាតិទាំងឡាយឯណា សូមញាតិទាំងឡាយនោះ របស់យើងទាំងឡាយ ចូររស់នៅយឺនយូរ។

អម្ហាកញ្ច កតា បូជា ក៏បូជា គឺញាតិទាំងឡាយធ្វើហើយដល់យើងទាំងឡាយ។ ទាយកា ច អនិប្ផលា ឯទាយកគឺអ្នកឱ្យទានក៏មិនឥតផល។ ន ហិ តត្ថ កសី អត្ថិ កសិកម្ម គឺការភ្ជួរស្រែចំការ ក៏មិនមានក្នុងភូមិនៃប្រេតនោះ។ គោរក្ខេត្ថ ន វិជ្ជតិ គោរក្ខ-កម្ម គឺការរក្សាគោ ក៏មិនមានក្នុងភូមិនៃប្រេតនោះ វណិជ្ជា តាទិសី នត្ថិ ពាណិជ្ជកម្ម គឺការជួញដែល

ជាហេតុបានសម្បត្តិដូច្នោះ ក៏មិនមាន ។ ហិរញ្ញន កយាកយំ មិនមានការលក់ទិញ ផ្លាស់ប្តូរដោយប្រាក់។

ឥតោ ទិន្នេន យាបេន្តិ បេតា កាលកតា តហឹ

បុគ្គលទាំងឡាយ ធ្វើកាលកិរិយា ទៅកើតជាប្រេត រមែងញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងប្រេតវិស័យនោះ ដោយផលទានដែលញាតិឱ្យហើយអំពីលោកនេះ។

ឧណ្ណតេ ឧទកំ វុដ្ឋំ                យថា និន្នំ បវត្តតិ
ឯវមេវ ឥតោ ទិន្នំ              បេតានំ ឧបកប្បតិ

ទឹកធ្លាក់ចុះក្នុងទីទួល រមែងហូរទៅកាន់ទីទំនាប ដូចម្តេចមិញ ទានដែលបុគ្គលឱ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយដូច្នោះដែរ។

យថា វារិវហា បូរា              បរិបូរេន្តិ   សាគរំ
ឯវមេវ ឥតោ ទិន្នំ              បេតានំ  ឧបកប្បតិ

ជ្រលងផ្លូវទឹកទាំងឡាយ មានទន្លេ និងស្ទឹងជាដើម រមែងញ៉ាំងសាគរឱ្យពេញ ប្រៀបដូចម្ដេចមិញ ទានដែលបុគ្គលឱ្យហើយអំពីលោកនេះរមែងសម្រេចផលដល់ប្រេតទាំងឡាយដូច្នោះដែរ។

**អទាសិ មេ អកាសិ មេ ញាតិមិត្តា សុខា ច មេ បេតានំ ទក្ខិណំ ទជ្ជា បុព្វេ កតមនុស្សរំ**

បុគ្គលកាលរលឹកឃើញនូវឧបការគុណដែលលោកធ្វើទុកដល់ខ្លួនក្នុងកាលមុនថា អ្នកនេះបានឱ្យរបស់នេះដល់អញ អ្នកនេះបានធ្វើគុណនេះ ដល់អញ ជនទាំងឡាយនោះ ជាញាតិមិត្ត និងជាសម្លាញ់របស់អញដូច្នេះហើយ គួរឱ្យទក្ខិណាទាន ដើម្បីប្រេតទាំងឡាយ។

**ន ហិ រុណ្ណំ វា សោកោ វា យាវញ្ញា បរិទេវនា**

ការយំ ឬសោកសៅ ឬការខ្សឹកខ្សួលដទៃៗ មិនមាន

ប្រយោជន៍ឡើយ។ ន តំ បេតានមត្ថាយ ធ្វើដូច្នេះរកបានជាប្រយោជន៍ ដល់ប្រេតទាំងឡាយគ្មាន។ ឯវំ តិដ្ឋន្តិ ញាតយោ ញាតិទាំងឡាយ រមែងស្ថិតនៅឥតបានដឹង បានឮយ៉ាងនេះ។ អយញ្ច ខោ ទក្ខិណា ទិន្នា បើទក្ខិណាទាន ដែលបុគ្គលបានឱ្យហើយនេះឯង សង្ឃម្ហិ សុបតិដ្ឋិតា ជាទានដំកល់នៅល្អហើយក្នុងសង្ឃ។ ទីឃរត្តំ ហិតាយស្ស ឋានសោ ឧបកប្បតិ ទក្ខិណាទាននោះ ទើបចូលទៅសម្រេចតាមស្ថាន ដើម្បីជាប្រយោជន៍ដល់ប្រេតនោះអស់កាលជាអង្វែង។

សោ ញាតិធម្មោ ច អយំ និទស្សិតោ ក៏ញាតិធម៌នោះ គឺអ្នកបានសម្តែងជាបែបយ៉ាងហើយ។

បេតាន បូជា ច កតា ឧឡារា ការបូជាដ៏ថ្លៃ

ថ្វា ចំពោះដល់ប្រេតទាំងឡាយ គឺអ្នកបានធ្វើហើយ។

ពលញ្ច ភិក្ខូនមនុប្បទិន្នំ កម្លាំងកាយនៃភិក្ខុទាំងឡាយ ឈ្មោះថា គឺអ្នកបានបំពេញឱ្យហើយ។

តុម្ហេហិ បុញ្ញំ បសុតំ អនប្បកន្តិ បុណ្យ គឺអ្នកសន្សំទុកហើយមិនមែនតិចដូច្នេះ។

យទិ ហីនេ គតោ ឋានេ កាយទុច្ចរិតេន វា បើញាតិណាមួយ ទៅកើតក្នុងទីដ៏ថោកទាប ព្រោះកាយទុច្ចរិតក្តី (វចីទុច្ចរិតក្តី មនោទុច្ចរិតក្តី)។

ឥមិនា បុញ្ញតេជេន តម្ហា ឋានា បមុញ្ចតុ ក៏សូមឱ្យរួចរំដោះ ចាកទី (ដ៏ថោកទាប) នោះ ដោយតេជៈ គឺបុណ្យនេះ។

យទិ ទេវបុរេ រម្មេ វិមានេ រតនសោភិតេ ឬបើទៅកើតក្នុងទេវបុរី ជាវិមានគួរីករាយ ដែលជា

ឋានមានលំអរដោយរតនៈផ្សេងៗស្រាប់ហើយ។

ឥមិនា បុញ្ញតេជេន ភិយ្យោ ភិយ្យោ បវឌ្ឍតិ ក៏សូមឱ្យរីងរឹតតែចម្រើនជាភិយ្យោភាព ដោយតេជៈគឺបុណ្យនេះ។

ឯវំ មហិទ្ធិយា ឯសា យទិទំ បុញ្ញសម្បទា បុញ្ញសម្បទា គឺគុណជាតិជាហេតុដល់ព្រម ដោយបុណ្យឯណា បុញ្ញសម្បទានេះ មានឫទ្ធិដ៏ធំក្រៃលែងដោយប្រការយ៉ាងនេះ។

តស្មា ធីរា បសំសន្តិ បណ្ឌិតា កតបុញ្ញតំ ព្រោះហេតុនោះ បណ្ឌិតទាំងឡាយអ្នកមានប្រាជ្ញា រមែងសរសើរនូវភាពនៃបុគ្គល អ្នកមានបុណ្យធ្វើទុកហើយ។

សុខោ វិបាកោ បុញ្ញានំ ផលរបស់បុណ្យទាំងឡាយ រមែងនាំមកនូវសេចក្តីសុខ។ អធិប្បាយោ

សមិជ្ឈតិ សេចក្តីប្រាថ្នា រមែងសម្រេច។

ឱប្បញ្ច បរិយោសានេ និព្វានំ សមធិគច្ឆតិ ម្យ៉ាងទៀត ក្នុងកាលជាទីបំផុត បុគ្គលរមែងបាននូវព្រះនិព្វានដ៏ឆាប់រហ័ស។

យោ ភាជនសហស្សេហិ បូរណំ វរភោជនំ

ទទេយ្យ បរិមាណានំ ឯកបត្តម្បិ នាលភេ

ពុទ្ធុប្បាទេ សារីបុត្តោ យេ ចញ្ញេ អគ្គសាវកា

បុគ្គលគប្បីឱ្យនូវវរភោជន ដ៏ពេញដោយភាជនៈមួយពាន់ ក៏មិនបានស្មើនឹងភោជនមួយបាត្រ ដែលគេបានឱ្យហើយដល់ព្រះសារីបុត្រ និងពួកអគ្គសាវ័កដទៃ ក្នុងពុទ្ធុប្បាទ (នេះ) ដែលមានគុណប្រមាណមិនបាន ។

បត្តបូរានុភាវេន មាតាបិតា បមុញ្ចរេ (ព្រោះហេតុនោះ) បានជាមាតា និងបិតា រមែងរួច (ចាកទីដ៏

ថៅកទាប) ដោយអានុភាពនៃបាយដែលពេញក្នុងបាត្រ។

## សំវេជនីយគាថា

ន គាមធម្មោ និគមស្ស ធម្មោ ន ចាបិយំ ឯកកុលស្ស ធម្មោ សព្វស្ស លោកស្ស សទេវកស្ស ឯសេវ ធម្មោ យទិទំ អនិច្ចតា។

ធម៌ណាដែលមានឈ្មោះថា អនិច្ចតាធម៌ គឺសភាពប្រែប្រួលមិនទៀងទាត់ អនិច្ចតាធម៌នេះ មិនមែនជាធម៌សម្រាប់អ្នកស្រុក (តែមួយៗ)ទេ មិនមែនជាធម៌សម្រាប់អ្នកនិគម (តែមួយៗ)ទេ ឬនឹងថា ជាធម៌សម្រាប់ត្រកូលតែមួយៗ ក៏មិនមែនដែរ អនិច្ចតាធម៌នុ៎ះជាធម៌សម្រាប់មនុស្សសត្វ ព្រមទាំងទេវតាមារព្រហ្ម

ទាំងអស់គ្រប់រូប។

ន គាមធម្មោ និគមស្ស ធម្មោ ន ចាបិ យំ ឯកកុលស្ស ធម្មោ សព្វស្ស លោកស្ស សទេវកស្ស ឯសេវ ធម្មោ យទិទញ្ច ទុក្ខតា។

ធម៌ណាដែលមានឈ្មោះថា ទុក្ខតាធម៌ គឺសភាពជាទុក្ខ ទុក្ខតាធម៌នេះ មិនមែនជាធម៌សម្រាប់អ្នកស្រុក (តែមួយៗ) ទេ មិនមែនជាធម៌សម្រាប់អ្នកនិគម (តែមួយៗ) ទេ ឬនឹងថាជាធម៌សម្រាប់ត្រកូលតែមួយៗ ក៏មិនមែនដែរ ទុក្ខតាធម៌នុ៎ះ ជាធម៌សម្រាប់មនុស្សសត្វព្រមទាំងទេវតាមារព្រហ្មទាំងអស់គ្រប់រូប។

ន គាមធម្មោ និគមស្ស ធម្មោ ន ចាបិយំ ឯកកុលស្ស ធម្មោ សព្វស្ស លោកស្ស សទេវកស្ស ឯសេវ ធម្មោ យទិទំ អនត្តតា។

ធម៌ណាដែលមានឈ្មោះថា អនត្តាធម៌ គឺសភាព មិនមែនជារបស់ខ្លួន អនត្តាធម៌នេះ មិនមែនជាធម៌ សម្រាប់អ្នកស្រុក (តែមួយៗ) ទេ មិនមែនជាធម៌សម្រាប់ អ្នកនិគម (តែមួយៗ) ទេ ឬនឹងថា ជាធម៌សម្រាប់ត្រកូល តែមួយៗ ក៏មិនមែនដែរ អនត្តាធម៌នុ៎ះ ជាធម៌សម្រាប់ មនុស្សសត្វ ព្រមទាំងទេវតាមារព្រហ្មទាំងអស់គ្រប់រូប។

អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ

សង្ខារធម៌ទាំងឡាយ មិនទៀងមែនពិត មានកិរិយា កើតឡើង នឹងវិនាសទៅវិញជាធម្មតា រមែងតែកើត ឡើងហើយរលត់ទៅវិញ លុះតែរលត់នូវសង្ខារទាំង-ឡាយនោះហើយ ទើបបាននូវសេចក្តីសុខគ្រប់យ៉ាង។

សព្វេ សត្តា មរិស្សន្តិ មរណន្តំ ហិ ជីវិតំ

យថាកម្មំ គមិស្សន្តិ បុញ្ញបាបផលូបគា និរយំ បាបកម្មន្តា បុញ្ញកម្មា ច សុគតឹ។

សត្វទាំងឡាយទៀងតែនឹងស្លាប់គ្រប់ៗគ្នា ព្រោះថា ជីវិត (របស់សត្វទាំងឡាយ) សុទ្ធតែមានសេចក្តីស្លាប់ នៅខាងចុងបំផុតគ្រប់ៗប្រាណ (ម្យ៉ាងទៀត) សត្វទាំងឡាយ រមែងកាន់យកនូវផលបុណ្យ ផលបាប ហើយនឹងទៅតាមយថាកម្ម គឺទៅតាមគួរដល់អំពើល្អ និងអាក្រក់ដែលខ្លួនបានធ្វើ អ្នកដែលធ្វើបាប តែងធ្លាក់ទៅសោយទុក្ខក្នុងនរក ចំណែកខាងអ្នកធ្វើបុណ្យ តែងឡើងទៅកាន់សុគតិភព។

តស្មា ករេយ្យ កល្យាណំ និចយំ សម្បរាយិកំ បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ។

ព្រោះហេតុដូច្នោះហើយ សាធុជនអ្នកមានចំណង់

ចង់បានសេចក្តីសុខដល់ (ខ្លួន) គួរតែប្រញាប់ប្រញាល់ធ្វើអំពើបុណ្យដែលជាគុណ គឺអ្នកប្រាជ្ញតែងរាប់អានឱ្យបានជានិច្ច គឺខ្លួនត្រូវកសាងសន្សំ (គ្រាន់នឹងបានជាទីពឹង) ទៅក្នុងភពខាងនាយ (ព្រោះថា) បុណ្យទាំងឡាយតែងជាទីពឹងពុំនាក់របស់សត្វទាំងឡាយ ក្នុងបរលោក។

ផេណុបិណ្ឌោបមំ រូបំ វេទនា បុព្វុឡូបមា
មរីចិកូបមា សញ្ញា សង្ខារា កទលូបមា
មាយូបមញ្ចវិញ្ញាណំ ទេសិតា ទិច្ចពន្ធុនា

រូបមានសេចក្តីប្រៀបធៀបនឹងដុំនៃពពុះទឹក វេទនាមានសេចក្តីប្រៀបធៀបនឹងក្រពេញទឹក ដែលប៉ោងឡើងព្រួចៗ សញ្ញាមានសេចក្តីប្រៀបធៀបនឹងថ្ងៃបណ្តើរកូនសង្ខារទាំងឡាយ មានសេចក្តីប្រៀបធៀបនឹងដើមចេកវិញ្ញាណមានសេចក្តីប្រៀបធៀបនឹងកលមាយា (សេចក្តី

ប្រៀបធៀបនៃខន្ធទាំង ៥ នេះ) គឺព្រះសម្ពុទ្ធមានផៅពង្ស ដ៏ខ្ពង់ខ្ពស់ដូចជាព្រះអាទិត្យ ព្រះអង្គទ្រង់សម្ដែងហើយ។

**អចិរំ វត យំ កាយោ    បឋវឹ អធិសេស្សតិ**

**ឆុទ្ធោ អបេតវិញ្ញាណោ  និរត្ថំវ  កលិង្គរំ។**

កាយនេះ មិននៅយូរប៉ុន្មានឡើយ តែមានវិញ្ញាណ ទៅប្រាសហើយ ជាកាយគឺគេបោះបង់ចោល ក៏នឹងដេក សង្កត់នៅលើផែនដី ដូចជាអង្កត់ឧសរកប្រយោជន៍គ្មាន។

**អាយុ ឧស្មា ច វិញ្ញាណំ យទា កាយំ ជហន្តិមំ**

**អបវិដ្ឋោ តទា សេតិ    និរត្ថំវ  កលិង្គរំ។**

អាយុក្តី ភ្លើងធាតុក្តី វិញ្ញាណក្តី តែលះបង់នូវកាយ នេះទៅក្នុងកាលណាហើយ (កាយនេះ ក៏ដល់នូវសេចក្តី មិនគួរនឹងទុកដាក់ ឱ្យនៅលើផ្ទះសម្បែងបានឡើយ) គេ តែងនាំយកទៅចោល ឱ្យដេកនៅ (លើផែនដី) ក្នុងកាល

ណោះឯង ដូចជាអង្កត់ឧសរកប្រយោជន៍គ្មានឡើយ។

**យថា ទណ្ឌេន គោបាលោ គាវោ បាជេតិ គោចរំ**

**ឯវំ ជរា ច មច្ចុ ច អាយុំ បាជេន្តិ បាណិនំ**

គង្វាលគោ គៀងគោទាំងឡាយ ទៅកាន់ទីគោចរ ដោយអាជ្ញា គឺដំបង ឬរំពាត់ យ៉ាងណាមិញ ជរា គឺសេចក្តីទ្រុតទ្រោមគ្រាំគ្រា និងមច្ចុរាជ គឺសេចក្តីស្លាប់ ក៏គៀងទៅនូវអាយុរបស់សត្វទាំងឡាយ យ៉ាងនោះឯង។

## ភត្តានុមោទនាគាថា

**យថា វារិវហា បូរា បរិបូរេន្តិ សាគរំ** ផ្លូវទឹកទាំងឡាយ មានទន្លេ និងស្ទឹងជាដើមដ៏ពេញ ដែលញុំាងសាគរ គឺសមុទ្រឱ្យពេញ ព្រៀបដូចម្តេចមិញ

ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ ទានដែលទាយកទាយិកា ឧទ្ទិសឱ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់អ្នកដែលចែកស្ថានទៅកាន់បរលោក ហើយដូច្នោះឯង ឥច្ឆិតំ បត្ថិតំ តុម្ហំ ខិប្បមេវ សមិជ្ឈតុ សូមឥដ្ឋផលគឺផលជាទីគាប់ចិត្ត ដែលអ្នកប្រាថ្នាហើយតាំងចិត្ត ហើយចូរឱ្យសម្រេចដល់អ្នក ឱ្យបានឆាប់រួសរាន់ទាន់ចិត្ត។ សព្វេ បូរេន្តុ សង្កប្បា សូមតម្រិះត្រូវទាំងពួងចូរពេញ (ដល់អ្នក)។ ចន្ទោ បណ្ណរសោ យថា ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត មណិជោតិរសោ យថា (ពុំនោះសោត) ដូចកែវមណី មានរស្មីដ៏រុងរឿង ជាកែវពិសេស អាចញុំាងសេចក្តីប្រាថ្នាទាំងពួងឱ្យសម្រេចបាន។

# សាមញ្ញានុមោទនាគាថា

សព្វីតិយោ វិវជ្ជន្តុ សូមឱ្យចង្រៃទាំងពួង ទាំង-
ឡាយប្រាសចេញ គឺថា ចូរឱ្យចៀសវាងចេញឆ្ងាយទៅ
សព្វរោគោ វិនស្សតុ សូមឱ្យរោគទាំងពួង (របស់
អ្នក) ជាសះស្បើយទៅ ។

មា តេ ភវត្វន្តរាយោ អន្តរាយកុំបីមានដល់អ្នក
ឡើយ សុខី ទីឃាយុកោ ភវ សូមឱ្យអ្នកជាបុគ្គល
មានសេចក្តីសុខ មានអាយុវែង។

អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ
ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ

ធម៌គឺពរទាំងឡាយ ៤ ប្រការ គឺអាយុ ១ ពណ៌សម្បុរ-
កាយ ១ សេចក្តីសុខ ១ កម្លាំង ១ រមែងចម្រើនអស់កាល
ជានិច្ច ដល់អ្នកដែលមានសេចក្តីឱនកាយថ្វាយបង្គំ ដល់

ព្រះរតនត្រ័យជាប្រក្រតី និងអ្នកដែលមានសេចក្តីគោរពកោតក្រែងដល់បុគ្គល ដែលជាអ្នកមានសេចក្តីចម្រើនដោយគុណមានសីលគុណជាដើម ឬដែលចម្រើនដោយវ័យ គឺចាស់ព្រឹទ្ធាចារ្យ។

## ចប់ធម៌សូត្រម៉ោង ៩ ព្រឹក

"សូម្បីបុគ្គលអាចយកជ័យជំនះលើមនុស្សបានរាប់ពាន់នាក់ ក្នុងសង្គ្រាមរាប់ពាន់ដងក៏ដោយ ក៏មិនប្រសើរជាងការឈ្នះលើខ្លួនឯង តែម្នាក់ឡើយ។

បុគ្គលអ្នកឈ្នះខ្លួនឯង ឈ្មោះថា ជាអ្នកឈ្នះសង្គ្រាមដ៏ប្រសើរបំផុត"។

"ចិត្តជាធម្មជាតិបរិសុទ្ធ ផូរផង់ពីកំណើត តែចិត្តនេះ

កាលណាបើមានឧបក្កិលេសថ្មីចូលទៅ ទើបសៅហ្មង "។

"ចិត្តេន នីយតិ លោកោ សត្វលោកត្រូវចិត្តដឹកនាំ "។

"គឺចិត្តនេះហើយ ដែលបុគ្គលទូន្មានបានដោយកម្រ "។

**រូបំ ជិរតិ មច្ចានំ នាមគោត្តំ ន ជិរតិ**

រូបកាយរលត់រលាយទៅ កេរ្តិ៍ឈ្មោះគង់នៅឥតរសាយ
ល្អឬអាក្រក់ឮវែងឆ្ងាយ គួរស្តាយខំសាងអំពើល្អ...

# ធម៌សូត្រម៉ោង ២ ថ្ងៃ

១.សគ្គេ កាមេ...
២.ឥមេហិ ទីបធូបា...
៣.នមោ តស្ស...
៤.យោ សន្និសិន្នោ...
៥.ពុទ្ធំ ជីវិតំ...
៦.យេ ច ពុទ្ធា...
៧.ឥតិបិសោ ភគវា...
៨.នត្ថិ មេ សរណំ...
៩.ឧត្តមង្គេន...
១០.អដ្ឋង្គិការិយបថោ...
១១.ធម្មំ ជីវិតំ...
១២.យេ ច ធម្មា...
១៣.ស្វាក្ខាតោ...
១៤.នត្ថិ មេ សរណំ...
១៥.ឧត្តមង្គេន...
១៦.សង្ឃោ វិសុទ្ធោ...
១៧.សង្ឃំ ជីវិតំ+ភវតុ សព្វមង្គលំ +នក្ខត្តយក្ខតានំ...
១៨.យេ ច សង្ឃា...
១៩.សុបដិបន្នោ ភគវតោ...
២០.នត្ថិ មេ សរណំ...
២១.ឧត្តមង្គេន...
២២.កែវមួយ គឺព្រះពុទ្ធ...
២៣.វន្ទាមិ ចេតិយំ...
២៤.វន្ទាមិ ពុទ្ធំ...
២៥.យោ កប្បកោដី...
២៦.ឥច្ចេវ មច្ចន្ត...
២៧.ពុទ្ធំ សរណំ គច្ឆាមិ...
២៨.សម្ពុទ្ធេ...
២៩.យេ សន្តា...
៣០.ឯវម្មេ សុតំ...
៣១.មហាមេត្រី...
៣២.បណិធាន...
៣៣.យានី...
៣៤.ឥតិបិសោ+ស្វាក្ខាតោ+
សុបដិបន្នោ + យន្ទុន្និមិត្តំ...
៣៥.មហាការុណិកោ...
៣៦.សោ អត្ថលទ្ធោ + សា អត្ថលទ្ធា
+តេ អត្ថលទ្ធា+ សក្កត្វា...
៣៧.សព្វពុទ្ធា...
៣៨.យថាវារិវហា...
៣៩.ហោតុ សព្វំ...
៤០.ឥទំ វត នោ...
៤១.យំ កិញ្ចិ...

# អញ្ជើញពួកទេវតា

សគ្គេ កាមេ ច រូបេ គិរិសិខរតដេ ចន្តលិក្ខេ វិមានេ ទីបេ រដ្ឋេ ច គាមេ តរុវនគហនេ គេហវត្ថុម្ហិ ខេត្តេ ភុម្មា ចាយន្តុ ទេវា ជលថល-វិសមេ យក្ខគន្ធព្វនាគា តិដ្ឋន្តា សន្តិកេ យំ មុនិវរវចនំ សាធវោ មេ សុណន្តុ។

ប្រែថា: ទេវតាទាំងឡាយដែលស្ថិតនៅក្នុងឋានសួគ៌ដែលជាកាមភព និងរូបភពក្តី ភុម្មទេវតាទាំងឡាយដែលឋិតនៅក្នុងទិព្វវិមាន គឺលើកំពូលភ្នំ ឬភ្នំដែលដាច់ក្តី ព្ធដ៏អាកាសក្តី នៅនាកោះ និងដែន និងស្រុកក្តី នៅនាដើមព្រឹក្សា និងព្រៃញាតស្បាត ឬទីស្រែចំការក្តី យក្ខនិងគន្ធព្វ និងនាគទាំងឡាយ ដែលស្ថិតនៅនាទីទឹក ទីគោក ឬទីមិនរាបស្មើ ដែលនៅក្នុងទីជិតនេះក្តី សូម

អញ្ជើញមកប្រជុំគ្នា (ក្នុងទីនេះ) ពាក្យឯណា ដែលជាពាក្យព្រះសាក្យមុនីដ៏ប្រសើរ (ដែលយើងខ្ញុំនឹងសូត្រឥឡូវនេះ) លោកអ្នកសប្បុរសទាំងឡាយ ចូរស្តាប់នូវពាក្យនោះ (អំពីសំណាក់) នៃខ្ញុំដោយគោរព។

ធម្មស្សវនកាលោ អយម្ភទន្តា បពិត្រលោកអ្នកដ៏ចម្រើនទាំងឡាយ ពេលនេះ ជាពេលគួរនឹងស្តាប់នូវព្រះធម៌។

ធម្មស្សវនកាលោ អយម្ភទន្តា បពិត្រលោកអ្នកដ៏ចម្រើនទាំងឡាយ ពេលនេះ ជាពេលគួរនឹងស្តាប់នូវព្រះធម៌។

ធម្មស្សវនកាលោ អយម្ភទន្តា បពិត្រលោកអ្នកដ៏ចម្រើនទាំងឡាយ ពេលនេះ ជាពេលគួរនឹងស្តាប់នូវព្រះធម៌។

# សម្ពុទ្ធេ

សម្ពុទ្ធេ អដ្ឋវីសញ្ច ទ្វាទសញ្ច សហស្សកេ

បញ្ចសតសហស្សានិ នមាមិ សិរសា អហំ

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ២៨ ព្រះអង្គផង ១ ម៉ឺន ២ ពាន់ព្រះអង្គផង ៥ សែនព្រះអង្គផង ដោយត្បូង (របស់ខ្ញុំព្រះករុណា)។

តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះដោយគោរព។

នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ

អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ

ដោយអានុភាពនៃកិរិយា នមស្ការថ្វាយបង្គំ សូម

ឱ្យកំចាត់បង់នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្តីអន្តរាយទាំងឡាយជាអនេក ក៏ចូរឱ្យវិនាសទៅ កុំបីមានសេសសល់ឡើយ។

**សម្ពុទ្ធេ បញ្ចបញ្ញាសញ្ច  ចតុវីសតិសហស្សកេ**
**ទសសតសហស្សានិ  នមាមិ សិរសា អហំ**

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ៥៥ ព្រះអង្គផង ២ ម៉ឺន ៤ពាន់ព្រះអង្គផង ១ លានព្រះអង្គផង ដោយត្បូង (របស់ខ្ញុំព្រះករុណា)។

**តេសំ ធម្មញ្ច សង្ឃញ្ច  អាទរេន នមាមិហំ**

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះដោយគោរព។

**នមក្ការានុភាវេន  ហន្ត្វា សព្វេ ឧបទ្ទវេ**

អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ

ដោយអានុភាពនៃកិរិយា នមស្ការថ្វាយបង្គំ សូមឱ្យកំចាត់បង់នូវឧបទ្រព្យទាំងឡាយទាំងពួង ទាំងសេចក្តីអន្តរាយទាំងឡាយ ជាអនេក ក៏ចូរឱ្យវិនាសទៅ កុំបីមានសេសសល់ឡើយ។

សម្ពុទ្ធេ នវុត្តរសតេ អដ្ឋចត្តាឡីសសហស្សកេ វីសតិសតសហស្សានិ នមាមិ សិរសា អហំ

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ១០៩ ព្រះអង្គផង ៤ ម៉ឺន ៨ ពាន់ព្រះអង្គផង ២ លានព្រះអង្គផង ដោយត្បូង (របស់ខ្ញុំព្រះករុណា)។

តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ

ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ

ដោយគោរព។

នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ
អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ

ដោយអានុភាពនៃកិរិយានមស្ការថ្វាយបង្គំ សូមឱ្យកំចាត់បង់នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្តីអន្តរាយទាំងឡាយជាអនេក ក៏ចូរឱ្យវិនាសទៅ កុំបីមានសេសសល់ឡើយ។

---

ទីឃា ជាគរតោ រត្តិ រាត្រីវែងចំពោះតែអ្នកភ្ញាក់រលឹក(អ្នកដេកមិនលក់)។
ទីឃំ សន្តស្ស យោជនំ យោជន៍វែងចំពោះតែអ្នកនឿយហត់។
ទីឃោ ពាលានំ សំសារោ សទ្ធម្មំ អវិជានតំ សង្សារវដ្តវែងចំពោះតែបុគ្គលពាល មិនដឹងច្បាស់នូវធម៌របស់សប្បុរស។

# ធ្វារពួមង្គលសូត្រ

យេ សន្តា សន្តចិត្តា តិសរណសរណា ឯត្ថ លោកន្តរេ វា ភុម្មា ភុម្មា ច ទេវា គុណគណគ-ហណព្យាវដា សព្វកាលំ ទេវតាទាំងឡាយឯណា ជាភុម្មទេវតាក្តី មិនមែនជាភុម្មទេវតាក្តី ជាអ្នកមានចិត្តស្ងប់ មានព្រះរតនត្រ័យជាទីពឹងទីរឮក ដែលមាននៅក្នុងលោកនេះ ឬក្នុងចន្លោះនៃលោក ជាអ្នកខ្វល់-ខ្វាយក្នុងកិរិយាកាន់យកនូវពពួកនៃគុណសព្វៗកាល។

ឯតេ អាយន្តុ ទេវា វរកនកមយេ មេរុរាជេ វសន្តោ សន្តោ សន្តោ សហេតុំ មុនិវរវចនំ សោតុមគ្គំ សមគ្គំ សូមទេវតាទាំងឡាយនោះ អញ្ជើញមក ម្យ៉ាងទៀត ទេវតាដែលស្ថិតនៅលើភ្នំមេរុរាជសុទ្ធសឹងតែមាសដ៏ប្រសើរ សូមអញ្ជើញមកផង សូមទេវតា

ជាសប្បុរសទាំងឡាយ អញ្ជើញមកកាន់ទីសមាគម ដើម្បីស្តាប់នូវពាក្យនៃព្រះមុនីដ៏បវរ ជាធម៌ដ៏ប្រសើរលើសជាហេតុនាំឱ្យកើតសេចក្តីត្រេកអរ។

សព្វេសុ ចក្កវាឡេសុ យក្ខា ទេវា ច ព្រហ្ម-នោ យំ អម្ហេហិ កតំ បុញ្ញំ សព្វសម្បត្តិ សាធកំ

បុណ្យឯណាដែលយើងបានធ្វើហើយ ជាបុណ្យអាចឱ្យសម្រេចនូវសម្បត្តិទាំងពួង សូមយក្ខទាំងឡាយផងទេវតាទាំងឡាយផង ព្រហ្មទាំងឡាយផង ក្នុងចក្រ-វាឡទាំងអស់ (អនុមោទនាត្រេកអរនឹងបុណ្យនោះ)។

សព្វេ តំ អនុមោទិត្វា សមគ្គា សាសនេ រតា

បមាទរហិតា ហោន្តុ អារក្ខាសុ វិសេសតោ

យក្ខ និងទេវតា និងព្រហ្មទាំងអស់ កាលបើបានអនុមោទនានូវបុណ្យនោះហើយ ចូរព្រមព្រៀងគ្នា

ត្រេកអរក្នុងព្រះពុទ្ធសាសនា ហើយចូរប្រាសចាក សេចក្តីប្រហែសធ្វេសក្នុងការរក្សា (នូវព្រះពុទ្ធសាសនា) ដោយឧបាយដ៏វិសេស។

សាសនស្ស ច លោកស្ស វុឌ្ឍី ភវតុ សព្វទា

សាសនម្បិ ច លោកញ្ច ទេវា រក្ខន្តុ សព្វទា

សូមឱ្យសេចក្តីចម្រើន កើតមានដល់ព្រះពុទ្ធសាសនា ផង ដល់សត្វលោកផង ឱ្យបានសព្វៗ កាលទៅ សូម ទេវតាទាំងឡាយ អភិបាលរក្សានូវព្រះពុទ្ធសាសនាផង នូវសត្វលោកផង ឱ្យបានសព្វៗ កាល រៀងទៅ។

សទ្ធី ហោន្តុ សុខី សព្វេ បរិវារេហិ អត្តនោ

អនីឃា សុមនា ហោន្តុ សហ សព្វេហិ ញាតីភិ

សព្វសត្វទាំងអស់ ព្រមទាំងបរិវារទាំងឡាយរបស់ខ្លួន សូមឱ្យមានសេចក្តីសុខស្រួល សូមឱ្យជាអ្នកឥតមាន

សេចក្តីទុក្ខភ័យ ជាអ្នកមានចិត្តល្អ ព្រមទាំងជនជាញាតិសន្តានទាំងអស់គ្នា។

យញ្ច ទ្វាទស វស្សានិ ចិន្តយឹសុ សទេវកា
ចិរស្សំ ចិន្តយន្តាបិ នេវ ជានឹសុ មង្គលំ
ចក្កវាឡសហស្សេសុ ទសសុ យេន តត្តកំ
កាលំ កោលាហលំ ជាតំ យាវ ព្រហ្មនិវេសនា

មនុស្សព្រមទាំងទេវតាទាំងឡាយ បាននាំគ្នាគិតរកនូវមង្គលឯណា អស់ ១២ ឆ្នាំ មនុស្ស និងទេវតាទាំងនោះក្នុង ១ ម៉ឺនចក្រវាឡ ទោះខំប្រឹងគិតអស់កាលយូរ ម្ល៉ោះក៏នៅតែមិនដឹងនូវមង្គលនោះត្រឹមណា វីកោលាហលក៏កើតរហូតដល់ភពជាទីនៅនៃព្រហ្ម អស់កាលត្រឹមណោះឯង។

យំ លោកនាថោ ទេសេសិ សព្វបាបវិនាសនំ
យំ សុត្វា សព្វទុក្ខេហិ មុញ្ចន្តា សំខិយា នរា

ឯវមាទិគុណូបេតំ មង្គលន្តម្ភណាម ហេ

ព្រះបរមលោកនាថ ទ្រង់ត្រាស់សម្តែងហើយនូវ មង្គលឯណា ដែលជាគ្រឿងញុាំងបាបទាំងពួងឱ្យវិនាស នរជនទាំងឡាយ រាប់ចំនួនមិនបាន ស្តាប់នូវមង្គល ឯណាហើយ បានរួចចាកទុក្ខទាំងពួង ម្នាលទេវតា ទាំងឡាយ យើងពោលឥឡូវនេះ នូវមង្គលនោះ ដ៏ ប្រកបដោយគុណមានយ៉ាងនេះជាដើម។

## មង្គលសូត្រ

ឯវម្មេ សុតំ (សូត្រនេះឈ្មោះមង្គលសូត្រ) គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្តាប់មកហើយយ៉ាងនេះថា

ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ សម័យមួយ

ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាម របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។

**អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ** លំដាប់នោះឯង ទេវតា អង្គ ១ កាលដែលវេលារាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏ល្អ ញុំាងវត្តជេតពនជុំវិញទាំងអស់ ឱ្យភ្លឺស្វាង ហើយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងទីណា ក៏ចូលទៅ ក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំចំពោះ អង្គព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ។

**ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ** កាលទេវតានោះ ឈរក្នុងទីដ៏

សមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគ ដោយពាក្យជាគាថា (យ៉ាងនេះ) ថាៈ

ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ
អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ។

ទេវតា និងមនុស្សទាំងឡាយជាច្រើន ប្រាថ្នានូវសិរីសួស្តី បានគិតរកនូវមង្គលទាំងឡាយ សូមព្រះអង្គទ្រង់ព្រះមេត្តាសម្តែងប្រាប់នូវមង្គលដ៏ឧត្តម (ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងតបពាក្យទេវតានោះ ដោយពុទ្ធភាសិតជាគាថាយ៉ាងនេះ) ថាៈ

អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា
បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ។

កិរិយាមិនសេពគប់ នូវបុគ្គលពាលទាំងឡាយ ១ កិរិយាសេពគប់នូវបុគ្គល ជាបណ្ឌិតទាំងឡាយ ១

កិរិយាបូជាដល់បុគ្គល ដែលគួរបូជាទាំងឡាយ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម។

បដិរូបទេសវាសោ ច បុព្វេ ច កតបុញ្ញតា

អត្តសម្មាបណីធិ ច ឯតម្មង្គលមុត្តមំ

កិរិយានៅក្នុងប្រទេសដ៏សមគួរ ១ ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន ១ កិរិយាតម្កល់ខ្លួនដោយប្រពៃ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម។

ពាហុសច្ចញ្ច សិប្បញ្ច វិនយោ ច សុសិក្ខិតោ

សុភាសិតា ច យា វាចា ឯតម្មង្គលមុត្តមំ

ភាវៈនៃបុគ្គលបានស្តាប់ បានរៀនហើយ ដោយច្រើន ១ សិល្ប៍សាស្ត្រ គឺសេចក្តីឆ្លៀវឆ្លាសក្នុងហត្ថ-កម្មរបស់អ្នកបួស និងគ្រហស្ថ ១ វិន័យដែលបុគ្គលសិក្សាដោយប្រពៃ ១ វាចាដែលបុគ្គលពោលត្រឹមត្រូវ ១

ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម។

មាតាបិតុឧបដ្ឋានំ  បុត្តទារស្ស សង្គហោ
អនាកុលា ច កម្មន្តា  ឯតម្មង្គលមុត្តមំ

កិរិយាបំរើនូវមាតា ១ កិរិយាបំរើនូវបិតា ១ សេចក្តីសង្គ្រោះដល់បុត្រ និងភរិយា ១ ការងារទាំងឡាយដែលមិនច្របូកច្របល់ ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម។

ទានញ្ច ធម្មចរិយា ច ញាតកានញ្ច សង្គហោ
អនវជ្ជានិ កម្មានិ  ឯតម្មង្គលមុត្តមំ។

កិរិយាបរិច្ចាគទាន១ កិរិយាប្រព្រឹត្តិនូវធម៌ ១ សេចក្តីសង្គ្រោះដល់ញាតិទាំងឡាយ ១ ការងារទាំងឡាយដែលមិនមានទោស ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម។

អារតី វិរតី បាបា  មជ្ជបានា ច សញ្ញមោ
អប្បមាទោ ច ធម្មេសុ ឯតម្មង្គលមុត្តមំ។

កិរិយាមិនត្រេកអរក្នុងបាប និងកិរិយាវៀរចាកបាប ១ សេចក្តីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង ១ សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម។

គារវោ ច និវាតោ ច សន្តុដ្ឋី ច កតញ្ញុតា
កាលេន ធម្មស្សវនំ ឯតម្មង្គលមុត្តមំ។

សេចក្តីគោរពចំពោះបុគ្គល ដែលគួរគោរព ១ កិរិយាប្រព្រឹត្តបន្ទាបនូវខ្លួន ១ សេចក្តីត្រេកអរចំពោះរបស់ដែលមាន ១ ភាវៈនៃបុគ្គលអ្នកដឹងនូវឧបការៈដែលអ្នកដទៃធ្វើហើយដល់ខ្លួន ១ កិរិយាស្តាប់នូវធម៌តាមកាល ១ ទាំង ៥ នេះ ជាមង្គលដ៏ឧត្តម។

ខន្តិ ច សោវចស្សតា សមណានញ្ច ទស្សនំ
កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ។

សេចក្ដីអត់ធន់ ១ ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ ១ កិរិយាបានឃើញបានជួបនូវសមណៈទាំងឡាយ ១ ធម្មសាកច្ឆា គឺកិរិយាសន្ទនាទៅវិញទៅមកនូវធម៌តាមកាល ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្ដម។

តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចាន ទស្សនំ
និព្វានសច្ឆិកិរិយា ច ឯតម្មង្គលមុត្តមំ។

សេចក្ដីព្យាយាមដុតនូវបាបធម៌ ១ កិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ១ កិរិយាឃើញនូវអរិយសច្ចទាំងឡាយ១ កិរិយាធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្ដម។

ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ
អសោកំ វិរជំ ខេមំ ឯតម្មង្គលមុត្តមំ

ចិត្តនៃបុគ្គលឯណា ដែលលោកធម៌ទាំងឡាយពាល់

ត្រូវហើយ មិនរំភើបញាប់ញ័រ ១ មិនមានសេចក្តីសោក ១ មានធូលី គឺរាគៈទៅប្រាសហើយ ១ ជាចិត្តក្សេមក្សាន្ត ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម។

**ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា សព្វត្ថ សោត្ថឹ គច្ឆន្តិ តន្តេសំ មង្គលមុត្តមន្តិ។**

ទេវតា និងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយ ប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង តែងដល់នូវសិរីសួស្តីក្នុងទីទាំងពួង (ម្នាលទេវតា អ្នកចូរប្រកាន់ជឿថា) មង្គលទាំង ៣៨ ប្រការ មានកិរិយាមិនសេពគប់ នូវបុគ្គលពាលជាដើមនោះ របស់ទេវតា និងមនុស្សទាំងអម្បាលនោះ ជាមង្គលដ៏ឧត្តម។

# មហាមេត្រី

មេត្តិសុត្តំ រតនញ្ច ខន្ធា តានាតាយំ តថា-
ធុជគ្គំ អង្គុលិមាលញ្ច ទិសាបាលញ្ច សត្តមំ
អដ្ឋវីសតិពុទ្ធញ្ច បរិត្តំ អដ្ឋមង្គលំ សេយ្យថីទំ
ឯកាទសមុត្តិវុត្តំ មារវិជញ្ច សាខញ្ច ធារណី
គិរិមានន្ទំ មោគ្គល្លានញ្ច ចុន្ទញ្ច កស្សបំ មារា-
ខានុត្តត្ថាយ សុរិយំ ចន្ទញ្ចេវ ឆទ្ទន្តំ វេទជាដកំ
រាហុលញ្ច បរិត្តានិ សិរសានិ ច លោកានញ្ច
ហិតត្ថាយ អត្តនោ សាវកា សច្ចមាតាបិតុរស្ស
សព្វានិ ចតុវីសានិ ពុទ្ធេនេវ បកាសិតា អត្ថាយ
ហិតាយ សុខាយ សព្វលោកស្សាតិ។

ឥមេ មាតាបិតរោ បរលោកំ គន្ត្វា ឥធ

សាសនេ ឥមស្ស មាតាបិតុរស្ស អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ។

ឥមេ ភគនិយោ ញាតិកា ពន្ធុវកុសលហា-យិកា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ។

ឥមេ រាជានោ ទេវាធិបតិ ទេវា សហបុត្តទារា សហអមច្ចា សហបរិវារា ជនា សហសេនាបតិ

សហពលពាហនា សហទាសាទាសី ហត្ថី អស្សគោណោ មហិង្សាទយោ បរិហរន្តុ។

ឥមស្មឹ គាមេ វា រាជធានិយោ វា អរញ្ញេសុ វា ច សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ។

ឥមេ មនុស្សា ច រត្តិន្ទិវញ្ច ឥត្ថី វា បុរិសោ វា កុមារោ វា កុមារី វា យេ ច ទហរា យេ ច មជ្ឈិមបុរិសា យេ ច វុឌ្ឍា យេ ច ទលិទ្ទា យេ ច សមិទ្ធា យេ ច ពាលា យេ ច បណ្ឌិតា យេ ច សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ

និទ្ទុក្ខា ហោន្តុ អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ អយំ សុរិយោ ច អយំ ចន្ទោ ច ពារនោ ច នាគោ ច ភារទ្វាជោ ច សុបណ្ណោ ច សហស្សទេវា មហិទ្ធិកា មហានុភាវា ច សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ អព្យា-បជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ។

ឥមេ ចាតុម្មហារាជិកា ទេវា តាវត្តិង្សា ទេវា យាមា ទេវា តុសិតា ទេវា និម្មានរតី ទេវា

បរនិម្មិតវសវត្តី ទេវា យាវ ព្រហ្មលោកា ព្រហ្ម-
បារិសជ្ជា ព្រហ្មបរោហិតា មហាព្រហ្មា បរិត្តាភា
អប្បមាណាភា អាភស្សរា បរិត្តសុភា អប្ប-
មាណសុភា សុភកិណ្ហកា វេហប្ផលា អសញ្ញិ-
សត្តា អវិហា អតប្បា សុទស្សា សុទស្សី
អកនិដ្ឋកា អាកាសានញ្ចាយតនំ វិញ្ញាណញ្ចា-
យតនំ អាកិញ្ចញ្ញាយតនំ នេវសញ្ញានាសញ្ញា-
យតនំ មហាព្រហ្មសង្ខារា បថវីតលតោ យាវ
ភវគសមន្តតោ ច អរិជហិត្វា យាវ សុចក្ក-
វាឡេសុ បរិយន្តា ឥតរា សព្វេ សត្តា អបាទា វា
ទ្វេ បាទា វា ចតុប្បាទា វា ពហុប្បាទា វា បក្ខិ-
មេហិ វា ជលេហិ វា ថលេហិ វា អន្តលិក្ខេហិ

វា ច សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ។

ឥមេ និរយេ អដ្ឋនិរយេសុ សញ្ជិវេសុ កាលសុ តេសុ សំឃាតេសុ រោរវេសុ មហា-រោរវេសុ តាបណេសុ មហាតាបណេសុ អវិចីសុ មហាអវិចីសុ លោហកុម្ភីសុ មហាលោហកុម្ភីសុ សិម្ពលីរុក្ខេ វា ខារណុទេវា អង្គារបព្វតេ វា អយំ មហាបថវី យាវ សោឡស មហានិរយេសុ សព្វេ តេ និរយេសុ សត្តា លោកន្តរនិរយេសុ សត្តា កាយកាមេន វា ឧប្បតោ បេតោ

អលេនតោ អសុរិណ្ណភូតោ មម បញ្ញានុភាវេន មម មេត្តានុភាវេន មម ករុណានុភាវេន មម មុទិតានុភាវេន មម ឧបេក្ខានុភាវេន សព្វេ តេ និរយកសត្តានំ អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ។ មេត្តិបរិត្តំ និដ្ឋិតំ។

## ព្រះរតនសូត្រ

បណិធានតោ បដ្ឋាយ តថាគតស្ស ទស បារមិយោ ទស ឧបបារមិយោ ទស បរមត្ថ-បារមិយោ បញ្ច មហាបរិច្ចាគេ តិស្សោ ចរិយា

បច្ឆិមព្ភវេ គព្ភាវក្កន្តឹ ជាតឹ អភិនិក្ខមនំ បធាន-ចរិយំ ពោធិបល្លង្កេ មារវិជយំ សព្វញ្ញុ-តញ្ញាណប្បដិវេធំ នវលោកុត្តរធម្មេតិ សព្វេបិមេ ពុទ្ធគុណេ អាវជ្ជិត្វា វេសាលិយា តីសុ បាការន្តរេសុ តិយាមរត្តឹ បរិត្តំ ករោន្តោ អាយស្មា អានន្ទត្ថេរោ វិយ ការុញ្ញចិត្តំ ឧបដ្ឋបេត្វា។

យើងទាំងឡាយតាំងចិត្ត ប្រកបដោយសេចក្តីករុណា (ចំពោះសត្វទាំងឡាយ) ដូចជាព្រះអានន្ទត្ថេរដ៏មានអាយុ ដែលលោកពិចារណា នូវព្រះពុទ្ធគុណទាំងឡាយនេះ គ្រប់ទាំងអស់ របស់ព្រះតថាគត ចាប់ដើមអំពីសេចក្តីផ្តើមតាំងប្រាថ្នាជាព្រះពុទ្ធមក គឺបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ មហាបរិច្ចាគ ៥ ចរិយា ៣ កិរិយាយាងចុះកាន់គភ៌នៃព្រះមាតា ក្នុង

បច្ឆិមភព កិរិយាប្រសូតិ កិរិយាយាងចេញសាងអភិ-
នេស្រ្កម កិរិយាបំពេញនូវទុក្ករកិរិយា កិរិយាផ្ចាញ់មារ
កិរិយាត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ លើពោធិបល្ល័ង្ក
លោកុត្តរធម៌ ៩ ហើយ (ព្រះអានន្ទត្ថេរលោក) សូត្រ
នូវព្រះបរិត្តអស់រាត្រីមានយាម ៣ ក្នុងខាងក្នុងកំពែង
ទាំងឡាយ ៣ ជាន់នៃក្រុងវេសាលី។

កោដិសតសហស្សេសុ ចក្កវាឡេសុ ទេវតា
យស្សាណម្បដិគ្គណ្ហន្តិ យញ្ច វេសាលិយម្បុរេ
រោគាមនុស្សទុព្ភិក្ខសម្ភូតន្តិវិធម្ភយំ ខិប្បមន្តរ-
ធាបេសិ បរិត្តន្តម្ភណាម ហេ ទេវតាទាំងឡាយ
ក្នុងសែនកោដិចក្រវាឡតែងទទួលយកនូវអាជ្ញានៃព្រះ
បរិត្តឯណា ម្យ៉ាងទៀត ព្រះបរិត្តឯណាញុំាងភ័យ ៣
ប្រការដែលកើតអំពីរោគ និងអមនុស្ស និងទុព្ភិក្ស គឺគ្រា

អំណត់ក្នុងក្រុងវេសាលី ឱ្យអន្តរធានបាត់ទៅ ដោយឆាប់រហ័ស ម្នាលទេវតាទាំងឡាយ យើងសូត្រឥឡូវនេះនូវព្រះបរិត្តនោះ។

# រតនសូត្រ

យានីធ ភូតានិ សមាគតានិ ភុម្មានិ វា យានិវ អន្តលិក្ខេ ពួកភូតឯណា ជាទេវតាស្ថិតនៅលើផែនដីក្តី ពួកភូតឯណា ជាទេវតាស្ថិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ សព្វេវ ភូតា សុមនា ភវន្តុ សូមពួកភូតទាំងអស់នោះមានចិត្តល្អ អថោបិ សក្កច្ច សុណន្តុ ភាសិតំ ម្យ៉ាងទៀត ចូរស្តាប់នូវភាសិតដោយគោរព តស្មា ហិ ភូតានិ សាមេថ សព្វេ មេត្តំ ករោថ មានុសិយា បជាយ ព្រោះ

ហេតុនោះ អ្នកទាំងឡាយជាភូតទាំងអស់ ចូរស្តាប់នូវព្រះបរិត្ត ចូរធ្វើនូវមេត្តាចិត្ត ចំពោះពពួកសត្វ ជាមនុស្សជាតិ ទិវា ច រត្តោ ច ហរន្តិ យេ ពលឹ មនុស្សទាំងឡាយឯណា តែងនាំមកនូវពលិកម្ម ក្នុងពេលថ្ងៃ និងពេលយប់ តស្មា ហិ នេ រក្ខថ អប្ប-មត្តា ព្រោះហេតុនោះ សូមអ្នកទាំងឡាយ កុំមើលបំណាំឡើយ សូមរក្សានូវមនុស្សទាំងឡាយនោះ។

យំ កិញ្ចិ វិត្តំ ឥធ វា ហុរំ វា សគ្គេសុ វា យំ រតនំ បណីតំ ទ្រព្យឯណាមួយក្នុងលោកនេះ និងក្នុងលោកឯទៀតក្តី រតនវត្ថុដ៏ឧត្តមឯណាក្នុងឋានសួគ៌ក្តី ននោ សមំ អត្ថិ តថាគតេន ទ្រព្យ និងរតនវត្ថុទាំងនោះ ស្មើដោយព្រះតថាគតមិនមានឡើយ ឥទម្បិ ពុទ្ធេ រតនំ បណីតំ កែវគឺព្រះពុទ្ធនេះឯង ជាកែវដ៏ឧត្តម

ឯតេន សច្ចេន សុវត្ថិ ហោតុ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ខយំ វិរាគំ អមតំ បណីតំ យទជ្ឈគា សក្យមុនី សមាហិតោ ព្រះសក្យមុនីជាម្ចាស់ មានព្រះទ័យតម្កល់មាំ បានត្រាស់ដឹងហើយនូវព្រះធម៌ឯណា ជាទីក្ស័យនៃកិលេស ជាទីប្រាសចាករាគៈ ជាធម៌មិនស្លាប់ ជាធម៌ដ៏ឧត្តម។ ន តេន ធម្មេន សមត្ថិ កិញ្ចិ របស់អ្វីមួយស្មើដោយព្រះធម៌នោះ មិនមានឡើយ ឥទម្បិ ធម្មេ រតនំ បណីតំ កែវគឺព្រះធម៌នេះឯង ជាកែវដ៏ឧត្តម។ ឯតេន សច្ចេន សុវត្ថិ ហោតុ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។

យម្ពុទ្ធសេដ្ឋោ បរិវណ្ណយី សុចឹ ព្រះពុទ្ធដ៏ប្រសើរទ្រង់សរសើរនូវសមាធិឯណាថាជាធម៌ដ៏ស្អាត

សមាធិមានន្តរិកញ្ញមាហុ បណ្ឌិតទាំងឡាយពោល ហើយនូវសមាធិឯណាថាជាធម៌ឱ្យផលដោយលំដាប់ ។ សមាធិនា តេន សមោ ន វិជ្ជតិ សមាធិឯទៀត ស្មើដោយសមាធិនោះមិនមានឡើយ។

ឥទម្បិ ធម្មេ រតនំ បណីតំ កែវគឺព្រះធម៌នេះ ឯង ជាកែវដ៏ឧត្តម ឯតេន សច្ចេន សុវត្ថិ ហោតុ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។

យេ បុគ្គលា អដ្ឋ សតំ បសដ្ឋា ចត្តារិ ឯតានិ យុគានិ ហោន្តិ បុគ្គលទាំងឡាយឯណា ៨ ជំពូក ដែលសប្បុរសទាំងឡាយសរសើរហើយ បើរាប់ជាគូ បាន ៤ គូ តេ ទក្ខិណេយ្យា សុគតស្ស សាវកា បុគ្គលទាំងឡាយនោះ ជាសាវ័ករបស់ព្រះសុគត លោក គួរដល់នូវទក្ខិណាទាន។ ឯតេសុ ទិន្នានិ មហប្ផ-

លានិ ទានទាំងឡាយ ដែលបុគ្គលឱ្យហើយ ដល់ទក្ខិណេយ្យបុគ្គលទាំងឡាយនោះ ជាទានមានផលច្រើន។

ឥទម្បិ សង្ឃេ រតនំ បណីតំ កែវគឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម ឯតេន សច្ចេន សុវត្ថិ ហោតុ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។

យេ សុប្បយុត្តា មនសា ទឡ្ហេន និក្កាមិនោ គោតមសាសនម្ហិ អរិយបុគ្គលទាំងឡាយឯណា ក្នុងសាសនានៃព្រះសម្ពុទ្ធទ្រង់ព្រះនាមគោតម ប្រកបត្រូវល្អហើយ មានចិត្តខ្ជាប់ខ្ជួន ឥតមានកាម គឺសេចក្តីប្រាថ្នាឡើយ។

តេ បត្តិបត្តា អមតំ វិគយ្ហ លទ្ធា មុធា និព្វុតឹ ភុញ្ជមានា អរិយបុគ្គលទាំងឡាយនោះដល់ហើយនូវ

ព្រះអរហត្តផល ហើយចូរទៅកាន់ព្រះនិព្វាន បាននូវកិរិយារលត់កិលេសដោយទទេ គឺឥតមានទិញដូរឡើយ ហើយសោយនូវផល។

ឥទម្បិ សង្ឃេ រតនំ បណីតំ កែវគឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម។ ឯតេន សច្ចេន សុវត្ថិ ហោតុ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្ដីកើតមាន។

យថិន្ទខីលោ បថវិសិតោ សិយា ចតុព្ភិវាៈតេភិ អសម្បកម្បិយោ សរសរខឿនដែលគេបោះភ្ជាប់នឹងផែនដី ជារបស់មិនកម្រើកញាប់ញ័រ ដោយខ្យល់ព្យុះ ដែលបក់មកអំពីទិសទាំង ៤យ៉ាងណាមិញ។

តថូបមំ សប្បុរិសំ វទាមិ យោ អរិយសច្ចានិ អវេច្ច បស្សតិ អ្នកណាពិចារណាឃើញនូវអរិយសច្ចៈទាំងឡាយ តថាគតហៅអ្នកនោះថា ជាសប្បុរស (មិន

ញាប់ញ័រ ដោយលោកធម៌ទាំងឡាយ) ប្រៀបដូចជាសសរខឿនដូច្នោះឯង។

ឥទម្បិ សង្ឃេ រតនំ បណីតំ កែវគឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម។ ឯតេន សច្ចេន សុវត្ថិហោតុ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។

យេ អរិយសច្ចានិ វិភាវយន្តិ គម្ភីរបញ្ញេនសុទេសិតានិ អរិយបុគ្គលទាំងឡាយឯណា ធ្វើឱ្យជាក់ច្បាស់នូវអរិយសច្ចៈទាំងឡាយ ដែលព្រះតថាគតព្រះអង្គមានប្រាជ្ញាដ៏ជ្រាលជ្រៅសំដែងល្អហើយ។

កិញ្ចាបិ តេ ហោន្តិ ភុសប្បមត្តា អរិយបុគ្គលទាំងឡាយនោះ ទុកជាប្រមាទដ៏លើសលន់ក៏ដោយ។

ន តេ ភវំ អដ្ឋមមាទិយន្តិ អរិយបុគ្គលទាំងឡាយនោះ គង់មិនកាន់យកនូវភពជាគំរប់ ៨ គឺមិន

កើតទៀតហួសពី ៧ ជាតិឡើយ។

ឥទម្បិ សង្ឃេ រតនំ បណីតំ កែវគឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្ដម ឯតេន សច្ចេន សុវត្ថិ ហោតុ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្ដីកើតមាន។

សហាវស្ស ទស្សនសម្បទាយ តយស្សុ ធម្មា ជហិតា ភវន្តិ សក្កាយទិដ្ឋិ វិចិកិច្ឆិតញ្ច សីលព្វតំ វាបិ យទត្ថិ កិញ្ចិ (សំយោជនកិលេស ៣ យ៉ាងគឺ) សក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសៈឯណាមួយ តែងមាន ធម៌ទាំងឡាយ ៣ នោះ សោតាបន្នបុគ្គលនោះ បានលះបង់ហើយ ជាមួយនឹងទស្សនសម្ប័ទ គឺ សោតាបត្តិមគ្គ។

ចតូហបាយេហិ ច វិប្បមុត្តោ ម្យ៉ាងទៀត សោតាបន្នបុគ្គលបានរួចស្រឡះចាកអបាយទាំងឡាយ

៤ ហើយ ឆ ចាភិដ្ឋានានិ អភព្វោ កាតុំ មិនអាច ធ្វើនូវឋានដ៏អាក្រក់ទាំងឡាយ ៦ គឺអនន្តរិយកម្ម ៥ និងកិរិយាងាកចិត្តទៅកាន់សាសនាដទៃឡើយ។

ឥទម្បិ សង្ឃេ រតនំ បណីតំ កែវគឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម ឯតេន សច្ចេន សុវត្ថិ ហោតុ ដោយពាក្យសច្ចនេះ សូមសិរីសួស្តីកើតមាន។ កិញ្ចាបិ សោ កម្មំ ករោតិ បាបកំ កាយេន វាចាយុទចេតសា វា ប្រសិនណាបើសោតាបន្នបុគ្គលនោះ ធ្វើនូវបាបកម្មខ្លះ ដោយកាយវាចា ឬក៏ដោយចិត្ត (ព្រោះសេចក្តីភ្លាំងភ្លាត់)។ អភព្វោ សោ តស្ស បដិច្ឆទាយ សោតាបន្នបុគ្គលនោះ មិនអាចបិទបាំងនូវបាបកម្មនោះឡើយ។ អភព្វតា ទិដ្ឋបទស្ស វុត្តា

ភាវៈនៃបុគ្គល មានផ្លូវនៃព្រះនិព្វានឃើញហើយ ជាបុគ្គលមិនអាចនឹងបិទបាំងនូវបាបកម្ម ព្រះពុទ្ធទាំងឡាយបានត្រាស់សម្ដែងហើយ។

ឥទម្បិ សង្ឃេ រតនំ បណីតំ កែវគឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្ដម ។ ឯតេន សច្ចេន សុវត្ថិ ហោតុ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្ដីកើតមាន។

វនប្បគុម្ពេ យថា ផុស្សិតគ្គេ គិម្ហានមាសេ បឋមស្មឹ គិម្ហេ គុម្ពឈើក្នុងព្រៃមានត្រួយលូតលាស់ក្នុងខាងដើមគិម្ហរដូវ គឺខែក្ដៅយ៉ាងណាមិញ។

តថូបមំ ធម្មវរំ អទេសយិ និព្វានគាមឹ បរមំ ហិតាយ ព្រះសម្ពុទ្ធបានត្រាស់សម្ដែងហើយ នូវធម៌ដ៏ប្រសើរ ជាធម៌អាចញ៉ាំងសត្វទាំងឡាយ ឱ្យដល់នូវ

ព្រះនិព្វាន ដើម្បីប្រយោជន៍ដ៏ឧត្តម ប្រៀបដូចជាគុម្ព ឈើក្នុងព្រៃដូច្នោះឯង។

ឥទម្បិ ពុទ្ធេ រតនំ បណីតំ កែវគឺព្រះពុទ្ធនេះ ឯងជាកែវដ៏ឧត្តម។ ឯតេន សច្ចេន សុវត្ថិ ហោតុ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។

វរោ វរញ្ញូ វរទោ វរាហរោ ព្រះសម្មាសម្ពុទ្ធជា បុគ្គលប្រសើរ ទ្រង់ជ្រាបនូវធម៌ដ៏ប្រសើរ ទ្រង់ប្រទាន នូវធម៌ដ៏ប្រសើរ ទ្រង់នាំមកនូវធម៌ដ៏ប្រសើរ។

អនុត្តរោ ធម្មវរំ អទេសយិ ព្រះអង្គប្រសើរឥត មានអ្នកណាមួយស្មើ ទ្រង់ត្រាស់សម្តែងហើយនូវធម៌ ដ៏ប្រសើរ។ ឥទម្បិ ពុទ្ធេ រតនំ បណីតំ កែវគឺព្រះ ពុទ្ធនេះឯង ជាកែវដ៏ឧត្តម។ ឯតេន សច្ចេន សុវត្ថិ ហោតុ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។

ខីណំ បុរាណំ នវំ នត្ថិ សម្ភវំ កម្មចាស់(របស់អរិយបុគ្គលឯណា) អស់ហើយ កម្មថ្មី រមែងមិនកើតប្រាកដឡើយ។ វិរត្តចិត្តាយតិកេ ភវស្មិំ អរិយបុគ្គលទាំងឡាយឯណានោះ មានចិត្តនឿយណាយហើយក្នុងភពតទៅ។ តេ ខីណពីជា អវិរុឡ្ហិឆន្ទា អរិយ-បុគ្គលទាំងឡាយនោះ មានពូជអស់ហើយ មានឆន្ទៈ គឺសេចក្ដីប៉ុនប៉ងក្នុងចិត្តមិនដុះចម្រើនឡើយ។ និព្វន្តិ ធីរា យថាយម្បទីបោ ជាអ្នកមានប្រាជ្ញា តែងរលត់ទៅដូចជាប្រទីបដែលរលត់ទៅនេះ។ ឥទម្បិ សង្ឃេ រតនំ បណីតំ កែវគឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម។ ឯតេន សច្ចេន សុវត្ថិ ហោតុ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្ដីកើតមាន។

យានីធ ភូតានិ សមាគតានិ ភុម្មានិ វា យានិវ អន្តលិក្ខេ ពួកភូតឯណា ជាទេវតាស្ថិតនៅលើផែនដីក្តី ពួកភូតឯណាជាទេវតាស្ថិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ។

តថាគតំ ទេវមនុស្សបូជិតំ ពុទ្ធំ នមស្សាម សុវត្ថិ ហោតុ យើងទាំងឡាយ សូមនមស្ការនូវព្រះពុទ្ធជាម្ចាស់ ទ្រង់បានត្រាស់មកហើយដូចគ្នា ដែលទេវតានិងមនុស្ស តែងបូជាសូមសិរីសួស្តីកើតមាន។

យានីធ ភូតានិ សមាគតានិ ភុម្មានិ វា យានិវ អន្តលិក្ខេ ពួកភូតឯណា ជាទេវតាស្ថិតនៅលើផែនដីក្តី ពួកភូតឯណាជាទេវតាស្ថិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ។

តថាគតំ ទេវមនុស្ស បូជិតំ ធម្មំ នមស្សាម សុវត្ថិ ហោតុ យើងទាំងឡាយ សូមនមស្ការនូវព្រះធម៌ មានមកហើយដូចគ្នា ដែលទេវតា និងមនុស្សតែងបូជាសូមសិរីសួស្តីកើតមាន។

យានីធ ភូតានិ សមាគតានិ ភុម្មានិ វា យានិវ អន្តលិក្ខេ ពួកភូតឯណា ជាទេវតាស្ថិតនៅលើផែនដីក្តី ពួកភូតឯណា ជាទេវតាស្ថិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ។

តថាគតំ ទេវមនុស្សបូជិតំ សង្ឃំ នមស្សាម សុវត្ថិ ហោតុ យើងទាំងឡាយសូមនមស្ការ នូវព្រះសង្ឃមានមកហើយដូចគ្នា ដែលទេវតា និងមនុស្សតែងបូជាសូមសិរីសួស្តីកើតមាន។

# អភយបរិត្តគាថា

យន្ទុន្និមិត្តំ អវមង្គលញ្ច យោ ចាមនាបោ សកុណស្ស សទ្ទោ បាបគ្គហោ ទុស្សុបិនំ អកន្តំ ពុទ្ធានុភាវេន វិនាសមេន្តុ និមិត្តអាក្រក់ឯណាក្តី អពមង្គលឯណាក្តី សម្លេងសត្វមិនជាទីគាប់ចិត្តឯណាក្តី បាបគ្រោះឯណាក្តី សុបិនអាក្រក់ មិនជាទីពេញចិត្តឯណាក្តី ដោយអានុភាពនៃព្រះពុទ្ធជាម្ចាស់ សូមឱ្យនិមិត្តអាក្រក់ជាដើមនោះ ដល់នូវសេចក្តីវិនាសបាត់បង់ទៅ។

យន្ទុន្និមិត្តំ អវមង្គលញ្ច យោ ចាមនាបោ សកុណស្ស សទ្ទោ បាបគ្គហោ ទុស្សុបិនំ អកន្តំ ធម្មានុភាវេន វិនាសមេន្តុ និមិត្តអាក្រក់ឯណាក្តី អពមង្គលឯណាក្តី សម្លេងសត្វមិនជាទីគាប់ចិត្តឯណាក្តី

បាបគ្រោះឯណាក្តី សុបិនអាក្រក់ មិនជាទីពេញចិត្ត ឯណាក្តី ដោយអានុភាពនៃព្រះធម៌ សូមឱ្យនិមិត្តអាក្រក់ ជាដើមនោះ ដល់នូវសេចក្តីវិនាសបាត់បង់ទៅ។

យន្ទុន្និមិត្តំ អវមង្គលញ្ច យោ ចាមនាបោ សកុណស្ស សទ្ទោ បាបគ្គហោ ទុស្សុបិនំ អកន្តំ សង្ឃានុភាវេន វិនាសមេន្តុ និមិត្តអាក្រក់ឯណាក្តី អពមង្គលឯណាក្តី សម្លេងសត្វមិនជាទីគាប់ចិត្តឯណាក្តី បាបគ្រោះឯណាក្តី សុបិនអាក្រក់ មិនជាទីពេញចិត្ត ឯណាក្តី ដោយអានុភាពនៃព្រះសង្ឃ សូមឱ្យនិមិត្តអា-ក្រក់ជាដើមនោះ ដល់នូវសេចក្តីវិនាសបាត់បង់ទៅ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ សត្វទាំងឡាយទាំងពួងដែលដល់ហើយ នូវ

សេចក្តីទុក្ខ សូមឱ្យជាសត្វបាត់សេចក្តីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយនូវសេចក្តីសោក សូមឱ្យជាសត្វបាត់សេចក្តីសោកទៅ។

ឯត្តាវតា ច អម្ហេហិ សម្ភតំ បុញ្ញសម្បទំ សព្វេ ទេវានុមោទន្តុ សព្វសម្បត្តិសិទ្ធិយា សូមទេវតាទាំងឡាយទាំងពួង អនុមោទនានូវសម្បទា គឺបុណ្យដែលយើងទាំងឡាយ បានកសាងហើយទាំងប៉ុណ្ណេះ ដើម្បីឱ្យបានសម្រេចនូវសម្បត្តិទាំងពួង។

ទានំ ទទន្តុ សទ្ធាយ សីលំ រក្ខន្តុ សព្វទា ភាវនាភិរតា ហោន្តុ គច្ឆន្តុ ទេវតា គតា មនុស្សទាំងឡាយចូរនាំគ្នាឱ្យទានដោយសទ្ធា ចូរនាំគ្នារក្សាសីល ចូរជាអ្នកត្រេកអរចំពោះភាវនាសព្វៗកាលទៅ ទេវតាទាំងឡាយដែលមកហើយ សូមអញ្ជើញត្រឡប់ទៅវិញចុះ។

សព្វេ ពុទ្ធា ពលប្បត្តា បច្ចេកានញ្ច យម្ពលំ អរហន្តានញ្ច តេជេន រក្ខំ ពន្ធាមិ សព្វសោ ព្រះសម្មាសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គ សុទ្ធតែទ្រទ្រង់នូវកម្លាំង ទាំងព្រះបច្ចេកពុទ្ធទាំងឡាយ ក៏មានកម្លាំង ព្រះអរហន្តទាំងឡាយក៏មានកម្លាំង ខ្ញុំសូមចងនូវការរក្សាដោយតេជៈ (នៃកម្លាំងទាំងឡាយនោះ) ដោយប្រការៈទាំងពួង។

សោ អត្ថលទ្ធោ សុខិតោ វិរុឡ្ហោ ពុទ្ធសាសនេ អរោគោ សុខិតោ ហោហិ សហ សព្វេហិ ញាតីភិ អ្នក (ជាបុរស) នោះ ចូរបាននូវប្រយោជន៍ បាននូវសេចក្តីសុខ ចូរចម្រើនក្នុងព្រះពុទ្ធសាសនា ចូរកុំឱ្យមានរោគ ឱ្យបាននូវសេចក្តីសុខ ព្រមទាំងញាតិទាំងឡាយគ្រប់គ្នា។

សា អត្ថលទ្ធា សុខិតា វិរុឡ្ហា ពុទ្ធសាសនេ អរោគា សុខិតា ហោហិ សហ សព្វេហិ ញាតីភិ

អ្នក (ជាស្ត្រី) នោះ ចូរបាននូវប្រយោជន៍ បាននូវសេចក្តីសុខ ចូរចម្រើនក្នុងព្រះពុទ្ធសាសនា ចូរកុំឱ្យមានរោគ ឱ្យបាននូវសេចក្តីសុខ ព្រមទាំងញាតិទាំងឡាយគ្រប់គ្នា។

តេ អត្ថលទ្ធា សុខិតា វិរុឡ្ហា ពុទ្ធសាសនេ អរោគា សុខិតា ហោថ សហ សព្វេហិ ញាតីភិ

អ្នកទាំងឡាយ (ទាំងបុរស ទាំងស្ត្រី) នោះ ចូរបាននូវប្រយោជន៍ បាននូវសេចក្តីសុខ ចូរចម្រើនក្នុងព្រះពុទ្ធសាសនា ចូរកុំឱ្យមានរោគ ឱ្យបាននូវសេចក្តីសុខ ព្រមទាំងញាតិទាំងឡាយគ្រប់គ្នា។

# អាដានាដិយបរិត្តគាថា

សក្កត្វា ពុទ្ធរតនំ ឱសថំ ឧត្តមំ វរំ ហិតំ ទេវមនុស្សានំ ពុទ្ធតេជេន សោត្ថិនា នស្សន្តុ-បទ្ទវា សព្វេ ទុក្ខា វូបសមេន្តុ តេ សូមឱ្យឧបទ្រព ទាំងឡាយទាំងពួង វិនាសបាត់ទៅ សូមឱ្យសេចក្តីទុក្ខ ទាំងឡាយរបស់អ្នកស្ងប់រម្ងាប់ទៅ ដោយសិរីសួស្តី ដោយ តេជានុភាពនៃព្រះពុទ្ធជាម្ចាស់ ព្រោះធ្វើគោរពនូវព្រះ ពុទ្ធរតន៍ ដូចជាឱសថដ៏ឧត្តមប្រសើរ ជាប្រយោជន៍ ដល់ទេវតា និងមនុស្សទាំងឡាយ។

សក្កត្វា ធម្មរតនំ ឱសថំ ឧត្តមំ វរំ ហិតំ បរិ-ឡាហូបសមនំ ធម្មតេជេន សោត្ថិនា នស្សន្តុ-បទ្ទវា សព្វេ ភយា វូបសមេន្តុ តេ សូមឱ្យឧបទ្រព ទាំងឡាយទាំងពួងវិនាសបាត់ទៅ សូមឱ្យភ័យទាំងឡាយ

របស់អ្នកស្ងប់រម្ងាប់ទៅ ដោយសិរីសួស្តី ដោយតេជា-
នុភាពនៃព្រះធម៌ ព្រោះធ្វើគោរពនូវព្រះធម្មរតន៍ ដូច
ជាឱសថដ៏ឧត្តមប្រសើរ ជាគ្រឿងរម្ងាប់ នូវសេចក្តី
ក្រវល់ក្រវាយ។

សក្កត្វា សង្ឃរតនំ ឱសថំ ឧត្តមំ វរំ អាហុ-
នេយ្យំ បាហុនេយ្យំ សង្ឃតេជេន សោត្ថិនា
នស្សន្តុបទ្ទវា សព្វេ រោគា វូបសមេន្តុ តេ សូម
ឱ្យឧបទ្រពទាំងឡាយទាំងពួង វិនាសបាត់ទៅ សូមឱ្យ
រោគទាំងឡាយរបស់អ្នកស្ងប់រម្ងាប់ទៅ ដោយសិរីសួស្តី
ដោយតេជានុភាពនៃព្រះសង្ឃ ព្រោះធ្វើគោរពនូវព្រះ
សង្ឃរតន៍ ដូចជាឱសថដ៏ឧត្តមប្រសើរ ជាវត្ថុគួរគេនាំ
មកបូជា ជាវត្ថុគួរគេទទួលរាក់ទាក់។

ភវតុ សព្វមង្គលំ មង្គលទាំងពួងចូរមាន (ដល់អ្នក)។

រក្ខន្តុ សព្វទេវតា សូមទេវតាទាំងអស់ បីបាច់រក្សា (នូវអ្នក)។ សព្វពុទ្ធានុភាវេន ដោយអានុភាពនៃព្រះពុទ្ធជាម្ចាស់រាល់ព្រះអង្គ។ សទា សោត្ថី ភវន្តុ តេ សូមសិរីសួស្តីទាំងឡាយ កើតមានដល់អ្នក ឱ្យបានសព្វកាល សព្វវេលា។

ភវតុ សព្វមង្គលំ មង្គលទាំងពួងចូរមាន(ដល់អ្នក)។ រក្ខន្តុ សព្វទេវតា សូមទេវតាទាំងអស់បីបាច់រក្សា (នូវអ្នក)។ សព្វធម្មានុភាវេន ដោយអានុភាពនៃព្រះធម៌ទាំងពួង។ សទា សោត្ថី ភវន្តុ តេ សូមសិរីសួស្តីទាំងឡាយ កើតមានដល់អ្នក ឱ្យបានសព្វកាល សព្វវេលា។

ភវតុ សព្វមង្គលំ មង្គលទាំងពួងចូរមាន(ដល់អ្នក)។ រក្ខន្តុ សព្វទេវតា សូមទេវតាទាំងអស់បីបាច់រក្សា (នូវ

អ្នក)។ សព្វសង្ឃានុភាវេន ដោយអានុភាពនៃព្រះសង្ឃទាំងពួង។ សទា សោត្ថី ភវន្តុ តេ សូមសិរីសួស្តីទាំងឡាយកើតមានដល់អ្នក ឱ្យបានសព្វកាល សព្វវេលា។

នក្ខត្តយក្ខភូតានំ បាបគ្គហនិវារណា កិរិយារារាំងនូវបាបគ្រោះទាំងឡាយ(ដែលកើតអំពីសំណាក់)នៃនក្ខត្តឫក្ស និងយក្ខ និងភូតបីសាចទាំងឡាយ ។ បរិត្តស្សានុភាវេន ហន្ត្វា តេសំ ឧបទ្ទវេ ដោយអានុភាពនៃព្រះបរិត្ត សូមកម្ចាត់បង់នូវឧបទ្រពទាំង-ឡាយ (ដែលកើតអំពីសំណាក់) នៃនក្ខត្តឫក្ស និងយក្ខនិងភូតបីសាចទាំងឡាយនោះ។

## មង្គលចក្កវាឡ

សព្វពុទ្ធានុភាវេន ដោយអានុភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ។ សព្វធម្មានុភាវេន ដោយអានុភាពនៃ

ព្រះធម៌ទាំងពួង។ សព្វសង្ឃានុភាវេន ដោយអានុ-ភាពនៃព្រះសង្ឃទាំងពួង។

ពុទ្ធរតនំ ធម្មរតនំ សង្ឃរតនំ តិណ្ណំ រតនានំ អានុភាវេន ដោយអានុភាពនៃព្រះរតនៈទាំង ៣ គឺ ពុទ្ធរតនៈ ១ ធម្មរតនៈ ១ សង្ឃរតនៈ ១ ។

ចតុរាសីតិសហស្សធម្មក្ខន្ធានុភាវេន ដោយ អានុភាពនៃព្រះធម្មក្ខន្ធ ៨ ម៉ឺន ៤ ពាន់។

បិដកត្តយានុភាវេន ដោយអានុភាពនៃព្រះត្រៃបិដក

ជិនសាវកានុភាវេន ដោយអានុភាពនៃសាវ័ក នៃព្រះជិនស្រី។

សព្វេ តេ រោគា រោគទាំងឡាយទាំងពួងនៃអ្នក។

សព្វេ តេ ភយា ភ័យទាំងឡាយទាំងពួងនៃអ្នក។

សព្វេ តេ អន្តរាយា អន្តរាយទាំងឡាយទាំងពួងនៃអ្នក។

សព្វេ តេ ឧបទ្ទវា ឧបទ្រពទាំងឡាយទាំងពួងនៃអ្នក។

សព្វេ តេ ទុន្និមិត្តា និមិត្តអាក្រក់ទាំងឡាយទាំងពួងនៃអ្នក

សព្វេ តេ អវមង្គលា អពមង្គលទាំងឡាយទាំងពួងនៃអ្នក។ វិនស្សន្តុ សូមឱ្យវិនាសបាត់ទៅ។

អាយុវឌ្ឍកោ សេចក្តីចម្រើនដោយអាយុ។

ធនវឌ្ឍកោ សេចក្តីចម្រើនដោយទ្រព្យ។

សិរីវឌ្ឍកោ សេចក្តីចម្រើនដោយសិរីសួស្តី។

យសវឌ្ឍកោ សេចក្តីចម្រើនដោយយសបរិវារ។

ពលវឌ្ឍកោ សេចក្តីចម្រើនដោយកំលាំង។

វណ្ណវឌ្ឍកោ សេចក្តីចម្រើនដោយសម្បុរកាយ។

សុខវឌ្ឍកោ សេចក្តីចម្រើនដោយសុខ។

ហោតុ សព្វទា សូមឱ្យមានដល់អ្នកឱ្យបានសព្វៗ កាល។ ទុក្ខរោគភយា វេរា សេចក្តីទុក្ខ និងរោគ និងភ័យ និងពៀរទាំងឡាយក្តី។សោកា សត្តូចុបទ្ទវា សេចក្តីសោកទាំងឡាយក្តី សត្រូវ និងឧបទ្រពទាំង-ឡាយក្តី។ អនេកា អន្តរាយាបិ អន្តរាយទាំងឡាយដ៏ច្រើនក្តី។ វិនស្សន្តុ ច តេជសា សូមឱ្យវិនាសបាត់ទៅដោយតេជៈ (នៃអានុភាព មានពុទ្ធានុភាពជាដើមនោះ)។ ជយសិទ្ធិ ធនំ លាភំ សេចក្តីសម្រេចនៃជ័យជំនះក្តី ទ្រព្យក្តី លាភក្តី។ សោត្ថិភាគ្យំ សុខំ ពលំ សួស្តីក្តី ជោគជ័យល្អក្តី សេចក្តីសុខក្តី កំលាំងក្តី។ សិរី អាយុ ច វណ្ណោ ច បុញ្ញសិរីក្តី អាយុក្តី ពណ៌សម្បុរកាយក្តី។ ភោគំ វុឌ្ឍី ច យសវា ភោគសម្បទាក្តី

សេចក្តីចម្រើនក្តី មានយសក្តី។ សតវស្សា ច អាយុ ច អាយុប្រមាណ ១ រយឆ្នាំក្តី។ ជីវសិទ្ធី ភវន្តុ តេ សេចក្តីសម្រេចនៃកិរិយាចិញ្ចឹមជីវិតជាសុខក្តី (ទាំងអស់នេះ សូមឱ្យមានដល់អ្នក)។

## សំណូមពរ

សូមជូនអ្នកអានបានសុខប្រពៃ រួចផុតទុក្ខភ័យចង្រៃនានា
ទ្រព្យពុំប្រសើរស្មើនឹងសទ្ធា រសព្រះធម្មាឈ្នះរសអ្វីៗ។
សូមកុំកើតជាអ្នកសទ្ធាក្រ ឥតចេះអក្សរឥតធម៌វិន័យ
ជីវិតនៅរស់បាត់អស់ស្មារតី មានទ្រព្យច្រើនក្តីក៏ឥតខ្លឹមសារ។
សូមសាធុជនធ្ងន់ក្នុងទានសីល ជម្រះមន្ទិលចម្រើនមេត្តា
សូមកុំមាក់ងាយព្រះពុទ្ធសាសនាព្រោះតែដោយសារកំហុសអ្នកកាន់។

ដោយឧបាសក **គុយ សុធន**

(ដកស្រង់ចេញពីជំនួយសតិភាគ ៧)

**ចប់ធម៌សូត្រម៉ោង ២ រសៀល**

# ធម៌សូត្រ ម៉ោង ៥ ល្ងាច

១_សគ្គេ កាមេ...

២_ឥមេហិ ទីបធូបា...

៣_នមោ តស្ស...

៤_យោ សន្និសិន្នោ...

៥_ពុទ្ធំ ជីវិតំ...

៦_យេ ច ពុទ្ធា...

៧_ឥតិបិសោ ភគវា...

៨_នត្ថិ មេ សរណំ...

៩_ឧត្តមង្គេន...

១០_អដ្ឋង្គិការិយបថោ...

១១_ធម្មំ ជីវិតំ...

១២_យេ ច ធម្មា...

១៣_ស្វាក្ខាតោ...

១៤_នត្ថិ មេ សរណំ...

១៥_ឧត្តមង្គេន...

១៦_សង្ឃោ វិសុទ្ធោ...

១៧_សង្ឃំ ជីវិតំ...

១៨_យេ ច សង្ឃា...

១៩_សុបដិបន្នោ ភគវតោ...

២០_នត្ថិ មេ សរណំ...

២១_ឧត្តមង្គេន...

២២_កែវមួយ គឺព្រះពុទ្ធ...

២៣_វន្ទាមិ ចេតិយំ...

២៤_វន្ទាមិ ពុទ្ធំ...

២៥_យោ កប្បកោដី...

២៦_ឥច្ចេវ មច្ចន្ត...

២៧_ពុទ្ធំ សរណំ គច្ឆាមិ...

២៨_សម្ពុទ្ធេ...

២៩_បណិធាន...

៣០_យានី...

៣១_យស្សានុភាវេ...+ករណី...

៣២_សព្វាសីវិសជាតីនំ...

៣៣ ឥតិបិសោ...+ស្វាក្ខាតោ...+សុបដិបន្នោ...+ យន្ទុន្និមិត្តំ...

៣៤_មហាការុណិកោ...

៣៥_នមោ តស្ស...+កុសលា...

៣៦_អវិជ្ជាបច្ចយា...+អវិជ្ជាយត្វេវ...

៣៧_មេត្តញ្ច...

៣៨_អនិច្ចា...+សព្វីតិយោ...

៣៩_ យំ កិញ្ចិ...

នែនាងក្រូចឆ្មា នៅក្នុងបន្ទារ កុំថារូចខ្លួន
ជូរឆ្មាស់ពីម៉ែ ហូរហែរដល់កូន ទោះខំកែខ្លួន
បានត្រឹមណាំង៉ូវ ។
ចំណែកនាងស្វាយ ខ្ចីជូរពីម្តាយ រហូតដល់ឪ
តែគេចេះកែ ប្រែតាមរដូវ ដល់ចាស់ទុំទៅ
ផ្អែមគួរគាប់ហោង។

ល្ងង់មិនកែប្រែ ជាចំណីទាស់របស់មនុស្សចចេស។

អ្នកសុំតែងទាស់ចិត្តអ្នឱ្យ ការសុំហ្នឹងហើយនាំឱ្យបែកមិត្ត
អ្នកសុំងាយនរណាចង់ដើរជិត ជាតិបណ្ឌិតត្រូវរិះគិតហើយទើបសុំ។
អ្នកឱ្យម្តេចឡើយគេចង់អស់ មាសប្រាក់ទ្រព្យរបស់គេខំផ្តុំ
អ្នកឱ្យតែងទាស់ចិត្តអ្នកសុំ វៀរតែវង្សបរមអង្គសម្មា។
ពៅអើយពៅ រសជាតិមាននៅ គេតែងរាប់អាន
កាលណារសផ្អែម ល្វែមចេញចាកប្រាណ នោះគេសន្និដ្ឋាន
ទុកជាសំរាម។
សត្វស្វាស៊ីស្វាយមិនស្តាយគ្រាប់ ក្អាតស៊ីសាកសពមិនជិនណាយ
ជនពាលមិនឆ្អែតដោយបាបទាំងឡាយ បណ្ឌិតមិនងាយឆ្អែតធម្មា។

អាវុធអ្វីមិនស្មើនឹងបញ្ញា កំព្រាអ្វីមិនស្មើនឹងអត់បុណ្យ ។

# ប្រកាសករណីយមេត្តសូត្រ

យស្សានុភាវតោ យក្ខា នេវ ទស្សេន្តិ ភីសនំ យក្ខទាំងឡាយ មិនហ៊ានសំដែងនូវអាការៈគួរខ្លាចឡើយ ព្រោះអានុភាពនៃព្រះបរិត្តឯណា។ យម្ហិ ចេវានុ-យុញ្ជន្តោ រត្តិន្ទិវមតន្ទិតោ ម្យ៉ាងទៀត បុគ្គលមិនខ្ជិលច្រអូសក្នុងយប់ និងថ្ងៃ ហើយព្យាយាមរៀនសូត្រនូវព្រះបរិត្តឯណា។ សុខំ សុបតិ សុត្តោ ច បាបំ កិញ្ចិ ន បស្សតិ កំពុងដេកលក់ ឬលក់រួចហើយ ក៏ជាសុខ រមែងមិនឃើញនូវសុបិនក៏អាក្រក់តិចតួច។

ឯវមាទិគុណូបេតំ បរិត្តន្តម្ភណាម ហេ យើងទាំងឡាយសូត្រឥឡូវនេះ នូវព្រះបរិត្តនោះដែលប្រកបដោយគុណទាំងឡាយ មានយ៉ាងនេះជាដើម ។

# ករណីយមេត្តសូត្រ

ករណីយមត្ថកុសលេន យន្តំ សន្តំ បទំ អភិ-
សមេច្ច កិច្ចឯណា (ដែលព្រះអរិយៈ) បានត្រាស់ដឹង
នូវកោដ្ឋាសៈនៃធម៌ដ៏ស្ងប់រម្ងាប់ គឺព្រះនិព្វាន បានធ្វើ
ហើយ កិច្ចនោះ គឺកុលបុត្រ អ្នកឈ្លាសក្នុងប្រយោជន៍
គួរធ្វើ។ សក្កោ ឧជូ ច សុហុជូ ច កុលបុត្រនោះ
ជាអ្នកអាចហ៊ានផង ត្រង់ដោយកាយ និងវាចាផង
ត្រង់ល្អដោយចិត្តផង។ សុវចោ ចស្ស មុទុ អន-
តិមានី ជាអ្នកប្រដៅងាយផង សុភាពទន់ភ្លន់ផង មិន
មានមានះដ៏ក្រៃលែងផង។ សន្តុស្សកោ ច សុភរោ
ច ជាអ្នកសន្តោសផង គេចិញ្ចឹមងាយផង។ អប្ប-
កិច្ចោ ច សល្លហុកវុត្តិ ជាអ្នកមានកិច្ចធុរៈតិចផង

ប្រព្រឹត្តស្រាល(ក្នុងកាយ និងចិត្តផង)។ **សន្តិន្ទ្រិយោ ច និបកោ ច** ជាអ្នកមានឥន្ទ្រិយស្រគត់ស្រគំផង មានប្រាជ្ញាចាស់ផង។ **អប្បគព្ភោ សុលេសុ អននុគិទ្ធោ** ជាអ្នកមិនឆ្គងផង មិនជាប់ជំពាក់ក្នុងត្រកូលទាំងឡាយផង។ **ន ច ខុទ្ទំ សមាចរេ កិញ្ចិ យេន វិញ្ញូ បរេ ឧបវទេយ្យុំ** វិញ្ញូជនទាំងឡាយ គួរតិះដៀលនូវជនទាំងឡាយ ដទៃដោយកម្មឯណា មិនគួរប្រព្រឹត្តធ្វើនូវកម្មនោះ ដែលជាកម្មលាមក សូម្បីតិចតួច (ហើយ គួរផ្សាយមេត្តាចិត្តចំពោះពពួកនៃសត្វថា) **សុខិនោ វា ខេមិនោ ហោតុ សព្វេ សត្តា ភវន្តុ សុខិតត្តា** សត្វទាំងឡាយទាំងពួង សូមឱ្យមានសេចក្តីសុខ ឱ្យមានសេចក្តីក្សេម ឱ្យមានខ្លួនដល់នូវសេចក្តីសុខចុះ។ **យេ កេចិ**

បាណភូតត្ថិ តសា វា ថាវរា វា អនវសេសា សត្វមានជីវិតទាំងឡាយឯណា ឥតមានសេសសល់ ទោះសត្វដែលជាអ្នកមានសេចក្តីតក់ស្លុត គឺនៅមានតណ្ហាក្តី ជាអ្នកមាំមួនគឺឥតមានតណ្ហាក្តី។ ទីឃា វា យេ មហន្តា វា សត្វទាំងឡាយឯណា មានកាយវែងក្តី ធំក្តី ។ មជ្ឈិមា រស្សកា អនុកថូលា មានកាយយ៉ាងកណ្តាលក្តី ខ្លីក្តី មានកាយដ៏ស្គម ឬធាត់ក្តី។ ទិដ្ឋា វា យេ ច អទិដ្ឋា សត្វទាំងឡាយឯណា ដែលយើងឃើញក្តី មិនឃើញក្តី។ យេ ច ទូរេ វសន្តិ អវិទូរេ សត្វទាំងឡាយឯណា នៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី។ ភូតា វា សម្ភវេសី វា ដែលកើតរួចមកហើយក្តី ដែលកំពុងស្វែងរកទីកើតក្តី។ សព្វេ សត្តា

ភវន្តុ សុខិតត្តា សត្វទាំងឡាយទាំងពួង សូមឱ្យមាន ខ្លួនដល់នូវសេចក្ដីសុខចុះ ន បរោ បរំ និកុព្វេថ សត្វដទៃមិនគួរកំហែងបៀតបៀននូវសត្វដទៃឡើយ។ នាតិមញ្ញេថ កត្ថចិ នំ កិញ្ចិ មិនគួរមើលងាយគេ តិចតួចក្នុងទីណាមួយឡើយ។ ព្យារោសនា បដិឃ-សញ្ញា នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ មិនគួរប្រាថ្នា នូវសេចក្ដីទុក្ខដល់គ្នានឹងគ្នា ដោយសេចក្ដីក្រេវក្រោធ និងដោយបដិឃសញ្ញា គឺសេចក្ដីចង្អៀតចង្អល់ក្នុងចិត្ត ឡើយ។ មាតា យថា និយំ បុត្តំ អាយុសា ឯក-បុត្តមនុរក្ខេ មាតាថ្នមរក្សាបុត្រដែលកើតអំពីខ្លួន ជា កូនតែមួយដោយអាយុ គឺថាសូម្បីជីវិត ក៏ហ៊ានលះបង់ ក្នុងការរក្សានូវបុត្របាន យ៉ាងណាមិញ។ ឯវម្បិ សព្វ-

ភូតេសុ មានសម្ភាវយេ អបរិមាណំ បុគ្គលគួរចម្រើននូវមេត្តាចិត្ត មិនមានប្រមាណចំពោះទៅរកសត្វទាំងឡាយទាំងពួងយ៉ាងនោះឯង។ មេត្តញ្ច សព្វ-លោកស្មិំ មានសម្ភាវយេ អបរិមាណំ ឧទ្ធំ អធោ ច តិរិយញ្ច អសម្ពាធំ អវេរំ អសបត្តំ បុគ្គលគួរចម្រើននូវមេត្តាចិត្ត មិនមានប្រមាណ ជាធម៌មិនចង្អៀត មិនមានពៀរ មិនមានសត្រូវទៅក្នុងលោកទាំងអស់ គឺក្នុងខាងលើផង ខាងក្រោមផង ខាងទទឹង គឺត្រង់កណ្ដាលផង ។

តិដ្ឋញ្ចរំ និសិន្នោ វា សយានោ វា យាវតស្ស វិគតមិទ្ធោ (បុគ្គលអ្នកចម្រើននូវមេត្តាចិត្តនោះ) ទោះឈរក្ដី ដើរក្ដី អង្គុយក្ដី ដេកក្ដី ជាអ្នកមានសេចក្ដី

ងោកងក់ទៅប្រាសហើយ គឺថា ជាអ្នកមិនដេកលក់ អស់កាលត្រឹមណា។ ឯតំ សតឹ អធិដ្ឋេយ្យ គួរដំកល់ នូវមេត្តានុស្សតិនុ៎ះ (អស់កាលត្រឹមនោះ)។ ព្រហ្ម-មេតំ វិហារំ ឥធ មាហុ បណ្ឌិតទាំងឡាយពោលនូវ កិរិយានុ៎ះថាជាព្រហ្មវិហារក្នុងសាសនានេះ។

ទិដ្ឋិញ្ច អនុបគម្ម សីលវា ទស្សនេន សម្បន្នោ កាមេសុ វិនេយ្យ គេធំ នហិជាតុ គព្ភសេយ្យំ បុនរេតីតិ (បុគ្គលដែលមានមេត្តាព្រហ្ម-វិហារ) មិនដល់ស៊ប់នូវទិដ្ឋិ ជាអ្នកមានសីលប្រកប ដោយទស្សនសម្ប័ទ គឺសោតាបត្តិមគ្គ បន្ទោបង់នូវ សេចក្តីត្រេកអរក្នុងកាមទាំងឡាយហើយ រមែងមិនមក កាន់គព្ភសេយ្យាសៈ គឺថាមិនកើតក្នុងគភ៌ទៀតឡើយ។

# ធម្មារព្ទខន្ធបរិត្ត

សព្វាសីវិសជាតីនំ ទិព្វមន្តាគទំ វិយ យន្នា-
សេតិ វិសំ ឃោរំ សេសញ្ចាបិ បរិស្សយំ
អាណាក្ខេត្តម្ហិ សព្វត្ថ សព្វទា សព្វបាណិនំ សព្វ-
សោបិ និវារេតិ បរិត្តន្តម្ភណាមហេ។

ព្រះបរិត្តឯណា តែងញុំាងពិសដ៏ពន្លឹកនៃពួកសត្វ
ទីឃជាតិទាំងអស់ ឱ្យវិនាសទៅ ដូចជាឱសថវិសេស ដ៏
ប្រកបដោយមន្តទិព្វ ម្យ៉ាងទៀត ព្រះបរិត្តឯណា តែងឃាត់
បង់នូវសេចក្តីអន្តរាយដ៏វិសេស របស់សត្វទាំងអស់ ក្នុង
អាណាខេត្តទាំងមូល ដោយប្រការទាំងពួងសព្វៗ កាល
យើងទាំងឡាយ សូត្រឥឡូវនេះ នូវព្រះបរិត្តនោះ។

# ខន្ធបរិត្ត

វិរូបក្ខេហិ មេ មេត្តំ ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្តេចនាគឈ្មោះវិរូបក្ខៈទាំងឡាយផង។ មេត្តំ ឯរាបថេហិ មេ ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្តេចនាគឈ្មោះ ឯរាបថៈទាំងឡាយផង។

ឆព្យាបុត្តេហិ មេ មេត្តំ ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្តេចនាគឈ្មោះឆព្យាបុត្រទាំងឡាយផង។

មេត្តំ កណ្ហាគោតមកេហិ ច ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្តេចនាគឈ្មោះកណ្ហាគោតមកៈទាំងឡាយផង។

អបាទកេហិ មេ មេត្តំ ភាវៈជាមិត្ររបស់អាត្មា

អញ(ចូរមានជាមួយ)នឹងសត្វឥតជើងទាំងឡាយផង។

មេត្តំ ទិបាទកេហិ មេ ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ)នឹងសត្វជើងពីរទាំងឡាយផង។

ចតុប្បទេហិ មេ មេត្តំ ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងសត្វជើង៤ទាំងឡាយផង។

មេត្តំ ពហុប្បទេហិ មេ ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងសត្វជើងច្រើនទាំងឡាយផង។

មា មំ អបាទកោ ហឹសិ សត្វឥតជើង កុំបីបៀតបៀនអាត្មាអញឡើយ។

មា មំ ហឹសិ ទិបាទកោ សត្វជើងពីរ កុំបីបៀត-បៀនអាត្មាអញឡើយ។

មា មំ ចតុប្បទោ ហឹសិ សត្វជើង ៤ កុំបៀត-បៀនអាត្មាអញឡើយ។

មា មំ ហឹសិ ពហុប្បទោ សត្វជើងច្រើន កុំបៀតបៀនអាត្មាអញឡើយ។ សព្វេ សត្តា សព្វេ បាណា សព្វេ ភូតា ច កេវលា សព្វសត្វទាំងឡាយផង សព្វប្រាណទាំងឡាយផង សត្វភូតទាំងឡាយផង ទាំងអស់គ្នា។ សព្វេ ភទ្រានិ បស្សន្តុ សូមសព្វសត្វ (ទាំងនោះ) ឃើញនូវសេចក្តីចម្រើនទាំងឡាយ។

មា កិញ្ចិ បាបមាគមា សេចក្តីលាមកអាក្រក់តិចតួច កុំមកដល់ឡើយ គឺថា កុំកើតមាន (ដល់សត្វទាំងនោះឡើយ)។

អប្បមាណោ ពុទ្ធោ ព្រះពុទ្ធជាម្ចាស់ទ្រទ្រង់នូវព្រះគុណ នឹងប្រមាណមិនបាន។

អប្បមាណោ ធម្មោ ព្រះធម៌ទ្រទ្រង់នូវព្រះគុណ នឹងប្រមាណមិនបាន។

អប្បមាណោ សង្ឃោ ព្រះសង្ឃទ្រទ្រង់នូវព្រះគុណ នឹងប្រមាណមិនបាន។

បមាណវន្តានិ សិរឹសបានិ អហិវិច្ឆិកា សត-បទី ឧណ្ណា នាភី សរព្ហូ មូសិកា សត្វលូន ឬសត្វវារទាំងឡាយ គឺពស់ ខ្ទួយ ក្អែប ពីងពាង តុកកែ និងកណ្តុរ សុទ្ធតែមានប្រមាណ (គួររាប់ចំនួនបាន) គឺថាមិនច្រើនដូចគុណព្រះរតនត្រ័យទេ កតា មេ រក្ខា កតា មេ បរិត្តា កិរិយារក្សាអាត្មាអញបានធ្វើហើយទាំងកិរិយារាំង អាត្មាអញក៏បានធ្វើហើយ។

បដិក្កមន្តុ ភូតានិ ពួកសត្វ (កាច) ទាំងឡាយចូរចៀសចេញទៅ។ សោហំ នមោ ភគវតោ អាត្មាអញ( ធ្វើឥឡូវនេះ) នូវកិរិយានមស្ការ ចំពោះព្រះដ៏មានព្រះភាគជាម្ចាស់។

នមោ សត្តន្នំ សម្មាសម្ពុទ្ធានន្តិ (អាត្មាអញធ្វើឥឡូវនេះ) នូវកិរិយានមស្ការ ចំពោះព្រះសម្មាសម្ពុទ្ធទាំង ៧ ព្រះអង្គ។

## ព្រះរាជមោរបរិត្ត

បូរេន្តម្ពោធិសម្ភារេ និព្វត្តំ មោរយោនិយំ យេន សំវិហិតារក្ខំ មហាសត្តំ វនេ ចរា ចិរស្សំ វាយមន្តាបិ នេវ សក្ខឹសុ គណ្ហិតុំ ព្រានព្រៃទាំងឡាយ សូម្បីព្យាយាមអស់កាលយូរ ក៏មិនអាចដើម្បីចាប់នូវព្រះមហាសត្វ ដែលកើតហើយក្នុងកំណើតនៃក្ងោក ព្រះអង្គកំពុងបំពេញនូវពោធិសម្ភារ មានកិរិយារក្សា (នូវព្រះអង្គ) ចាត់ចែងល្អហើយ ដោយព្រះបរិត្តឯណា។ ព្រហ្មមន្តន្តិ អក្ខាតំ បរិត្តន្តម្ភណាម ហេ យើងទាំងឡាយសូត្រឥឡូវនេះ នូវព្រះបរិត្តនោះ ដែល

ព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ហៅថា ព្រហ្មមន្ត គឺមន្តដ៏ប្រសើរ។

## មោរបរិត្ត

ឧទេតយញ្ចក្ខុមា ឯករាជា ហរិស្សវណ្ណោ បឋវិប្បភាសោ ព្រះអាទិត្យនេះជាដួងភ្នែក(នៃលោក) ជាឯករាជមានពណ៌ដូចជាពណ៌នៃមាស ញុំាងប្រឹថពីឱ្យភ្លឺស្វាងហើយរះឡើង ។ តំ តំ នមស្សាមិ ហរិស្សវណ្ណំ បឋវិប្បភាសំ ព្រោះហេតុនោះខ្ញុំសូមនមស្ការនូវព្រះអាទិត្យនោះ ដែលមានពណ៌ដូចជាពណ៌នៃមាស ញុំាងប្រឹថពីឱ្យភ្លឺស្វាង។ តយជ្ជគុត្តា វិហរេមុទិវសំ យើងទាំងឡាយដែលលោកគ្រប់គ្រងរក្សាហើយក្នុងថ្ងៃនេះ គប្បីនៅជាសុខអស់មួយថ្ងៃ។ យេ ព្រាហ្មណា

**វេទគូ សព្វធម្មេ** ព្រាហ្មណ៍ទាំងឡាយ ដល់នូវវេទក្នុងធម៌ទាំងពួង។ **តេ មេ នមោ តេ ច មំ បាលយន្តុ** ព្រាហ្មណ៍ទាំងឡាយនោះ (ចូរទទួល) នូវកិរិយានមស្ការរបស់ខ្ញុំ ម្យ៉ាងទៀត ព្រាហ្មណ៍ទាំងឡាយនោះ ចូររក្សាខ្ញុំ។

**នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា** សូមនមស្ការថ្វាយបង្គំ ចំពោះព្រះពុទ្ធជាម្ចាស់ទាំងឡាយ សូមនមស្ការថ្វាយបង្គំចំពោះពោធិញ្ញាណ (នៃព្រះពុទ្ធទាំងឡាយនោះ)។

**នមោ វិមុត្តានំ នមោ វិមុត្តិយា** សូមនមស្ការថ្វាយបង្គំចំពោះ (ព្រះអរិយបុគ្គលទាំងឡាយដែលលោកផុតហើយ ចាករាគាទិក្កិលេស សូមនមស្ការ ថ្វាយបង្គំចំពោះវិមុត្តិធម៌ (នៃព្រះអរិយបុគ្គលទាំងឡាយនោះ) **ឥមំ សោ បរិត្តំ កត្វា មោរោ ចរតិ ឯសនា** ក្ងោកនោះ លុះតែបានធ្វើនូវព្រះបរិត្តនេះហើយ ទើបចរទៅដើម្បីស្វែងរកអាហារ។

អបេតយញ្ចក្ខុមា ឯករាជា ហរិស្សវណ្ណោ បឋវិប្បភាសោ ព្រះអាទិត្យនេះជាដួងភ្នែក (នៃលោក) ជាឯករាជមានពណ៌ដូចជាពណ៌នៃមាស ញុំាងប្រឹថពីឱ្យភ្លឺស្វាងហើយអស្តង្គតទៅ តំ តំ នមស្សាមិ ហរិស្ស-វណ្ណំ បឋវិប្បភាសំ ព្រោះហេតុនោះ ខ្ញុំសូមនមស្ការនូវព្រះអាទិត្យនោះ ដែលមានពណ៌ដូចជាពណ៌នៃមាស ញុំាងប្រឹថពីឱ្យភ្លឺស្វាង។

តយជ្ជគុត្តា វិហរេមុ រត្តឹ យើងទាំងឡាយដែលលោកគ្រប់គ្រងរក្សាហើយ ក្នុងថ្ងៃនេះ គប្បីនៅជាសុខអស់មួយរាត្រី។ យេ ព្រាហ្មណា វេទគុ សព្វ-ធម្មេ ព្រាហ្មណ៍ទាំងឡាយឯណា ដល់នូវវេទធម៌ទាំងពួង។ តេ មេ នមោ តេ ច មំ បាលយន្តុ ព្រាហ្មណ៍ទាំងឡាយនោះ (ចូរទទួល)នូវកិរិយានមស្ការ

របស់ខ្ញុំ ម្យ៉ាងទៀត ព្រាហ្មណ៍ទាំងឡាយនោះ (ចូររក្សានូវខ្ញុំ)។ នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា សូមនមស្ការថ្វាយបង្គំ ចំពោះព្រះពុទ្ធជាម្ចាស់ទាំងឡាយ សូមនមស្ការថ្វាយបង្គំចំពោះពោធិញ្ញាណ (នៃព្រះពុទ្ធទាំងឡាយនោះ)។

នមោ វិមុត្តានំ នមោ វិមុត្តិយា សូមនមស្ការថ្វាយបង្គំចំពោះ (ព្រះអរិយបុគ្គលទាំងឡាយ) ដែលលោកផុតហើយ ចាករាគាទិក្កិលេស សូមនមស្ការ ថ្វាយបង្គំចំពោះវិមុត្តិធម៌ (នៃព្រះអរិយបុគ្គលទាំងឡាយនោះ) ។ ឥមំ សោ បរិត្តំ កត្វា មោរោ វាសមកប្បយីតិ ក្រោកនោះ លុះតែបានធ្វើនូវព្រះបរិត្តនេះហើយ ទើបបានសម្រេចនូវកិរិយានោះ។

(ចប់ធម៌សូត្រម៉ោង ៥ ល្ងាច)

# អកុសលកម្មបថ

គន្លង ឬផ្លូវនៃអំពើជាអកុសល ហៅថា អកុសលកម្ម-បថ មាន ១០ យ៉ាងគឺ **កាយកម្ម** អំពើដែលសម្រេចដោយកាយ មាន ៣ យ៉ាង, វចីកម្ម អំពើដែលសម្រេចដោយវាចា មាន ៤ យ៉ាង, មនោកម្ម អំពើដែលសម្រេចដោយចិត្តមាន ៣ យ៉ាង រួមត្រូវជា ១០ យ៉ាង។

## កាយកម្ម ៣ យ៉ាង

១-បាណាតិបាតោ កិរិយាសម្លាប់សត្វ ដោយកាយរបស់ខ្លួន ឬប្រើគេឱ្យសម្លាប់ដោយវាចា។

២-អទិន្នាទានំ កិរិយាលួចលាក់ឆក់ដណ្តើមទ្រព្យគេ ដោយកាយរបស់ខ្លួន ឬប្រើគេឱ្យលួចលាក់ឆក់ដណ្តើមដោយវាចា។

៣_កាមេសុ មិច្ឆាចារោ កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺធ្វើនូវមេថុនសេវនៈ នឹងស្ត្រីដែលមានគេហួងហែងរក្សា។

## វចីកម្ម ៤ យ៉ាង

១_មុសាវាទោ កិរិយាពោលនូវពាក្យកុហក។

២_បិសុណាវាចា កិរិយាពោលនូវពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ។

៣_ផរុសវាចា កិរិយាពោលនូវពាក្យអាក្រក់មានពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម។

៤_សម្ផប្បលាបោ កិរិយាពោលនូវពាក្យរោយ_រាយឥតប្រយោជន៍។

# មនោកម្ម ៣ យ៉ាង

១-អភិជ្ឈា ចិត្តសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបម្រុងនឹងឱ្យបានជាទ្រព្យរបស់ខ្លួន។

២-ព្យាបាទោ ចិត្តចងគំនុំគុំគួនគិតប៉ងនឹងឱ្យអ្នកដទៃដល់នូវសេចក្តីវិនាស។

៣-មិច្ឆាទិដ្ឋិ គំនិតយល់ខុសហើយប្រកាន់ឡើងថាជាត្រូវ។

## អង្គនៃកម្មបថ និង សីល

### បាណាតិបាតៈ មានអង្គ ៥ គឺ

១.បាណោ សត្វមានជីវិត។

២.បាណសញ្ញិតា សេចក្តីដឹងថាសត្វមានជីវិត។

៣.វធកចិត្តំ គិតនឹងសម្លាប់។

៤.ឧបក្កមោ ព្យាយាមនឹងសម្លាប់។

៥.តេន មរណំ សត្វស្លាប់ដោយព្យាយាមនោះ។

**អទិន្នាទាន មានអង្គ ៥**

១.បរបរិគ្គហិតំ ទ្រព្យដែលមានម្ចាស់របស់គេហួងហែងរក្សា។

២.បរបរិគ្គហិតសញ្ញិតា សេចក្តីដឹងថា ទ្រព្យមានម្ចាស់របស់គេហួងហែងរក្សា។

៣.ថេយ្យចិត្តំ គិតនឹងលួច។

៤.ឧបក្កមោ ព្យាយាមនឹងលួច។

៥.តេន ហរណំ លួចបានមកដោយព្យាយាមនោះ។

**កាមេសុមិច្ឆាចារៈ មានអង្គ ៤**

១.អគមនីយដ្ឋានំ ស្ត្រីដែលមិនគួរនឹងគប់រក គឺ

ស្ត្រីដែលមានគេហួងហែងរក្សា។

២.តស្មឹ សេវនចិត្តំ គិតនឹងសេពនូវមេថុនធម្ម នឹងស្ត្រីនោះ។

៣.ឧបក្កមោ ព្យាយាមនឹងសេពនូវមេថុនធម្មនោះ។

៤.មគ្គេន មគ្គប្បដិបាទនំ ញ៉ាំងមគ្គ និងមគ្គឱ្យ ដល់គ្នា។

## មុសាវាទ មានអង្គ ៤

១.អតថំ វត្ថុ វត្ថុមិនពិត។

២.វិសំវាទនចិត្តំ គិតនឹងពោលឱ្យខុស។

៣.តជ្ជោ វាយាមោ ព្យាយាមនឹងពោលឱ្យខុស។

៤.បរស្ស តទត្ថវិជាននំ ញ៉ាំងអ្នកដទៃឱ្យដឹង ច្បាស់នូវសេចក្ដីនោះ។

## បិសុណាវាចា មានអង្គ ៤

១.ភិន្ទិតព្វោ បរោ អ្នកដទៃដែលមានរូប គឺខ្លួនគប្បីញុះញង់បំបែក។

២.ភេទនបុរេក្ខារតោ គិតនឹងញុះញង់បំបែកអ្នកដទៃ។

៣.តជ្ជោ វាយាមោ ព្យាយាមនឹងញុះញង់បំបែកអ្នកដទៃនោះ។

៤.តស្ស តទត្ថវិជាននំ ញុំាងអ្នកនោះឱ្យដឹងច្បាស់នូវដំណើរដែលខ្លួនញុះញង់បំបែកនោះ។

## ផរុសវាចា មានអង្គ ៣

១.អក្កោសិតព្វោ បរោ អ្នកដទៃដែលមានរូបគឺខ្លួនគប្បីជេរប្រទេច។

២.កុប្បិតចិត្តំ ចិត្តខឹងរន្ធត់។

៣.អក្កោសនា បានជេរប្រទេចគេ។

## សម្ផប្បលាបៈ មានអង្គ ២

១.ភារតយុទ្ធសិតាហរណាទិនិរត្ថកថា ពាក្យឥតប្រយោជន៍ មានរឿងចម្បាំងនៃមហាភារតៈ និងរឿងរាពណ៍លួចនាំនាងសេតាយកទៅជាដើម។

២.តថារូបីកថាកថនំ បានពោលនូវពាក្យឥតប្រយោជន៍មានសភាពដូច្នោះ។

## អភិជ្ឈា មានអង្គ ២

១.បរភណ្ឌំ ទ្រព្យជារបស់អ្នកដទៃ។

២.អត្តនោ បរិណាមនំ គិតចង់បង្អោនទ្រព្យរបស់អ្នកដទៃនោះ ឱ្យបានមកជាទ្រព្យរបស់ខ្លួនដោយកលឧបាយផ្សេងៗ។

## ព្យាបាទ មានអង្គ ២

១.បរសត្តោ អ្នកដទៃក្រៅពីខ្លួន។

២.តស្ស តំ តំ វិនាសចិន្តា គិតគុំគួនប្រុងនឹងឱ្យអ្នកនោះដល់នូវសេចក្ដីវិនាស ដោយហេតុនោះៗ។

## មិច្ឆាទិដ្ឋិ មានអង្គ ២

១.វត្ថុនោ ច គហិតាការវិបរិត្តតា ចិត្តប្រែប្រួលដោយអាការខុសអំពីព្រះរតនត្រ័យជាដើម។

២.យថា ច នំ គណ្ហាតិ តថាភាវេន តស្សុ-បដ្ឋានំ គំនិតដែលយល់ខុសនោះ ឃើញខុសយ៉ាងណាក៏ប្រកាន់សេចក្ដីខុសនោះថាជាត្រូវវិញ។

## អព្រហ្មចរិយៈ មានអង្គ ៤

១.ភេទនវត្ថុ វត្ថុជាទីទម្លាយនូវសីល គឺទ្វារទាំង ៣០ ចំពោះត្រង់ទ្វារណាមួយ។

២.សេវនចិត្តំ គិតនឹងសេព។

៣.តជ្ជោ វាយាមោ ព្យាយាមនឹងសេពនូវមេថុននោះ

៤.មគ្គេន មគ្គប្បដិបាទនំ ញុំាងមគ្គ និងមគ្គឱ្យដល់គ្នា។

## សុរាមេរយៈ មានអង្គ ៤

១.មជ្ជនីយវត្ថុ វត្ថុជាទីតាំងនៃសេចក្តីស្រវឹង គឺសុរា និងមេរ័យ។

២.បាតុកម្យតាចិត្តំ គិតបំរុងនឹងផឹក។

៣.តជ្ជោ វាយាមោ ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ។

៤.តស្ស បានំ បានផឹកនូវទឹកស្រវឹងនោះ ឱ្យកន្លងបំពង់កចូលទៅ។

## វិកាលភោជន មានអង្គ ៣

១.វិកាលោ កាលខុស គឺព្រះអាទិត្យជ្រេទៅ ហើយដ៏រាបទល់នឹងអរុណរះ។

២.យាវកាលិកំ របស់ដែលគួរបរិភោគបាន ក្នុងកាល គឺតាំងពីអរុណរះឡើងដ៏រាបដល់ថ្ងៃត្រង់។

៣.អជ្ឈោហរណំ បានលេបចូលទៅក្នុងបំពង់ក។

**នច្ចគីតៈ**និង**មាលា** រួមគ្នាជាសិក្ខាបទ១ មានអង្គ៦គឺៈ

១.នច្ចគីតាទិ ការល្បែងមានរាំនិងច្រៀងជាដើម។

២.កត្តុកម្យតាចិត្តំ គិតបំរុងនឹងធ្វើ។

៣.សុតទស្សនត្ថាយ គមនំ ទៅដើម្បីនឹងស្តាប់ ឬមើល ហើយបានស្តាប់ ឬមើល។

៤.មាលាទិ វត្ថុសម្រាប់ប្រដាប់កាយ មានផ្កាកម្រងជាដើម។

៥.ធារណច្ឆន្ទតា សេចក្តីប្រាថ្នានឹងប្រដាប់តាក់តែង។

៦.តស្ស ធារណំ បានប្រដាប់តាក់តែង នូវវត្ថុសម្រាប់ប្រដាប់កាយ មានផ្កាកម្រងជាដើមនោះ។

## ឧច្ចាសយនៈ មានអង្គ ៣

១.ឧច្ចាសយនមហាសយនំ ទីដេក ទីអង្គុយដ៏ខ្ពស់ ដ៏ប្រសើរហួសប្រមាណ។

២.បរិភោគចិត្តំ គិតនឹងដេក ឬអង្គុយ។

៣.បរិភោគករណំ បានដេក ឬអង្គុយ។

# កថាវត្ថុ

ពាក្យដែលគួរពោលមាន ១០ យ៉ាងគឺៈ

១.អប្បិច្ឆកថា ពាក្យដែលនាំឱ្យប្រាថ្នាតិច។

២.សន្តុដ្ឋិកថា ពាក្យដែលនាំឱ្យមានសន្តោស។

៣.បវិវេកកថា ពាក្យដែលនាំឱ្យស្ងាត់កាយស្ងាត់ចិត្ត។

៤.អសំសគ្គកថា ពាក្យដែលនាំមិនឱ្យច្រឡូកច្រឡំដោយពួកគណៈ។

៥.វិរិយារម្ភកថា ពាក្យដែលនាំឱ្យប្រារព្ធព្យាយាម។

៦.សីលកថា ពាក្យដែលនាំឱ្យតាំងនៅក្នុងសីល។

៧.សមាធិកថា ពាក្យដែលនាំឱ្យចិត្តឱ្យស្ងប់។

៨.បញ្ញាកថា ពាក្យដែលនាំឱ្យកើតប្រាជ្ញា។

៩.វិមុត្តិកថា ពាក្យដែលនាំឱ្យចិត្តឱ្យផុតចាកកិលេស

១០.វិមុត្តិញ្ញាណទស្សនកថា ពាក្យដែលនាំឱ្យកើតសេចក្ដីដឹងឃើញក្នុងការណ៍ដែលចិត្តផុតចាកកិលេស។

## គុណនៃឧបាសក

ធម៌សម្រាប់ឧបាសក ឧបាសិកាគ្រប់រូប ប្រតិបត្តិដើម្បីនឹងឱ្យកើត ឱ្យចម្រើននូវសម្បត្តិទាំងពួង ឈ្មោះថា "គុណ"។

គុណនេះ ជារបស់ឧបាសក ឧបាសិកា ហៅថា ឧបាសកគុណ មាន ១០ យ៉ាងគឺ:

១.សង្ឃេន សទ្ធឹ សមានសុខទុក្ខោ ហោតិ ឧបាសកអ្នករួមសេចក្ដីសុខទុក្ខ មួយអន្លើដោយភិក្ខុសង្ឃ គឺថា បើភិក្ខុសង្ឃមានសេចក្ដីសុខ ក៏ត្រេកអរ បើភិក្ខុសង្ឃមានសេចក្ដីទុក្ខព្រួយ ក៏ព្រួយជាមួយផងដែរ។

២.កាយិកវាចសិកញ្ច សុរក្ខិតំ ហោតិ

ឧបាសកមានកាយកម្ម និងវចីកម្ម រក្សាហើយដោយប្រពៃ។

៣.ធម្មោ អធិបតេយ្យោ ហោតិ ឧបាសកមានធម៌ជាអធិបតី គឺថា បើប្រព្រឹត្តធ្វើអ្វីៗ រមែងកាន់យកធម៌ជាធំ ជាទីតាំង ជាទីអាងមាំ មិនឱ្យខុស មិនឱ្យឃ្លៀងឃ្លាតអំពីធម៌ឡើយ។

៤.យថា ថាមេន សំវិភាគរតោ វ ហោតិ ឧបាសកជាអ្នកត្រេកអរក្នុងការបរិច្ចាគទាន តាមសមគួរដល់កម្លាំងនៃខ្លួន គឺធ្វើទានតាមសមគួរដល់ទ្រព្យតិច និងច្រើន បើមានតិច ក៏ធ្វើតិច បើមានច្រើន ក៏ធ្វើច្រើន មិនមានមច្ឆរិយធម៌គ្របសង្កត់សន្តានចិត្តឡើយ។

៥.ជិនសាសនំ ជានិតុញ្ច វាយមតិ ឧបាសកឧស្សាហ៍ព្យាយាម ដើម្បីនឹងឱ្យដឹងច្បាស់ នូវសាសនៈគឺពាក្យប្រៀនប្រដៅពាក្យបណ្តាំនៃព្រះជិនស្រី។

៦.សម្មាទិដ្ឋិកោ វ ហោតិ ឧបាសកជាសម្មាទិដ្ឋិ គឺមានប្រាជ្ញាឃើញត្រូវតាមសេចក្តីពិត។

៧.អបគតោ កោតុហលមង្គលិកោ វ ហោតិ ឧបាសកប្រាសចាកមង្គលភ្ញាក់ផ្អើល ហើយជាអ្នកមិនប្រកាន់ជឿថា មង្គលមានឫក្សពារវេលាជាដើម ឱ្យផលឡើយ ប្រកាន់ជឿតែកម្មជាកុសល និងអកុសលថាឱ្យផល។

៨.ជីវិតហេតុបិ អញ្ញំ សត្ថារំ ន ឧទ្ទិសតិ ឧបាសកបើទុកជាមានហេតុ គួរដល់នូវសេចក្តីវិនាសជីវិតក្តី ក៏មិនលះបង់ព្រះរតនត្រ័យ ហើយត្រឡប់ទៅកាន់យកមនុស្សដទៃជាគ្រូអាចារ្យជាទីពឹងរបស់ខ្លួនថាប្រសើរជាងព្រះរតនត្រ័យនោះឡើយ។

៩.សមគ្គារាមោ វា ហោតិ ឧបាសកមានសេចក្តីត្រេកអរ ក្នុងសាមគ្គីធម៌ គឺសេចក្តីព្រមព្រៀងគ្នា។

១០.សាសនេ ចរតិ ឧបាសកប្រព្រឹត្តល្អក្នុងព្រះ-ពុទ្ធសាសនាគឺប្រព្រឹត្តតាមតែធម៌វិន័យជាពុទ្ធសាសនា។

ឧបាសកគុណទាំង ១០ យ៉ាងនេះ ឧបាសក-ឧបាសិកា គប្បីប្រព្រឹត្តតាម កុំឱ្យឃ្លៀងឃ្លាតឡើយ ព្រោះជាធម៌ អាចនឹងធ្វើចិត្តឧបាសកឧបាសិកា អ្នកប្រតិបត្តិឱ្យសុចរិតផ្លូវផង់ក្នុងព្រះពុទ្ធសាសនា ហើយឱ្យបានជាបច្ច័យនៃនិព្វានសម្បត្តិផង។

# ឧបាសកនិទ្ទេស

សម្តែងអំពីឈ្មោះថា **ឧបាសក** និងធម៌របស់ឧបាសកផ្សេងៗ មានសីលជាដើម។

ជនដែលមាននាមបញ្ញត្តិថា “**ឧបាសក**” នោះ ដោយហេតុ ដែលបានចូលទៅជិតដល់នូវព្រះរតនត្រ័យជាទីពឹង ទីរឭក ដូចពុទ្ធភាសិតដែលព្រះសម្មាសម្ពុទ្ធ

ទ្រង់ត្រាស់សម្តែង ចំពោះនឹងមហានាមសក្យរាជថា: "ម្នាលមហានាម គ្រហស្ថឯណាមួយ បានដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹង ទីរឭក គ្រហស្ថនោះឯង បានឈ្មោះថា ឧបាសក(បើស្ត្រីហៅថាឧបាសិកា)"។

ម្យ៉ាងទៀត មានបាលីថា **រតនត្តយំ ឧបាសតីតិ ឧបាសកោ** ប្រែថា: ជនឯណាចូលទៅអង្គុយជិតព្រះរតនត្រ័យ ជននោះ ឈ្មោះថា ឧបាសក។ អធិប្បាយថា ជនដែលចូលទៅអង្គុយជិតព្រះរតនត្រ័យនោះ គឺមិនមែនចូលទៅអង្គុយជិតព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជានិច្ច ដោយរូបកាយនោះទេ គឺលោកសង្គ្រោះយកនាមកាយជាប្រមាណ, សូម្បីជននោះ ស្ថិតនៅក្នុងទីឆ្ងាយប៉ុន្មាន តែមានសន្តានចិត្តប្រព្រឹត្តជាប់នៅក្នុងគុណព្រះរតនត្រ័យ ជាទីពឹងជាទីរឭកជានិច្ច ចិត្តនោះ តោង

ឱនយកគុណព្រះរតនត្រ័យ ជាទីពឹងទីរឭកជានិច្ច, បើគ្រាន់តែចូលទៅអង្គុយជិតព្រះពុទ្ធ ដោយរូបកាយ តែសន្តានចិត្តនោះស្ថិតនៅក្នុងទីឆ្ងាយ អំពីគុណព្រះរតនត្រ័យ មិនបង្អោនចិត្តទៅ ក្នុងគុណព្រះរតនត្រ័យទេ ជននោះឈ្មោះថា ស្ថិតនៅឆ្ងាយអំពីគុណព្រះរតនត្រ័យ មិនមែនជា "**ឧបាសក ឧបាសិកា**" ឡើយ។

បុៈ អ្វីជាសីលនៃឧបាសក? វិៈ បញ្ចវិរតិចេតនា គឺចេតនាវៀរចាកនូវបញ្ចវេរាទាំង ៥ ឈ្មោះថា ជាសីលនៃឧបាសក។ បុៈ តើវេរាទាំង ៥ នោះ គឺអ្វីខ្លះ? វិៈ វេរាទាំង ៥ នោះ គឺ :

១-សម្លាប់សត្វ ២-លួចទ្រព្យគេ ៣-ប្រព្រឹត្តខុសក្នុងកាម ៤-និយាយកុហក ៥-ផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យទាំង ៥ នេះ ឈ្មោះថា បញ្ចវេរា។ បុៈ យ៉ាង-

ម៉េចហៅថា អាជីវៈ ការចិញ្ចឹមជីវិតត្រូវរបស់ឧបាសក ?
វិៈ ការលះបង់នូវជំនួញខុសទាំង ៥ ប្រការ ហើយ ប្រកបកិច្ចការចិញ្ចឹមជីវិតដ៏ប្រពៃ ដោយត្រឹមត្រូវតាមគន្លងធម៌ ឈ្មោះថា អាជីវៈនៃឧបាសក។ ព្រះសម្មាសម្ពុទ្ធទ្រង់ហាម ចំពោះភិក្ខុទាំងឡាយថាៈ **បញ្ចហិ ភិក្ខវេ វណិជ្ជា ឧបាសកេន អករណីយា** ម្នាលភិក្ខុទាំងឡាយ ជំនួញខុសទាំង ៥ ប្រការ ឧបាសកមិនគប្បីធ្វើឡើយ។ បុៈ តើជំនួញខុសទាំង ៥ នោះ គឺអ្វីខ្លះ?

វិៈ ជំនួញខុសទាំង ៥ នោះ គឺៈ

១-សត្ថវណិជ្ជា ជួញគ្រឿងសាស្ត្រាវុធ

២-សត្តវណិជ្ជា ជួញមនុស្ស

៣-មំសវណិជ្ជា ជួញសត្វយកសាច់លក់

៤-មជ្ជវណិជ្ជា ជួញទឹកស្រវឹង

៥_វិសវណិជ្ជា ជួញថ្នាំពុល។

បុះ យ៉ាងម៉េចហៅថា វិបត្តិ របស់ឧបាសក ? វិះ ធម្មជាតិដែលញ៉ាំងសីល និងអាជីវធម៌ ឱ្យវិនាស ឈ្មោះថា វិបត្តិ។ បុះ វិបត្តិនោះ មានប៉ុន្មានយ៉ាងអ្វីខ្លះ? វិះ វិបត្តិ មាន ៥ យ៉ាង គឺ :

១_អស្សទ្ធោ ហោតិ ឧបាសកមិនជឿគុណព្រះរតនត្រ័យ។

២_ទុស្សីលោ ហោតិ ឧបាសក ទ្រុស្តសីល

៣_កោតុហលមង្គលិកោ ហោតិ ឧបាសកជឿមង្គលភ្ញាក់ផ្អើល។

៤_មង្គលំ បច្ចេតិ នោ កម្មំ ឧបាសកជឿមង្គលភ្ញាក់ផ្អើល មិនជឿកម្មផល។

៥_ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ

តត្ថ ច បុញ្ញការំ ករោតិ ឧបាសកស្វែងរកទក្ខិណេយ្យ-បុគ្គលក្រៅពុទ្ធសាសនា។

បុៈ ចុះអ្វីទៅជាគុណសម្បត្តិរបស់ឧបាសក ? វិៈ ធម្មជាតិដែលញ៉ាំងសីល និងអាជីវធម៌របស់ឧបាសក ឱ្យល្អបរិសុទ្ធផូរផង់ឡើង ហៅថា សម្បត្តិឧបាសក។ បុៈ ចុះសម្បត្តិនោះមានប៉ុន្មានយ៉ាង អ្វីខ្លះ? វិៈ សម្បត្តិនោះ មាន ៥ យ៉ាង គឺៈ

១-សទ្ធោ ហោតិ ឧបាសកមានសទ្ធា ជឿគុណព្រះរតនត្រ័យ។

២-សីលវា ហោតិ ឧបាសកមានសីល

៣-ន កោតុហលមង្គលិកោ ហោតិ ឧបាសកមិនជឿមង្គលភ្ញាក់ផ្អើល។

៤-កម្មំ បច្ចេតិ នោ មង្គលំ ឧបាសកជឿកម្ម

ផល មិនជឿមង្គលភ្ញាក់ផ្អើល។

៥_ន ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ ឧបាសកមិនស្វែងរកទក្ខិ-ណេយ្យបុគ្គលក្រៅពុទ្ធសាសនា។

# អរិយទ្រព្យ ៧ ប្រការ

ទ្រព្យ គឺគុណសេចក្តីល្អ ដែលមាននៅក្នុងសន្តាន យ៉ាងប្រសើរ ហៅថា អរិយទ្រព្យ ៧ យ៉ាងគឺ:

១_សទ្ធាធនំ ទ្រព្យ គឺសេចក្តីជឿដែលគួរជឿ

២_សីលធនំ ទ្រព្យ គឺការរក្សាកាយ វាចា ឱ្យរៀបរយល្អ។

៣_ហិរិធនំ ទ្រព្យ គឺសេចក្តីខ្មាសអំពើបាប

៤_ឱត្តប្បធនំ ទ្រព្យ គឺសេចក្តីខ្លាចអំពើបាប

៥_សុតធនំ ទ្រព្យ គឺការធ្លាប់បានឮ បានស្តាប់មកជាច្រើន ជាអ្នកចេះចាំធម៌ វិជ្ជា សិល្បៈច្រើន។

៦_ចាគធនំ ទ្រព្យ គឺការលះបង់ បែងចែករបស់ខ្លួនឱ្យដល់បុគ្គលដែលគួរឱ្យ។

៧_បញ្ញាធនំ ទ្រព្យ គឺការដឹងស្គាល់របស់ដែលជាប្រយោជន៍ និងមិនជាប្រយោជន៍។

អរិយទ្រព្យទាំង ៧ ប្រការនេះ ល្អជាងទ្រព្យខាងក្រៅ មានមាសប្រាក់ជាដើម នេះ គឺគួររក គួរខំប្រឹងសន្សំទុកឱ្យមាននៅក្នុងសន្តាន ហេតុដូច្នេះ យើងត្រូវស្គាល់ឱ្យបានគ្រប់ៗគ្នា។

១_សទ្ធាយ តរតិ ឱឃំ សត្វលោកឆ្លងអន្លង់ ៤ បានដោយសារសទ្ធា។

២_សទ្ធា កម្មំ ពីជំ សទ្ធាជាពូជបុណ្យ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែង អំពីអាហាររបស់វិជ្ជា និងវិមុត្តិ ដែលទាក់ទងទៅនឹងឥន្ទ្រិយសំវរៈទុកក្នុងអង្គុត្តរនិកាយ ទសកនិបាតថាៈ

១_វិជ្ជា និងវិមុត្តិ មានអាហារគឺពោជ្ឈង្គៈ ៧។

២_ពោជ្ឈង្គៈ ៧ មានអាហារគឺសតិប្បដ្ឋាន ៤។

៣_សតិប្បដ្ឋាន ៤ មានអាហារ គឺសុចរិត ៣។

៤_សុចរិត ៣ មានអាហារគឺឥន្ទ្រិយសំវរៈ។

៥_ឥន្ទ្រិយសំវរៈមានអាហារ គឺសតិសម្បជញ្ញៈ។

៦_សតិសម្បជញ្ញៈមានអាហារគឺយោនិសោមនសិការ។

៧_យោនិសោមនសិការមានអាហារ គឺសទ្ធា។

៨_សទ្ធាមានអាហារ គឺការស្ដាប់នូវព្រះសទ្ធម្ម។

៩ ការស្ដាប់នូវព្រះសទ្ធម្មមានអាហារ គឺការសេព_គប់នូវសប្បុរស។

១០_ការសេពគប់សប្បុរសឱ្យបរិបូរណ៍ តែងញ៉ាំង ការបានស្តាប់ធម៌ឱ្យបរិបូរណ៍។

_ការបានស្តាប់ធម៌បរិបូរណ៍ តែងញ៉ាំងសទ្ធា ឱ្យ បរិបូរណ៍។

_ពោជ្ឈង្គៈ ៧ បរិបូរណ៍តែងញ៉ាំង វិជ្ជា និង វិមុត្តិ ឱ្យបរិបូរណ៍។

# ភាសិតោវាទ សង្ខេប

ឧកាស ខ្ញុំសូមគោរព យោ បន ធម្មានុធម្ម-ប្បដិបន្នោ វិហរតិ សាមីចិ បដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ បដិបត្តិបូជាយ ។ អ្នកឯណាមួយ ជាអ្នកប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌

ជាអ្នកប្រតិបត្តិដោយត្រឹមត្រូវ ជាអ្នកប្រព្រឹត្តតាមធម៌ ជាប្រក្រតី អ្នកនោះឈ្មោះថា ធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អាន បូជានូវព្រះតថាគត ដោយបដិបត្តិ-បូជា ជាបូជាដ៏ឧត្តម។

**សព្វបាបស្ស អករណំ កុសលស្សូបសម្បទា សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ។**

កិរិយាមិនធ្វើនូវបាបទាំងពួង កិរិយាបំពេញកុសល កិរិយាធ្វើចិត្តរបស់ខ្លួន ឱ្យផូរផង់ ទាំងនេះ ជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ។

**ខន្តិ បរមំ តបោ តីតិក្ខា និព្វានំ បរមំ វទន្តិ ពុទ្ធា ន ហិ បព្វជិតោ បរូបឃាតី សមណោ ហោតិ បរំ វិហេឋយន្តោ។**

អំណត់ គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធ

ទាំងឡាយទ្រង់ត្រាស់ថា ព្រះនិព្វានជាគុណជាតដ៏ឧត្តម អ្នកបួសដែលបៀតបៀនសត្វដទៃ សម្លាប់សត្វដទៃ មិនមែនជាបព្វជិត មិនមែនជាសមណៈឡើយ។

**អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច សំវរោ មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច សយនាសនំ អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ។**

កិរិយាមិនតិះដៀល (អ្នកដទៃ) ១ កិរិយាមិនបៀត-បៀន (អ្នកដទៃ)១ កិរិយាសង្រួមក្នុងបាតិមោក្ខ ១ ភាវៈដឹងប្រមាណក្នុងភត្តាហារ ១ ទីដេក និងទីអង្គុយដ៏ស្ងាត់ ១ កិរិយាបំពេញព្យាយាមក្នុងអធិចិត្ត ១ ទាំងនេះ ជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ។

**សីលសមាធិគុណានំ ខន្តិ បធានការណំ សព្វេបិ កុសលា ធម្មា ខន្ត្យាយេវ វឌ្ឍន្តិ តេ។**

សេចក្តីអត់ធន់ ជាហេតុ ជាទីតាំងនៃគុណ គឺសីល និងសមាធិទាំងឡាយ ធម៌ទាំងឡាយជាកុសលទាំងអស់នោះ តែងចំរើនដោយសេចក្តីអត់ធន់មែនពិត។

**កេវលានំបិ បាបានំ ខន្តិ មូលំ និកន្តតិ**
**គរហកលហាទីនំ មូលំ ខណតិ ខន្តិកោ។**

សេចក្តីអត់ធន់ តែងកាត់បង់បាននូវឫសនៃបាបទាំងឡាយទាំងអស់ បុគ្គលអ្នកអត់ធន់ ឈ្មោះថា ជីករំលើងនូវឫសនៃទោសទាំងឡាយ មានពាក្យតិះដៀលនឹងការឈ្លោះប្រកែកជាដើម។

**ខន្តិ ធីរស្ស លង្ការោ ខន្តិ តបោ តបស្សិនោ**
**ខន្តិ ពលំ វ យតីនំ ខន្តិ ហិតសុខាវហា។**

សេចក្តីអត់ធន់ ជាគ្រឿងអលង្ការ របស់អ្នកប្រាជ្ញ សេចក្តីអត់ធន់ ជាគ្រឿងដុតបង់នូវបាបរបស់អ្នកដែល

មានតបធម៌ សេចក្ដីអត់ធន់ជាកម្លាំងរបស់អ្នកប្រព្រឹត្តធម៌ សេចក្ដីអត់ធន់ ជាគុណជាតិនាំមកនូវប្រយោជន៍ និងសេចក្ដីសុខ។

## ខន្តិកោ មេត្តវា លាភី យសស្សី សុខសីលវា បិយោ ទេវមនុស្សានំ មនាបោ ហោតិ ខន្តិកោ។

អ្នកអត់ធន់ ជាអ្នកមានមិត្រសំឡាញ់ ជាអ្នកមានលាភ ជាអ្នកមានយស ជាអ្នកមានសេចក្ដីសុខជាប្រក្រតី អ្នកអត់ធន់ រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃទេវតានិងមនុស្សទាំងឡាយ។

## អត្តនោបិ បរេសញ្ច អត្ថាវហោ វ ខន្តិកោ សគ្គមោក្ខគមំ មគ្គំ អារុឡ្ហោ ហោតិ ខន្តិកោ។

អ្នកអត់ធន់ ជាអ្នកនាំមកនូវប្រយោជន៍ដល់ខ្លួនផង ដល់ជនទាំងឡាយឯទៀតផង អ្នកអត់ធន់ជាអ្នកឡើងកាន់

ផ្លូវជាទីទៅស្ថានសួគ៌ និងព្រះនិព្វាន។

សត្ថុនោ វចនោវាទំ ករោតិយេវ ខន្តិកោ
បរមាយ ច បូជាយ ជិនំ បូជេតិ ខន្តិកោ។

អ្នកអត់ធន់ ឈ្មោះថា ធ្វើតាមនូវព្រះពុទ្ធដីកា ជាឱវាទនៃព្រះសាស្តាមែនពិត អ្នកអត់ធន់ ឈ្មោះថា បូជានូវព្រះវិជិតមារដោយការបូជាដ៏ឧត្តម។

ទុល្លភញ្ច មនុស្សត្តំ ពុទ្ធុប្បាទោ ច ទុល្លភោ
ទុល្លភា ខណសម្បត្តិ សទ្ធម្មោ បរមទុល្លភោ។

ភាវៈកើតជាមនុស្ស គឺសត្វទាំងឡាយ បានដោយកម្រ កិរិយាត្រាស់ជាព្រះពុទ្ធ គឺសត្វទាំងឡាយបានដោយកម្រ កិរិយាដល់ព្រមដោយខណៈ គឺបានកើតជួបនឹងព្រះពុទ្ធ ឬនឹងព្រះពុទ្ធសាសនា គឺសត្វទាំងឡាយ

បានដោយកម្រ ធម៌របស់សប្បុរស គឺសត្វទាំងឡាយបានដោយកម្រក្រៃលែង។

**សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ។**

កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្ដីសុខ កិរិយាសំដែងនូវធម៌របស់សប្បុរស នាំមកនូវសេចក្ដីសុខ សេចក្ដីព្រមព្រៀងគ្នារបស់សង្ឃ ឬពួកក្រុម នាំមកនូវសេចក្ដីសុខ សេចក្ដីព្យាយាមរបស់អ្នកដែលព្រមព្រៀងគ្នាទាំងឡាយនាំមកនូវសេចក្ដីសុខ។

**សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស បស្សតោ អព្យាបជ្ឈំ សុខំ លោកេ បាណភូតេសុ សញ្ញមោ។**

សេចក្ដីស្ងប់ស្ងាត់ របស់អ្នកដែលត្រេកអរ (ក្នុងទីស្ងាត់) ជាអ្នកមានធម៌បានស្ដាប់ហើយ ពិចារណាឃើញ

(នូវធម៌) នាំមកនូវសេចក្ដីសុខ កិរិយាបៀតបៀន គឺកិរិយាសង្រួមចំពោះសត្វទាំងឡាយ នាំមកនូវសេចក្ដីសុខក្នុងលោក។

**សុខា វិរាគតា លោកេ កាមានំ សមតិក្កមោ**
**អស្មិមានស្ស វិនយោ ឯតំ វេ បរមំ សុខំ។**

ភាវៈប្រាសចាករាគៈ គឺកិរិយាកន្លងនូវកាមទាំងឡាយ នាំមកនូវសេចក្ដីសុខក្នុងលោក កិរិយាធ្វើឱ្យវិនាស នូវអស្មិមានៈនេះឯង នាំមកនូវសេចក្ដីសុខដ៏ឧត្តម។

**កិច្ឆោ មនុស្សប្បដិលាភោ កិច្ឆំ មច្ចាន ជីវិតំ**
**កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ។**

កិរិយាត្រឡប់បានអត្តភាពជាមនុស្ស ជាការលំបាក សេចក្ដីរស់នៅ របស់សត្វទាំងឡាយ ជាការលំបាក កិរិយាស្ដាប់នូវព្រះសទ្ធម្មជាការកម្រ កិរិយាបានត្រាស់

នៃព្រះពុទ្ធទាំងឡាយ ជាការលំបាក។

សត្ថុនោ សទ្ធម្មំ សុត្វា សព្វស្មឹ ជិនសាសនេ
កប្បានិ សតសហស្សានិ ទុគ្គតឹ សោ ន គច្ឆតិ។

បុគ្គលឯណាបានស្តាប់នូវព្រះសទ្ធម្មរបស់ព្រះសាស្តា (ដែលរាប់បញ្ចូល) ក្នុងពាក្យប្រៀនប្រដៅនៃព្រះវិជិតមារទាំងពួង បុគ្គលនោះ រមែងមិនទៅកាន់ទុគ្គតិ អស់នៃសែនកប្ប។

បុព្វណ្ហេ បិណ្ឌបាតញ្ច សាយណ្ហេ ធម្មទេសនំ
បទោសេ ភិក្ខុឱវាទំ អឌ្ឍរត្តេ ទេវបញ្ហានំ
បច្ចូសេវ គតេ កាលេ ភព្វាភព្វេ វិលោកនំ ឯតេ
បញ្ចវិធេ កិច្ចេ វិសោធេតិ មុនិបុង្គវោតិ។

ព្រះសម្មាសម្ពុទ្ធ ជាចម្បងជាងអស់អ្នកប្រាជ្ញ ទ្រង់ជំរះនូវពុទ្ធកិច្ចទាំងឡាយ ៥ ប្រការនេះ គឺក្នុងពេលព្រឹក

ទ្រង់ស្ដេចទៅបិណ្ឌបាត ១ ក្នុងពេលល្ងាច ទ្រង់សំដែងធម៌ទេសនា ១ ក្នុងពេលព្រលប់ ទ្រង់ប្រទានឱវាទដល់ពួកភិក្ខុ ១ ក្នុងពេលអាធ្រាត្រ ទ្រង់ដោះប្រស្នានៃទេវតា ១ ក្នុងពេលជិតភ្លឺ [១] ទ្រង់ប្រមើលមើលនូវសត្វលោក ដែលគួរត្រាស់ដឹង និងមិនគួរត្រាស់ដឹង ១។

**កុក្កដេ គព្ភវាសោ ច សោណេ ចុទរនិក្ខមិ**
**ឱសភេ រាជសម្បត្តិ សសេ បព្វជិតោ ជិនោ។**

ព្រះវិជិតមារ ទ្រង់យាងចុះមកអាស្រ័យនៅក្នុងព្រះគភ៌ (នៃព្រះវរមាតា) ក្នុងឆ្នាំរកា ទ្រង់ប្រសូតិចាកព្រះគភ៌ក្នុងឆ្នាំច ទ្រង់សោយរាជសម្បត្តិក្នុងឆ្នាំឆ្លូវ ទ្រង់ព្រះផ្នួស ក្នុងឆ្នាំថោះ។

---

១-ក្នុងអដ្ឋកថាធម្មបទសំដែងថាព្រះអង្គប្រមើលមើលឧបនិស្ស័យសត្វ ក្នុង ១ថ្ងៃ ១យប់ ពីរដង គឺក្នុងពេលជិតភ្លឺម្ដង ពេលល្ងាចម្ដង ។ ពេលជិតភ្លឺ ទ្រង់ប្រមើលមើលពីកណ្ដាប់មាត់ចក្រវាឡ រហូតដល់មកគន្ធកុដិ ពេលល្ងាច ទ្រង់ប្រមើលមើលពីគន្ធកុដិ រហូតដល់កណ្ដាប់មាត់ចក្រវាឡ។ ប្រមើលមើលនូវសត្វលោកដែលគួរត្រាស់ដឹង និងមិនគួរ ត្រាស់ដឹង ១ ។

កុក្កុដេ សព្វញ្ញុពុទ្ធោ តត្ថ ចក្កំ បវត្តយិ
និព្វានគមនំ សប្បេ សហស្សំ បញ្ច មូសិកេ។

ទ្រង់ត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធ ក្នុងឆ្នាំរកា ទ្រង់សំដែងនូវព្រះធម្មចក្រ ក្នុងឆ្នាំនោះ ទ្រង់យាងចូលកាន់ព្រះនិព្វាន ក្នុងឆ្នាំម្សាញ់ ព្រះពុទ្ធសាសនា នឹងគ្រប់ ៥.០០០ គត់ ក្នុងឆ្នាំជូត។

ឱក្កន្តោ ច គរុវារស្មឹ សុក្រវារេ ច និក្ខមិ
សម្ពុទ្ធោ ពុធវារស្មឹ អង្គារេ បរិនិព្វុតោ។

ទ្រង់យាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃព្រហស្បតិ៍ ប្រសូតក្នុងថ្ងៃសុក្រ បានត្រាស់ជាព្រះសម្ពុទ្ធ ក្នុងថ្ងៃពុធ បរិនិព្វានក្នុងថ្ងៃអង្គារ។

អាសាឡ្ហបុណ្ណមោក្កន្តោ វិសាខេយេវ និក្ខមិ
វិសាខបុណ្ណមី សម្ពុទ្ធោ វិសាខេ បរិនិព្វុតោ។

ព្រះអង្គយាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា)ក្នុងថ្ងៃពេញបូណ៌មីខែអាសាឍ ប្រសូតិក្នុងថ្ងៃពេញបូណ៌មីខែវិសាខ បានត្រាស់ជាព្រះសម្ពុទ្ធ ក្នុងថ្ងៃពេញបូណ៌មី ខែវិសាខ បរិនិព្វានក្នុងថ្ងៃពេញបូណ៌មីខែវិសាខ។

**និព្វុតេ លោកនាថម្ហិ សម្ពុទ្ធេ អគ្គបុគ្គលេ បដិមា ពោធិរុក្ខា ច ថូបា ច ជិនធាតុយោ ចតុរាសីតិសហស្ស- ធម្មក្ខន្ធា សុទេសិតា អគ្គប្បវត្តនដ្ឋានេ ឋបិតា ហោន្តិ បាណិនំ។**

កាលព្រះសម្មាសម្ពុទ្ធជាអគ្គបុគ្គល ជាទីពឹងនៃសត្វលោកបរិនិព្វានទៅហើយ ព្រះបដិមាផង ព្រះពោធិព្រឹក្សផង ព្រះស្តូបផង ព្រះជិនធាតុផង ព្រះធម៌ ៨ ហ្មឺន ៤ ពាន់ធម្មក្ខន្ធ ដែលព្រះអង្គទ្រង់សំដែងហើយ ដោយប្រពៃផង ជាវត្ថុគឺព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកក្នុងស្ថាន ដ៏ប្រព្រឹត្តទៅដើម្បីជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វទាំងឡាយ។

ឥតិ សម្មាសម្ពុទ្ធេន ទេសិតំ ឱវាទំ ចិត្តេ ឋបេត្វា

សម្មាសម្ពុទ្ធេន វុត្តប្បការេន បដិបត្តិបូជាយ បូជំ

ករោន្តេន លោកិយលោកុត្តរសម្បត្តិសិទ្ធិំ កាតព្វំ

ឱកាស អារាធនំ ករោមិ។

បុគ្គលគួរដំកល់នូវឱវាទ ដែលព្រះសម្មាសម្ពុទ្ធទ្រង់

សំដែងហើយទុកក្នុងចិត្ត ហើយធ្វើការបូជាដោយបដិ-

បត្តិបូជា ដោយនូវប្រការដែលព្រះសម្មាសម្ពុទ្ធ ត្រាស់

សំដែងហើយ គួរធ្វើឱ្យសម្រេចនូវសម្បត្តិជាលោកិយ និង

លោកុត្តរ ខ្ញុំសូមគោរពអារាធនាទុក ដោយប្រការដូច្នេះ។

ឱកាស សិរីសក្យមុនិសព្វញ្ញុពុទ្ធស្ស ពល-វប្បច្ចូសសមយេ កុសិនារាយ យមកសាលាន-មន្តរេ អមុម្ហិ សប្បសំវច្ឆរេ គិម្ហ ឧតុម្ហិ វិសាខ-មាសេ សុក្កបក្ខេ បណ្ណរសិយា តិថិយំ ភុម្មវារេ ភុម្មយាមេ អនុរាធនក្ខត្តទិវសេ បរិនិព្វានំ អហោសិ អនុបាទិសេសាយ និព្វានធាតុយា។

ខ្ញុំសូមគោរព សម្តេចព្រះសិរីសក្យមុនីសព្វញ្ញុពុទ្ធជាម្ចាស់ទ្រង់បរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ក្នុងចន្លោះសាលព្រឹក្សទាំងគូ ជិតក្រុងកុសិនារា ក្នុងបច្ចូសម័យ ដ៏មានកម្លាំង ក្នុងថ្ងៃនៃនក្ខត្តឫក្ស ឈ្មោះអនុរាធា ក្នុងថ្ងៃអង្គារ យាមអង្គារ ជាតិថីពេញបូណ៌មីខាងខ្នើត ខែវិសាខ ក្នុងគិម្ហ-រដូវ ឆ្នាំម្សាញ់ឯណោះហោង។

(តពីនេះទៅ ត្រូវបកសករាជប្រាប់ថ្ងៃ ខែ ឆ្នាំ ដែលជាអតីតៈ បច្ចុប្បន្ន និងអនាគត ដរាបដល់ចប់)។

# បច្ឆិមពុទ្ធវចនះ

យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ។ ម្នាលអានន្ទ សភាវៈឯណា គឺព្រះធម៌ក្តី ព្រះវិន័យក្តី ដែលតថាគតបានសំដែងហើយ បានបញ្ញត្តហើយដល់អ្នកទាំងឡាយ។

សោ វោ មមច្ចយេន សត្ថា សភាវៈ គឺព្រះធម៌ និងព្រះវិន័យនោះ លុះអំណើះតអំពីតថាគតទៅហើយ នឹងបានជាគ្រូប្រៀនប្រដៅនូវអ្នកទាំងឡាយ។

អហំ ឯកកោវ បរិនិព្វាយិស្សាមិ តថាគតជាព្រះពុទ្ធមួយអង្គឯងពិត នឹងបរិនិព្វានទៅ។

អហញ្ច បនិទានិ ឯកកោវ ឱវទាមិ អនុសា-សេមិ តែថា ឥឡូវនេះ តថាគតជាព្រះពុទ្ធមួយអង្គឯង

ពិត តែងទូន្មានប្រៀនប្រដៅនូវអ្នកទាំងឡាយ។

មយិ បរិនិព្វុតេ កាលបើតថាគតបរិនិព្វានទៅហើយ។ ឥមានិ ចតុរាសីតិសហស្សធម្មក្ខន្ធានិ តុម្ហេ ឱវទិស្សន្តិ អនុសាសិស្សន្តិ ព្រះធម្មក្ខន្ធ ៨ ហ្មឺន ៤ ពាន់នេះ នឹងទូន្មានប្រៀនប្រដៅនូវអ្នកទាំងឡាយជាខាងក្រោយ។

យោ កោចិ អានន្ទ ភិក្ខុ វា ភិក្ខុនី វា ឧបាសកោ វា ឧបាសិកា វា ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិ បដិបន្នោ អនុធម្មចារី ម្នាលអានន្ទ បុគ្គលឯណាមួយ គឺភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិធម៌វិន័យតាមសមគួរដល់ធម៌វិន័យ ជាអ្នកប្រតិបត្តិដោយសេចក្តីគោរព កោតក្រែងដល់ធម៌វិន័យ ប្រព្រឹត្តតាមធម៌វិន័យជាប្រក្រតី។

សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ បដិបត្តិបូជាយ បុគ្គលទាំងអស់នោះ បានឈ្មោះថា ធ្វើសក្ការៈនឹងតថាគត ធ្វើនូវសេចក្តីគោរព រាប់អាន បូជានូវតថាគត ដោយបដិ-បត្តិបូជា ជាបូជាយ៉ាងក្រៃលែង។

ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ ភិក្ខវេ ខយវយធម្មា សង្ខារា អប្បមាទេន សម្បាទេថា-តិ ឥទម្បច្ឆិមពុទ្ធវចនំ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះតថាគតនឹងផ្តាំនូវអ្នកទាំងឡាយ ឱ្យបានដឹងគ្រប់គ្នា នៃភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មានកិរិយាអស់ទៅ និងសាបសូន្យទៅជាធម្មតា។ អ្នករាល់គ្នា ចូរញុំាងប្រយោជន៍ឱ្យដល់ព្រមដោយអប្បមាទៈ គឺការមិនបណ្តែតបណ្តោយក្នុងធម៌វិន័យ ពាក្យប្រៀនប្រដៅ មានប្រមាណប៉ុណ្ណេះ

ជាដើមនេះ ឈ្មោះថា បច្ឆិមពុទ្ធវចនៈ ជាពាក្យផ្ដាំពៅបំផុតរបស់ព្រះពុទ្ធជាម្ចាស់នៃយើង។

**ឧភិន្នមន្តរេ យំ វុត្តំ ឯតំ មជ្ឈិមពុទ្ធវចនំ** ពាក្យប្រដៅឯណា ដែលទ្រង់ត្រាស់ពោលជាចន្លោះនៃបឋមពុទ្ធវចនៈ និងបច្ឆិមពុទ្ធវចនៈ ទាំងពីរនេះ ពាក្យប្រដៅនោះ ឈ្មោះថា មជ្ឈិមពុទ្ធវចនៈ គឺពាក្យប្រដៅជាកណ្ដាលរបស់ព្រះពុទ្ធ ជាបរមគ្រូ (នៃយើង)។

ចប់បច្ឆិមពុទ្ធវចនៈ

# ពាក្យប្រកាសស្ដាប់ព្រះធម៌ទេសនា

១-អហំ រីខ្ញុំម្ចាស់ សូមឱកាសក្រាបប្រណិបត្តិ
ដល់អស់ពួកបរិស័ទ ដែលលះកាត់ក្ដីកង្វល់។
២-ហើយមកប្រជុំគ្នា ព្រោះប្រាថ្នាយកកុសល

ហេតុនេះសូមតំកល់ តាំងចិត្តស្តាប់ធម៌ទេសនា។
៣.ដើម្បីជាការបុណ្យ និងជាគុណច្រើនណាស់ណា
អំណាចស្តាប់ទេសនា ដោយជ្រះថ្លាក្នុងសន្តាន។
៤.សូមតាំងចិត្តឱ្យស្អាត ខ្ញុំអារាធនាថ្កាន
និមន្តលោកនិទាន ទេសទូន្មានយើងរាល់គ្នា។
៥.ហេតុនេះសូមបរិស័ទ ដែលប្រណិបត្តិគាល់ត្រៀបត្រា
កុំពោលកុំចរចារ និយាយគ្នាបែរមុខក្រោយ។
៦.សូមផ្ចង់នូវសញ្ញា ផ្ទៀងសោតាស្តាប់កុំធ្វេយ
ទើបនឹងបានផលសោយ អានិសង្សប្រាំប្រការ។

# ព្រហ្មធំ

១. វីព្រហ្មដ៏ជាធំ ក្រៃលែងព្រហ្មផងនានា
ទើបលុតព្រះជង្ឃា លើកហត្ថានមស្ការ។
២.បពិត្រព្រះអង្គអើយ ព្រះគុណអើយសូមមេត្តា
ប្រោសសត្វមនុស្សទេវតា ទ្រង់ករុណាសំដែងធម៌
៣.ត្បិតសត្វទន្ទឹងណាស់ ឮព្រះត្រាស់ហើយត្រេកអរ

នឹងបានស្តាប់ព្រះធម៌ ហើយនឹងចរចេញចាកទុក្ខ។

៤_ត្បិតសត្វផងនានា មានអវិជ្ជាពោលគឺល្អក់

ធូលីផង់ដីភក់ កករល្អក់ជាប់នេត្រា។

៥_ព្រោះហេតុមោហធម៌ វិតរួបរុំជុំកាយា

បិទបាំងអាប់ប្រាជ្ញា មិនឱ្យឃើញព្រះត្រៃលក្ខណ៍។

៦_ងងឹតងងល់ងប់ ឱ្យជ្រុលជ្រប់ដូចមនុស្សខ្វាក់

លលើហើយលលាក់ ដូចអន្ទាក់ធ្លាក់វិតក។

៧_នឹងរកអ្នកណាមួយ នឹងមកជួយស្រាយក៏ក្រ

មានបន់តែព្រះធម៌ ទើបនឹងមកជួយស្រាយបាន។

៨_ហេតុនេះព្រះអង្គអើយ ព្រះគុណអើយសូមប្រោសប្រាណ

ដ្បិតព្រហ្មខ្ញុំរាប់អាន ចុះមកថ្កានអារាធនា។

៩_ព្រះធម៌ថ្លៃវិសេស លត់កិលេស និងតណ្ហា

នាំចិត្តឱ្យជ្រះថ្លា សោមនស្សាឥតសៅហ្មង។

១០_ហេតុនេះព្រះអង្គអើយ ព្រះគុណអើយសូមចម្លង

នាំសត្វឱ្យបានឆ្លង ដាក់ដល់ត្រើយនិព្វាននាយ។

# ធម៌អដ្ឋង្គិកមគ្គ

អដ្ឋង្គិកមគ្គទាំងប្រាំបី ជាផ្លូវព្រះអរិយៈទាំងឡាយ
ដំណើរដោយល្អតែងនាំកាយ ទៅកាន់ប្រឡាយព្រះនិព្វាន។
១.សម្មាទិដ្ឋិឃើញផ្លូវស្រេច គឺព្រះអរិយសច្ចទាំង ៤ មាន
ឃើញមែនឃើញពិតព្រះនិព្វាន ឃើញសុខសឹងគ្មានទោសទុក្ខា។
២.វីអង្គសម្មាសង្កប្បោនេះ តម្រិះដែលត្រិះត្រង់ឧស្សាហ៍
រារុញធុញថប់ក្តីប្រាថ្នា ចិន្តាចង់ជៀសចាកកាមគុណ។
៣.សម្មាវាចាពោលពាក្យពិត សុចរិតមិនពោលមុសាស៊ុន
មិនស៊កមិនសៀតឆ្មៀងពាក្យធ្ងន់ ពាក្យណាជាគុណថ្លែងចរចារ។
៤.សម្មាកម្មន្តោធ្វើការត្រូវ ជៀសផ្លូវមេថុនមិនប្រាថ្នា
មិនលបមិនលួចទ្រព្យនរណា បាណាជៀសមិនសម្លាប់សត្វ។
៥.សម្មាអាជីវោកាន់សុចរិត ចិញ្ចឹមជីវិតគិតប្រយ័ត្ន
មិនលក់មិនជួញមនុស្សនិងសត្វ បំបាត់ជំនួញប្រាំប្រការ។
៦.សម្មាវាយាមោព្យាយាមនៅ ធ្វើត្រូវមិនឱ្យធ្លោយប្រាថ្នា
ព្យាយាមរវាំងបាំងអកុសលា មិនឱ្យខ្លាំងក្លាកើតឡើងបាន។

៧.ព្យាយាមលះបាបដែលមានហើយ មិនធ្វើកន្តើយឱ្យរំខាន
រំលត់ឱ្យផុតចាកសន្តាន មិនឱ្យកើតមានក្តីវេទនា។
ព្យាយាមញ៉ាំងកុសលដែលមានពិត ឱ្យវិតចំរើនច្រើនមហិមា
សម្មាសតិតាំងសទ្ធា ភាវនារំឭកក្នុងរាងកាយ។
បញ្ញាពិចារណានឹករឿយៗ ក្នុងចិត្តព្រួយហើយនឹកនឿយណាយ
អនិច្ចំ ទុក្ខំ ទុក្ខក្នុងកាយ គ្មានខ្លឹម និងស្រាយអង្គអនត្តា។
៨.សម្មាសមាធិធ្វើចិត្តត្រូវ ហើយតាំងភ្ជាប់នៅកម្មដ្ឋានណា
ធ្វើឈានឱ្យបានដោយបញ្ញា ឱ្យបានឯកគ្គតាជាប្រធាន។

# ធម៌ផ្ចាញ់មារ

កាលអង្គព្រះសាស្តា ផ្ចាញ់កូនមារចាញ់អន្តរាយ
វិនាសប្រាសខ្ចាត់ខ្ចាយ ខ្ចាត់ទៅឆ្ងាយដោយញាណញេយ្យ។
ស្រាប់តែមារលើកពល ចូលមកដល់ជាច្រើនក្រៃ
រសៀលពេលល្ងាចថ្ងៃ ជិះដំរីមេខលា។
ព្រះអង្គឃើញដោយឈាន គឺកម្មដ្ឋានវិបស្សនា
និមិត្រពីរមាត្រា បតិភាគឧគ្គហះ។

លោភៈជាដំរី មារអប្រិយគឺទោសៈ
ចិត្តខឹងជាតួយក្ខ មកសត្រូវនឹងឈានប្រាំ។
មោហៈគឺមារា មកពាធាបីតិ ៥
បែងដៃច្រើនឆ្វេងស្តាំ គឺកោធៈខឹងនឹងរោគ។
រោយខ្នងរោយចង្កេះ ណែនស្មើរប្រេះក្នុងកាយលោក
ស្ពឹកជើងបែកញើសជោក ដាលកព្រឺ្សាកក្នុងព្រះអង្គ។
ធ្វើឈានបហានៈ ធម៌តបៈទាញតម្រង់
ធ្វើចិត្តឱ្យស្លូតត្រង់ កងពលមារជាង ១ ពាន់។
កិលេសប្រាំរយសុទ្ធ ព្រះសម្ពុទ្ធចាប់ជិះជាន់
ព្រះអង្គទ្រង់គិតទាន់ រួមតណ្ហា ១០៨។
ព្រមទាំងឧបាទាន ទ្រង់វាយច្រានដោយបារមី
កុសលព្រះជិនស្រី វាយបណ្តេញអស់តែម្តង។
អកុសលធម៌លាមក វាមកថ្ពក់រកចំណង
ព្រះអង្គចាប់មកក្រង ធម៌ជាកងទុកដោយខ្លួន។
អរិយសច្ច ព្រហ្មវិហារ ចែកប្រការមានបួនៗ
អាសវៈអន្លង់ ៤ វាច្រមុចអរិយសច្ច។

អគតិបួននោះ វារួមសមគ្គា
ឱយៈកាច់ទាញព្រហ្មវិហារ ផ្តាច់ទំលាក់ទៅអបាយ ៤។
បួន១ គ្រប់ ៣ ដង ដប់ពីរផងឱ្យខ្ជាប់ខ្ជួន
អរិយសច្ច ៤ ព្រហ្មវិហារជាប្រាំបី។
ចិត្តល្អមានតិចទេ អាក្រក់តែដេសដាស់
ដីរួមធម៌ប្រាប់ពេញទី ដប់ប្រាំទៀតចង្អៀតពេញ។
ខន្ធប្រាំនិងកាមគុណ វាកើតមុនមិនព្រមចេញ
នីវរណៈ ៥ ត្រួត វិញវាយបណ្តេញបីតិ ៥ ។
មិនឈ្នះតួអង្គឈាន ទ្រង់ក្លាហានប្រឹងបរិកម្ម
ស្រាប់តែវាទៅនាំ ធម៌ប្រាំមួយចូរមកទៀត។
កិលេសនិងតណ្ហា បីដូចគ្នាមកបៀតបៀន
ប្រាំមួយក្រុមមកទៀត មកបំផ្លាញត្រៃលក្ខណ៍បី។
ព្រះអង្គទ្រង់ខំច្បាំង ដោយសច្ចៈ និងខន្តី
លើកយកធម៌ទាំងបី សីល សមាធិ បញ្ញា។
ទ្រង់គង់លើបល្ល័ង្ក ទ្រង់ខំតាំងអានាបាណ៍
ឃើញមារមកតវ៉ា យកបល្ល័ង្ករូបព្រះពុទ្ធ។

កន្លែងមារធ្លាប់នៅ ពេលមារទៅមារស្រយុត
កិលេសវាខ្លាំងផុត ស្ដាយរូបកាយរបស់វា។
វាសួរថា សិទ្ធត្ថ ដេញកំចាត់យើងទៅណា
ព្រះអង្គលើកហត្ថា ចុចផែនដីជាកសិណ។
មារនៅក្នុងដីហ្នឹង បើដឹងរសសម្លេងក្លិន
ឃើញដីរូបមិនជិន ដីត្រូវការសេពនូវកាម។
បើដីចេះខឹងអរ ចូរអ្នកចរវាយប្រាស់ប្រាម
បើដីសើចយំតាម មារឯងនៅក្នុងដីទៅ។
ចំណែកតថាគត បានរំលត់គ្មានសល់នៅ
រូបរសក៏មិនត្រូវ ក្លិនសម្ផស្សសម្លេងឡើយ។
សច្ចៈ និងខន្តី ជាបារមីបានដល់ត្រើយ
ព្រះអង្គគង់កន្តើយ ទ្រង់ព្រះនាមអរហំ។
ឆ្ងាយចាកសឹកសត្រូវ កិលេសទៅលែងជាខ្មាំង
តួធម៌ព្រះអរហំ ផុសកណ្ដាលព្រះឱរា។
ឆព្វណ្ណរង្សី ដូចស្រ្ដីស្រស់ពុំងារ
បុរាណឱ្យឈ្មោះថា នាងគង្ហីងព្រះធរណី។

ច្បូតសក់ឱ្យចេញទឹក ជនសន្និកជាជលធី
សឹងមាននៅក្នុងទី បរមត្ថលោកសំដែង។
គឺស្បូតទឹកព្រះទ័យ ជ្រាបញ្ញាណញៀវដោយអង្គឯង
ផ្សាយចិត្តគ្រប់កន្លែង ក្នុងត្រៃលោកកើតវិជ្ជា។
ប្រកាសពេញអក្ខរៈ តាមមគធៈជាភាសា
ដែលយើងរៀនរាល់គ្នា គឺអនេកជាតិនោះ។
រៀបរាប់ជាតិកំណើត ស្លាប់ហើយកើតគ្មានចន្លោះ
សព្វដីសព្វកៀនកោះ ទឹកប់ខ្មោចរបស់ខ្លួន។
ទឹកលិចហូរចំហុត សីលបរិសុទ្ធយ៉ាងមាំមួន
ទឹកសីលហូរសំនួន លិចពលមារគឺកិលេស។
ក្រពើធ្លាមម្ករ ផ្អើលឈ្លូវរធរកុំប្រហែស
បីតិកើតភ្លីថែស គឺសោតា សកទា។
អនាគាមគ្គផល ដេញតាមដល់អភិញ្ញា
អរហត្តដេញទល់គ្នា គឺមគ្គផលស៊ីកិលេស។
មិនមែនធ្លាមតិរច្ឆាន ធ្លាមកម្មដ្ឋានជាពិសេស

ចូរអ្នកកុំប្រហែស ខំផ្ចាញ់មាររបស់ខ្លួន។
កុំផ្ចាញ់មារឱ្យព្រះ ដែលទ្រង់ឈ្នះហើយខ្ជាប់ខ្ជួន
មារានៅក្នុងខ្លួន ម្ដេចអាចារ្យមិនខំផ្ចាញ់។
ត្រូវមើលច្បាប់ឱ្យល្អះ ព្រះពុទ្ធឈ្នះចិត្តកំណាញ់
ឈ្នះអាក្រក់ ឈ្នះស្រឡាញ់ ឈ្នះសប្បាយលែងមានភ័យ។

(ធម៌នេះគេចំលងតាមចាំមាត់)

# ធម៌ឧទ្ទិសកុសល

ទានដែលខ្ញុំបានធ្វើហើយ ព្រះគុណអើយខ្ញុំសច្ចា
ឧទ្ទិសផលនេះណា ជូនមាតាបិតាខ្ញុំ។
ជីដូននិងជីតា គ្រូអាចារ្យទាំងតូចធំ
ញាតិមិត្តគ្រប់និគម មកជួបជុំទទួលផល។
ដែលកូនចៅបានធ្វើ នូវអំពើជាកុសល
សូមទានឱ្យបានដល់ ទោះមណ្ឌលឆ្ងាយយ៉ាងណា។
កុសលទាំងអស់ហ្នឹង សូមទីពឹងលើទេវតា
សូមមានចិត្តមេត្តា នាំផលាទាំងអស់នេះ។
ទៅជូនឱ្យខ្ញុំផង ដូចបំណងកុំបីធ្វេស

កូនចៅនៅឯណោះ មិនប្រហែសបញ្ជូនមក។
សូមមានចិត្តរីករាយ ដោយសប្បាយទទួលយក
កូនចៅបានលៃលក បញ្ជូនមកគ្រប់ៗគ្នា។
ដើម្បីសោយផលទាន សូមឱ្យបាននៅសុខជា
កូនចៅទាំងអស់គ្នា បានបូជាជូនទៅហោង។

## ខមាទោសចំពោះព្រះពុទ្ធព្រះធម៌ និងព្រះសង្ឃ

១.កាយេន វាចាយ វ ចេតសា វា ពុទ្ធេកុ-កម្មំ បកតំ មយា យំ ពុទ្ធោ បដិគ្គណ្ហតុ អច្ចយន្តំ កាលន្តរេ សំ វរិតុំវ ពុទ្ធេ។

-កម្មណាដែលខ្ញុំធ្វើ អាក្រក់លើព្រះពុទ្ធពិត
ដោយកាយវាចាចិត្ត ទុច្ចរិតឥតបារម្ភ។
-ពុទ្ធោសូមព្រះពុទ្ធ ទ្រង់អំណត់អត់ទោសខ្ញុំ
ខុសឆ្គងព្រះពុទ្ធកុំ យកទោសខ្ញុំតទៅទៀត។
-ដើម្បីនឹងសង្រួម រវាងព្រមមិនឱ្យឃ្លាត
សូមជួបព្រះពុទ្ធទៀត ឱ្យបានសព្វកាលទៅហោង។

២.កាយេន វាចាយ វ ចេតសា វា ធម្មេកុ-
កម្មំ បកតំ មយាយំ ធម្មោ បដិគ្គណ្ហតុ អច្ចយន្តំ
កាលុន្តរេសំ វ វិត្តុំវ ធម្មេ។

-កម្មណាដែលខ្ញុំធ្វើ　　អាក្រក់លើព្រះធម៌ពិត
ដោយកាយវាចាចិត្ត　　ទុច្ចរិតឥតបារម្ភ។
-ព្រះធម៌ជាមង្គល　　ទ្រង់អំណត់អត់ទោសខ្ញុំ
ខុសឆ្គងព្រះធម៌កុំ　　យកទោសខ្ញុំតទៅទៀត។
-ដើម្បីនឹងសង្រួម　　រវាងព្រមមិនឱ្យឃ្លាត
សូមជួបព្រះធម៌ទៀត　　ឱ្យបានសព្វកាលទៅហោង។

៣.កាយេន វាចាយ វ ចេតសា វា សង្ឃេ-
កុកម្មំ បកតំ មយាយំ សង្ឃោ បដិគ្គណ្ហតុ
អច្ចយន្តំ កាលុន្តរេសំ វ វិត្តុំវ សង្ឃេ។

-កម្មណាដែលខ្ញុំធ្វើ　　អាក្រក់លើព្រះសង្ឃពិត
ដោយកាយវាចាចិត្ត　　ទុច្ចរិតឥតបារម្ភ។

-ព្រះសង្ឃអង្គបរិសុទ្ធ　　ទ្រង់អំណត់អត់ទោសខ្ញុំ
ខុសឆ្គងព្រះសង្ឃកុំ　　យកទោសខ្ញុំតទៅទៀត។
-ដើម្បីនឹងសង្រួម　　រវាំងព្រមមិនឱ្យឃ្លាត
សូមជួបព្រះសង្ឃទៀត　　ឱ្យបានសព្វកាលទៅហោង។

# ឧទ្ទិសកុសលទាន

វីផលទានសីល　　ខ្ញុំសូមផ្ដាច់ផ្ដិល　　មន្ទិលទោសា
ឱ្យទានថ្មីៗ　　ដោយក្ដីជ្រះថ្លា　　ដោយកាយវាចា
　　ចិត្តឥតហ្មងសៅ។
វីផលទាននោះ　　ខ្ញុំសូមឧទ្ទិស　　ចំពោះជូនទៅ
មាតាបិតា　　គ្រូអាចារ្យញាតិផៅ ទោះស្លាប់រស់នៅ
　　បានដូចបំណង។
វីផលទាននេះ　　ទុកជាជំនិះ　　ជិះកាត់ចំលង
ឱ្យបានរួចទុក្ខ　　ទាំង១២កង　　សោយសុខកន្លង
　　ដល់ឋាននិព្វាន។

# ធម៌ខន្តីលះទោសៈ

សូមលាទោសៈ ថ្នាំងថ្នាក់អាក្រក់ ខឹងហើយតក់ម៉ក់

សម្ញឹងទោសគេ តែខឹងច្រើនដង សៅហ្មងឡើងទ្វេ

នេះហើយជាមេ នាំទៅអបាយ តែខឹងញយៗ

បែកមិត្តអន្តរាយ ធម៌រត់ខ្ចាត់ខ្ចាយ ចេញអស់ពីខ្លួន

ក្នុងទ្រូងដំបៅ ឈឺក្តៅផ្សួនៗ ដូចគេអង្រួន

លើសគេវាយដំ អ្នកណាហ៊ានខឹង អ្នកនោះខុសធំ

ដូចគេគុំនំ ដំដើមទ្រូងឯង ទោសៈនោះខ្លាំង

កម្លាំងក្រៃលែង ឱ្យតែដុះវែង គ្មានអ្វីខ្លាំងដូច។

ត្រូវកាត់ពីតិច ត្រូវក្តិចពីតូច ខំអត់ឱ្យរួច

ផុតទោសដែលខឹង។

អ្នកប្រាជ្ញបុរាណ បានឱ្យដំណឹង ថាអ្នកមិនខឹង

ទើបបានខន្តី។

ឱ្យគេឈ្នះចុះ យើងកុំថាអ្វី មិនខឹងមិនស្តី

ខន្តីបានយើង។

ខន្តីជាទ្រព្យ គួរគាប់ចុំថ្កើង ខន្តីកើតឡើង
ក្នុងលោកទាំងមូល។
ខន្តីជាឫស ផុះជាបណ្តូល ខន្តីជាមូល
មេធម៌ទាំងអស់។
ខន្តីជាស្ពាន ជាយានសប្បុរស អ្នកប្រាជ្ញទាំងអស់
អាស្រ័យខន្តី។
ទៅសួគ៌និព្វាន គ្មានទៅដោយអ្វី ដោយធម៌ខន្តី
ជាស្ពានដំណើរ។
ខន្តីជាសុខ ស្រណុកប្រសើរ មិនចាំបាច់ធ្វើ
ទ្រព្យហូរចូលឯង។
ខន្តីជាទ្រព្យ ប្រដាប់តាក់តែង អ្នកផងកោតក្រែង
ស្ញប់ស្ញែងគ្រប់គ្នា។
ជាទីស្រឡាញ់ នៃមនុស្សទេវតា ឈប់នៅទីណា
បានលាភគ្រប់យ៉ាង។
សូមទានលោកអ្នក ដែលមានសំណាង ធ្វើបុណ្យកសាង
ទានសីលភាវនា។

សមថកម្មដ្ឋាន សមាធិនេះក្តី បើចោលខន្តី
គ្មានអ្វីទីតាំង។
សូមបញ្ចប់ បញ្ជាក់ធម្មំ ធម្មោងវំ
និដ្ឋិតំចប់ហើយ។

# រំលឹកគុណមាតាបិតា

បពិត្រលោកអ្នកមាតាបិតា កូននឹកខ្លោចផ្សាពេកអំបាយ
តាំងពីកូនកើតមានរូបកាយ អ្នកតែងខ្វល់ខ្វាយថែរក្សា។
ឱះ ឱម្ចាស់ថ្លៃវិសេសលន់ ម៉ែរងទុក្ខធ្ងន់ពន់ពេកណា
ព្រោះអ្នកផ្តេកផ្តិតកូនពុំងា ពុំអាចពណ៌នាឱ្យអស់បាន។
ដូច្នេះកូនសូមផ្គងអញ្ជលី លើកហត្ថទាំងពីរបន្ទន់ប្រាណ
បង្គំបាទាព្រះក្សេមក្សាន្ត ទោះខុសប៉ុន្មានសូមប្រណី។
ម្ចាស់អើយកាលកូនទ្រហោយំ ម៉ែស្ទុះមកថ្នមត្រកងបី
ច្រៀងបំពេរកូនដោយប្រិមប្រិយ មានមេត្រីផ្តេកកូនណា។
ទឹកមូត្រទឹកមាត់លាមកផង នឹងគ្រឿងសៅហ្មងផងនានា
ម៉ែចាប់ម៉ែកាន់ម៉ែស្រវា លាងដោយហត្ថាឥតជិនឆ្អន់

បពិត្រអ្នកម្ដាយមានករុណា       បិតាមានគុណវិសេសលន់
កូនសូមគោរពព្រះគុណធ្ងន់  សូមព្រះសោភ័ណបានក្សេមក្សាន្ត។
ហេតុនេះកូនសូមឧទ្ទិសផល តម្កល់ចេតនាដោយក្លាហាន
ទានសីលភាវនាទាំងប៉ុន្មាន  ដែលកូនបានសាងជូនទៅអ្នក
សូមលោកទទួលដោយសោមនស្ស ចិត្តកូនត្រង់ស្មោះចំពោះជាក់
ដូចកូនបានពោលពាក្យសច្ចៈ ជូនទៅលោកអ្នកគ្រានេះហោង។

សូមឱ្យអ្នកទាំងឡាយ               សុខសប្បាយទាំងអស់គ្នា
កុំឱ្យមានរោគា                    ព្រមទាំងញាតិសាច់សន្ដាន។
ចូរខំប្រឹងប្រព្រឹត្ត                  សាងសុចរិតធម៌ឱ្យបាន
សព្វថ្ងៃសាសនាមាន               ខំប្រឹងរៀនសីលភាវនា។
កើតមកក្នុងលោកីយ៍               ទាំងប្រុសស្រីមានវាសនា
ខំរៀនសូត្រធម៌អាថ៌                ទាន់សាសនាព្រះទ្រង់ញាណ។
ដ្បិតយើងមិនស្គាល់ផ្លូវ              នឹងដើរទៅកាន់និព្វាន
ជាទីសុខក្សេមក្សាន្ត               លះបង់បានចាកមន្ទិល។
*វីអ្នកម្ចាស់ទាន       ដែលអ្នកមានចិត្តជ្រះថ្លា ជូនទានខ្ញុំនេះណា

សូមបានសំរេចផល ឱ្យបានដល់សួគ៌និព្វាន សូមឱ្យអ្នកបានសុខ តទៅមុខចេះតែមាន រីផលអ្នកម្ចាស់ទាន អ្នកបានបរិបូរណ៍ហោង។

*កុសលកម្ម តិចតួចឯណា ដែលខ្ញុំជ្រះថ្លា ហើយខ្ញុំបានធ្វើ ដោយកាយវាចា ចិត្តខ្ញុំអើពើ គួរនាំទៅលើ កើតឋានត្រៃត្រិង្ស សត្វមានសញ្ញា ឯណាបានដឹង បុណ្យដែលខ្ញុំប្រឹង ខំធ្វើនេះក្តី សូម្បីពួកសត្វ ជាអសញ្ញី ក៏ខ្ញុំគប្បី ចែកបុណ្យនេះឱ្យ ថាបើពួកសត្វ នោះមិនដឹងហើយ ក៏ខ្ញុំសូមឱ្យ ទេវតាមានឫទ្ធិ អញ្ជើញទៅប្រាប់ ទៅដាស់តឿនចិត្ត ដោយក្តីអាណិត សត្វក្នុងលោកា ឱ្យបានដឹងហើយ ដោយចិត្តមេត្តា ត្រេកអរគ្រប់គ្នា ក្នុងលោកទាំងមូល សូមមានអាហារ រស់នៅដោយស្រួល ដោយបានទទួល ផលបុណ្យនេះហោង។

# គុណម្តាយមាតាបិតា

កូនអើយកាលម្តាយនៅពីក្មេង និងឪពុកឯងសែនវេទនា
ខំប្រឹងចិញ្ចឹមកូនពុំងា ឥឡូវក្លាយជាមនុស្សឥតន័យ។
ចិត្តចង់រៀនសូត្រនូវធម៌អាថ៌ រក្សាសីលប្រាំ សីលប្រាំបី

ជាប់ចិត្តនឹងកូនស្ងួនពិសី     រៀនធម៌វិន័យមិនចេះចាំ។
កម្មក្រាស់ខ្លាំងណាស់និងតណ្ហា  មាតាបិតាប្រាថ្នាខ្លាំង
ចង់បានភោគទ្រព្យដោយកម្លាំង ទុកគ្រាន់ចែកកេរ្តិ៍កូនប្រុសស្រី។
កូនរៀនសូត្របានចេះដឹង     មិនឱ្យល្ងិតល្ងង់ក្នុងលោកីយ៍
រៀបគូរភរិយា និងស្វាមី     តាមច្បាប់វិន័យពីបុរាណ។
នឹកសង្ឃឹមថាខ្លួនចាស់ទៅ     រំពឹងទៅលើកូនកល្យាណ
ថាមុខនឹងជួយខ្លួនវិញបាន     ក៏សំរាកប្រាណភ្លេចអាត្មា។
លុះដល់ខ្លួនចាស់កម្លាំងស្រុត   ទើបបានតក់ស្លុត់នឹងសង្ខារ
ក៏ចាប់តាំងរៀនធម៌អាថ៌     ឯរូបកាយាដេកដួលហើយ។
រំពឹងទៅលើកូនប្រុសស្រី     បានប្រពន្ធប្តីធ្វើព្រងើយ
គេខំរកស៊ីធ្វើកន្តើយ     ព្រះអើយនេះហើយគួរអនិច្ចា។
កូនអើយនេះហើយកម្មឪពុកម្តាយ  ស្មានថារូបកាយមានខ្លឹមសារ
គ្មានធម៌អនិច្ចំនិងទុក្ខា     ឥឡូវនេះណាជរាហើយ។
ព្យាធិចុកចាប់សព្វរាងកាយ    ធ្វើឱ្យរូបម្តាយចុកគ្រាំគ្រា
ពុំមានធម៌ណាមកភាវនា     កាលខ្លួននៅជាធ្វេសប្រហែស។
រំពឹងអាចារ្យឱ្យពុទ្ធោ     ត្រចៀកក៏ហ៊ឹងស្តាប់មិនច្បាស់

ខ្លួនឯងមិនដែលយល់ធម៌ព្រះ   ទោះជាពូច្បាស់ថាមិនត្រូវ។
មិនបានហាត់កាយវាចាចិត្ត   ឱ្យបានសុចរិតទៅតាមផ្លូវ
ឱវាទព្រះពុទ្ធប្រៀនប្រដៅ   ឥឡូវធ្លាក់ខ្លួនជិតមរណា។
មុននឹងមរណៈខ្ញុំសូមផ្ដាំ   ប្រុសស្រីចងចាំស្ដាប់ឱ្យច្បាស់
ជរា ព្យាធិ និងមរណៈ   គេមិនបញ្ឆាក់សួរចិត្តឡើយ។
រុករានទន្ទ្រានយករាល់ថ្ងៃ   គួរខំកែខៃកុំព្រងើយ
ធ្វេញបាក់សក់ស្កូវអស់ទៅហើយ   ម្ដេចឡើយនៅតែមិនដឹងខ្លួន។
គួរតែធ្វើទានរក្សាសីល   ភាវនាកុំខ្ជិលឱ្យមាំមួន
កុំធ្វើដូចខ្ញុំ ខ្ញុំខុសខ្លួន   ព្រោះតែកូនស្ងួនទាំងប្រុសស្រី។
ខ្ញុំសូមផ្ដែផ្ដាំចាំឱ្យច្បាស់   នូវធម៌ត្រៃលក្ខណ៍ជាវិន័យ
អនិច្ចំមិនទៀងរៀងរាល់ថ្ងៃ   ទុក្ខអ្វី ទុក្ខអ្វី ទុក្ខឥតស្បើយ។
អនត្តាប្រែថាមិនមានខ្លួន   ពិតជាមិនមែនខ្លួនយើងឡើយ
បើរបស់ខ្លួនឃាត់បានហើយ   ម្ដេចឡើយមិនស្ដាប់បង្គាប់យើង
ថាតែប៉ុណ្ណេះបាត់ស្មារតី   ធាតុក្ដៅចេញផុតដល់ចុងជើង
ឯកូនប្រុសស្រីឆោរឡោឡើង   ឪពុកម្ដាយយើងគាត់ស្លាប់ហើយ។
ស្ដាយអើយសែនស្ដាយគាត់ស្លាប់ទៅ   កូនចៅមិនទាន់បានដឹងគុណ

មាតាបិតាមានគុណធ្ងន់ រកអ្វីប្រៀបផ្ទឹមស្មើពុំបាន។
នេះ នែកូនចៅជួបជុំគ្នា កូនសូមវន្ទាលាទោសហើយ
កាលលោកនៅរស់ខ្ញុំកន្តើយ ពោលពាក្យសំដីមិនសមរម្យ។
អញ្ជើញងូតទឹកណាអ្នកម្តាយ កូនសំអាតកាយដោយដៃខ្លួន
ឡើងព្រះឋានបានដ៏សមសួន កូនសូមធ្វើទានជូនទៅអ្នក។
មានភ្លេងពិណពាទ្យដូរ្យតន្ត្រី សាដក សង្ឃាដី និងភេសជ្ជៈ
បង្អែមចង្ហាបលើកឡើងដាក់ ចំពោះព្រះភ័ក្ត្រសង្ឃត្រៀបត្រា
នេះហើយថាអ្នកចេះធ្វើបុណ្យ តបគុណមាតា និងបិតា
មានចំណីម្ហូបអាហារ ជូនគាត់ពិសារទាន់នៅរស់។
ឥឡូវគាត់ស្លាប់បាត់ទៅហើយ កូនចៅខាងក្រោយធ្វើផ្ញើទៅ
មិនដឹងកន្លែងដែលគាត់នៅ មិនដឹងថាដល់ ឬមិនដល់។
ឥឡូវនេះខ្ញុំខុសហើយ បងប្អូនខាងក្រោយកុំងឿងឆ្ងល់
ម្តាយឪពុកនៅរស់ត្រូវផ្តល់ នេះជាកុសលឃើងឃើញពិត។
ខ្ញុំនេះជាកូនអកតញ្ញូ តស៊ូត្រាម្តាយអស់ជីវិត
កាលគាត់នៅរស់ខ្ញុំឥតគិត ញាតិមិត្តកុំយកតំរាប់ខ្ញុំ។

# ពុទ្ធកិច្ច ៥ យ៉ាង

ពុទ្ធកិច្ច ៥ យ៉ាងគឺអ្វីខ្លះ ចូរចាំឱ្យច្បាស់គ្រប់រូបា
បំណាច់អ្នកកាន់ពុទ្ធសាសនា ត្រូវចាំកិច្ចការនៃព្រះអង្គ។
ពេលព្រឹកទ្រង់យាងបិណ្ឌបាត តាមផ្ទះមានញាតិចាំរហង់
ជូនមួយអង្គឯងជូនមានសង្ឃ តម្រង់តាមសត្វមាននិស្ស័យ។
រសៀលទ្រង់ត្រាស់សំដែងធម៌ ដល់សត្វនិករដោយអាល័យ
បើសត្វមិនយល់ទ្រង់ឧបមេយ្យ បកស្រាយសេចក្ដីឱ្យយល់បាន។
ព្រលប់ប្រទានព្រះឱវាទ ដល់សង្ឃឱ្យស្អាតក្នុងសន្ដាន
កុំឱ្យប្រព្រឹត្តខុសលំអាន តាមផ្លូវដែលបានទ្រង់បញ្ញត្ត។
អាធ្រាត្រទ្រង់ដោះស្រាយបញ្ហា ដែលពួកទេព្ដាមកច្រើនខ្នាប់
សំដែងព្រះសូត្រ ឬបរមត្ថ តាមពពួកសត្វដែលសង្ស័យ។
ជិតភ្លឺប្រមើលនិស្ស័យសត្វ តើអាចប្រតិបត្តិមានកំរៃ
ដែលគួរត្រាស់ដឹងព្រះធម៌ថ្លៃ តាមឧបនិស្ស័យសត្វលោកា
៤៥ ឆ្នាំឥតមានខ្វះ ព្រះអង្គនឿយណាស់លើសមនុស្សា
ឥតមានសម្រាកព្រះកាយា ឥតមាននរណាប្រដូចបាន។

យើងបាត់ព្រះពុទ្ធទាន់សាសនា ធម៌ជាអាចារ្យទូន្មានប្រាណ
ប្រព្រឹត្តត្រង់ផ្លូវត្រូវលំអាន ដរាបដល់បាននិព្វានហោង។
យើងខ្ញុំបរិស័ទពុទ្ធសាសនា ឱនកាយវាចាចិត្តគោរព
ចំពោះព្រះពុទ្ធដែលជាម្លប់ គ្រប់គ្នាត្រូវចាំឱ្យទៀងទាត់។
ចងចាំថ្ងៃខែឆ្នាំឱ្យច្បាស់ នៃព្រះពុទ្ធម្ចាស់គឺប្រវត្តិ
សង្ខេបខ្លីៗឱ្យរត់មាត់ កំណត់ចាំបានពេលទាំងអស់។
យាងចូលកាន់គភ៌ឆ្នាំរកា អាសាឍមាសាថ្ងៃព្រហស្បតិ៍
ប្រសូតិឆ្នាំចថ្ងៃសុក្រស្មោះ ពិសាខឈើលាស់ដើមរដូវ។
សោយរាជ្យកត្តិកថ្ងៃអាទិត្យ ប្រជុំព្រាហ្មណ៍ព្រឹទ្ធនាឆ្នាំឆ្លូវ
បួសថោះអាសាឍព្រហស្បតិ៍ត្រូវ ត្រាស់នៅរកាពិសាខពុធ។
បរិនិព្វានថ្ងៃអង្គារ បរិស័ទគ្រប់គ្នាកើតតក់ស្លុត
នៅខែពិសាខព្រះសម្ពុទ្ធ រលត់បញ្ចក្ខន្ធនាឆ្នាំម្សាញ់។
យើងបាត់ព្រះពុទ្ធទាន់សាសនា ធម៌ជាអាចារ្យកុំគ្នន់គ្នាញ់
អ្នកប្រព្រឹត្តធម៌ឈ្មោះស្រឡាញ់ ចំពោះអង្គអញតថាគត។
បំណាច់អ្នកកាន់ពុទ្ធសាសនា ត្រូវចាំសាវតានៃព្រះពុទ្ធ
គឺថ្ងៃខែឆ្នាំឱយហ្មត់ចត់ ទើបបានកំណត់ជាពុទ្ធជន។

# កំណើតឆព្វណ្ណរង្សី

១-ជាតិយើងអ្នកកាន់សាសនា ត្រូវដឹងច្បាស់ថាព្រះពុទ្ធជិនស្រី
ទ្រង់មានឆព្វណ្ណរង្សី គឺព្រះរស្មី ទាំងប្រាំមួយពណ៌។
២-ផ្សាយចេញពីព្រះកាយទ្រង់ រុងរឿងឫទ្ធិរុងប្រសើរបវរ
ឆ្វៀលឆ្វាត់កាយឆើតឆាយល្អ ទាំងប្រាំមួយពណ៌ស្រស់ល្អសោភា។
៣-កំណើតនៃព្រះរស្មី កើតដោយបារមីនៃព្រះភគវា
ធ្វើទានឥតមានរុញរា កាលដែលនៅជាព្រះពោធិសត្វ។
៤-រស្មីពណ៌ខៀវនោះណា កាលឆ្កៀលនេត្រាទ្រង់ដោយចិត្តកាត់
ធ្វើទានដល់ឥន្ទព្រាហ្មណ៍ពិត កាលនៅជាក្សត្រនាមស្រីពិរាស្ត្រ។
៥-រស្មីពណ៌លឿងនោះណា កាលដែលទ្រង់អារសាច់ផែធ្វើមាស
បិទពុទ្ធរូបភ្លឺល្អឱភាស ព្រះឥន្ទជាងមាសទ្រង់វៃបណ្ឌិត។
៦-រស្មីក្រហមនោះណា កាលដែលមាតាពស់ខាំស្លាប់ពិត
បុទុមស្វប្តូរជីវិត កាត់បេះដូងបិទធ្វើថ្នាំមាតា។
៧-រស្មីពណ៌សសុទ្ធសាធ កាលដែលព្រះបាទវេស្សន្តរក្សត្រា
ឱ្យទានដំរីសសោភា ដែលទ្រង់ប្រាថ្នាយកពោធិញ្ញាណ។

៨-រស្មីពណ៌ដូចជើងហង្ស  កាលមាតាទ្រង់យក្សចាប់យកបាន
វិជ្ជាធរអារសាច់ខ្លួនប្រាណ  ឱ្យយក្ខសាមាន្យស៊ូប្តូរជីវិត។
៩-រស្មីភ្លឺផ្លេកពណ្ណរាយ  កាលជាទន្សាយឈ្មោះសោមបណ្ឌិត
ឱ្យទានសាច់ឈាមជីវិត  ដល់ឥន្ទព្រាហ្មណ៍ពិតថាអត់អាហារ។
១០-រស្មីខៀវ-លឿង-ក្រហម  សហង្សបាទព្រមភ្លឺផ្លេកអស្ចារ្យ
ត្រូវជាប្រាំមួយប្រការ  ក្មេងចាស់កុមារចូរចាំទុកអើយ។

# អាសនៈព្រះអរហន្ត ៩ ទិស

អហំតាំងស្មារតី  ឱនសិរសីថ្វាយបង្គំ
ព្រះពុទ្ធោជាធំ  គង់មជ្ឈិមជាកណ្តាល។
មានអង្គអរហន្តា  គង់ទិសាសព្វៗកាល
ព្រះទ័យត្រេកត្រអាល  ប្រោសប្រទានធម៌ទេសនា។
ព្រះសារីបុត្រចាំ  គង់ខាងស្តាំព្រះសាស្តា
ព្រះអានន្ទបច្ឆិមា  គង់ខាងក្រោយព្រះអង្គស្មោះ។
វីព្រះមោគ្គល្លានណា  គង់ឧត្តរាឆ្វេងចំពោះ

ព្រះកោណ្ឌញ្ញត្ថេរនោះ　　គង់ទិសបូពីចំព្រះភក្ត្រ។
ព្រះគវម្បតិស្សត្ថេរ　　គង់នៅឯពាយ័ព្យជាក់
ព្រះឧបាលិត្ថេរៈ　　គង់នីរតីនៃព្រះអង្គ។
វីព្រះកស្សបត្ថេរ　　គង់នៅឯអគ្នេយ៍នៃ
រាហុលបុត្រព្រះអង្គ　　គង់នៅនាទិសឦសាន។
បើអ្នកណាបានដឹងយល់　　ព្រះពុទ្ធមង្គលគួរឱ្យបាន
ទន្ទេញទុកក្នុងប្រាណ　　ប្រឹងសិក្សាថ្វាយបង្គំ។
បាលីលោកពោលថា　　បើអ្នកណាខំផ្ចិតផ្ចង់
លំអុតលំឱនអង្គ　　កុំឱ្យបង់ធម៌ប្រពៃ។
ជ្រះសោករោគាពាធ　　ឧត្បាតវៀសវាងវៃ
ភ័ន្តភាំងភៀសភិតភ័យ　　ឥតមោះមៃមកបៀនបាន។
សួស្តីជ័យជំនះ　　មានតេជៈរក្សាប្រាណ
ឥតអ្វីមកបៀតបាន　　រៀងរួចដល់និព្វានហោង។

# សង្វេជនីយដ្ឋានទាំង ៤ តំបន់

បឋមំ លុម្ពិនី វនយានំ ទុតិយំ ពោធិរតន-
បល្លង្កំ តតិយំ ធម្មចក្កំ ចតុត្ថំ បរិនិព្វានញ្ច កុសិនា-
រាយំ ចតុត្ថំ សង្វេជនីយដ្ឋានំ អហំ វន្ទាមិ ទូរតោ។

ខ្ញុំព្រះអង្គសូមបង្អោនកាយវាចាចិត្ត នមស្ការថ្វាយ
បង្គំចំពោះសង្វេជនីយដ្ឋានទាំង ៤ តំបន់ :

តំបន់ទី ១ ដែលទ្រង់ប្រសូតិលុម្ពិនី

តំបន់ទី ២ ដែលទ្រង់ត្រាស់ដឹង

តំបន់ទី ៣ ដែលទ្រង់សម្តែងព្រះធម្មចក្រ

តំបន់ទី ៤ ដែលទ្រង់រំលត់ខន្ធចូលកាន់បរិនិព្វាន ក្នុង
នគរកុសិនារា ដោយសេចក្តីគោរពអំពីចម្ងាយ។

# ឧទ្ទិសបុណ្យដល់ពពួកញាតិ

**ឥទំ នោ ទានំ (បុញ្ញំ) ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ។** សូមផលនៃទាន (បុណ្យនេះ) ចូរសំរេចដល់ពពួកញាតិទាំងឡាយរបស់ខ្ញុំ សូមឱ្យពពួកញាតិទាំងឡាយបានដល់នូវសេចក្តីសុខចុះ។

សូមឱ្យព្រះពុទ្ធសាសនារុងរឿងចំរើន សូមឱ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក សូមឱ្យលោកទាំងមូលបានប្រកបដោយសន្តិភាព ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា:

**នត្ថិ សន្តិ បរំ សុខំ** ពុំមានសេចក្តីសុខដទៃ ក្រៅអំពីសេចក្តីស្ងប់ឡើយ។

# ឯកសារពិគ្រោះ

-ប្រជុំភាណវារៈបាលី ដោយសម្ដេចសង្ឃនាយក ល្វី ឯម

-ប្រជុំភាណវារៈពិស្ដារ ដោយលោក គៅ ឈឹន

-គិហិបដិបត្តិពិស្ដារ ដោយព្រះសីលសំវរៈ រស់-តែប

-វចនានុក្រមខ្មែរ ដោយសម្ដេចព្រះសង្ឃរាជ ជួន ណាត

- វចនានុក្រមខ្មែរថ្មី-(អង់គ្លេស)។

-កំណាព្យ និងសុភាសិត ដោយធម្មាចារ្យ ឆឹម ការ ព្រម ទាំងដោយលោកអគ្គបណ្ឌិត ប៊ុត សាវង្ស ។ល។

-វិធីសុំសីលដោយភិក្ខុ សុន្ទរ៍ សាមឿន

# អ្នកមានឧបការៈក្នុងការរៀបរៀងធម្មទាននេះ

១- ភិក្ខុកល្យាណធម្មោ សុន្ទរ៍ សាមឿន

២- ព្រះសោភណត្ថេរោ សោម សុភាព

៣- ភិក្ខុសាសនធរោ សាន់ សុភា

៤- ភិក្ខុ អ៊ឹម សៀវ

៥-ឧបាសក ខៀវ សារឿន

៦-ឧបាសិកា ហុង សាវុន + ហុង សាវើន ( ហៅខៀប )។

# សប្បុរសជនដែលបានចូលប្រាក់បោះពុម្ព

-ភិក្ខុ ពិន អ៊ុម (ចៅអធិការវត្តស្វាយ) ........................................................ = 20$
-ភិក្ខុ អ៊ឹម សៀវ (វត្តមហាមន្ត្រី) ........................................................ = ៨០០០០៛
-ភិក្ខុ អឿន សុភាព (ចៅអធិការវត្តភ្នំបូក) ........................................ = ១០០០០០៛
-ភិក្ខុ ភេម ហ៊ាន (វត្តស្វាយ) ........................................................ = ២០០០០៛
-ភិក្ខុ សែម ប៊ុនហ៊ីម (វត្តស្វាយ) ........................................................ = ១២០០០៛
-ភិក្ខុ ជាក់ យឿម (វត្តស្វាយ) ........................................................ = ១៥០០០៛
-ភិក្ខុ សៅ គឹមហួន (វត្តស្វាយ) ........................................................ = ១០០០០៛
-ភិក្ខុ ពៅ កនសៅរឿន (វត្តស្វាយ) ........................................................ = ៨០០០៛
-ភិក្ខុ ជុំ ចន្ថា (វត្តនិរោធ) ........................................................ = ២០០០០៛
-ភិក្ខុ សៀម ហ៊ុន (វត្តនិរោធ) ........................................................ = ៥០០០៛
-ភិក្ខុ ឡុញ (វត្តស្វាយ) ........................................................ = ៣០០០៛
-ឧបាសក ខៀវ សារឿន ........................................................ = 100$
-ឧបាសិកា ហុង សាវុន និង-ឧបាសិកា ហុង សាវុធ + ហុង សាវីន (ហៅឡៀប)
និងយាយ គិម ហួយ ........................................................= 120000+ 5o$
-ឧបាសិកា ប៉ាត់ ណម ........................................................ = ១០០០០៛
-ឧបាសក សេង រស់ ព្រមទាំបុត្រ សឹង ចាន់និងបុត្រ ........................ = ២៥០០០៛
-លោក ទិន ស៊ីថន មន្ត្រីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ខេត្តស.រ. ... = 20$+១០០០០៛
-លោក សំ សុខហាន ........................................................ = ១០០០០៛
-លោក ឡេង សុខភីរម្យ ........................................................ = ១០០០០៛
-លោក អែម ហែម ........................................................ = ១០០០០៛
-លោក យ៉ោក មុំ ........................................................ = 2$
-ឧបាសក អៀវ ........................................................ = ៥០០០៛

-ឧបាសិកា សួង ប៉ូលីន (ហៅប៉ិច) ............................................. = 6$+១000៛
-ឧបាសិកា គត់ ពៅ ព្រមទាំងបុត្រ ................................................. = ៤0000៛
-ឧបាសិកា ភី ............................................................................................ = ៥000៛
-ឧបាសិកា យ៉ន .......................................................................................... = ១0000៛
-ឧបាសិកា វ៉ាន់ នី ...................................................................................... = ៧0000៛
-ឧបាសិកា ឈុយ សំ .................................................................................. = 20$
-ឧបាសិកា អ៊ុន រី ....................................................................................... = ៧000៛
-កញ្ញា ខាន់ សុខឿន (ហៅសុភាព) ........................................................ = ១៥000៛
-អ្នកមីង ង៉ូយ រិន ....................................................................................... = ៤000៛
-លោកយាយ មិនស្គាល់ឈ្មោះ ..................................................................... = ១000៛
-លោក អ៊ាន ទឹង និងឧបាសិកា ហេង សុខា និងបុត្រ .................... = ៥៥៥00៛
-ឧបាសិកា គង់ រុម និងកញ្ញា គង់ រស្មី ..................................................... = 10$
-ឧបាសិកា កុក ម៉ារេត ព្រមទាំងបុត្រ.......................................... = ៤0000៛+១$
-ឧបាសិកា ម៉ៅ .......................................................................................... = ២000៛
-ឧបាសិកា ហេង ទៀង ............................................................................. = ២000៛
-ឧបាសក ឃុន ស៊ីន ..................................................................................... = ២0000៛
-ឧបាសិកា ទត់ គឹមសៀង និងនាង តាន់ ទឹមទេវី ព្រមទាំបុត្រ .......... = ៣0000៛
-ឧបាសិកា ឈុយយក់ម្វិះ ............................................................................ = ៩000៛
-ឧបាសិកា ប្រឹក ......................................................................................... = ២៥000៛
-ឧបាសិកា ហុង សន .................................................................................. = ២000៛
-ឧបាសក គង់ និងឧបាសិកា វ៉ាត ........................................................ = ១0000៛
-ឧបាសិកា ពាញ អ៊ុស ................................................................................. = ២៥000៛
-ឧបាសិកា ទេព ទេពី ..................................................................... = ៨៦00៛+២$

-ឧបាសិកា លី វណ្ណៈ .............................................................................= ៤០០០០៛

-ឧបាសិកា លុយ រ៉ម ...............................................................................= ១០០០០៛

-លោក លុយ សិច ....................................................................................= ៥០០០៛

-ឧបាសិកា អ៊ុន សឿន ព្រមទាំងបុត្រ និងចៅៗ ...................................= ២៤០០០៛

-ឧបាសក ណៃ ..........................................................................................= ១០០០៛

-ឧបាសិកា ហ៊ុន ..................................................................................= ១០០០០៛

-ឧបាសិកា វ៉ុន ........................................................................................= ៧០០០៛

-ឧបាសក ឆ ..........................................................................................= ២០០០០៛

-ឧបាសិកា គន់ ប៊ុក ..........................................................................= ៣៥០០០៛

-លោក ឃុន វត្ថ័ និងភរិយា ព្រមទាំងបុត្រ .........................................= ២៥០០០៛

-ឧបាសិកា ម៉ាត់ ង៉ាត់ .........................................................................= ៣០០០០៛

-លោកយាយ ម៉ាត់ ង៉ាំ ...........................................................................= ១០០០០៛

-កញ្ញា ឡាំ សុវណ្ណនី ............................................................................= ១០០០០៛

អ្នកបងឡុង សម្ផស្ស ហៅ ស្រីមុំ.......................................................................= 5000៛

-កញ្ញា ឡាំ សុធាវី ..................................................................................= ១០០០០៛

-កុមារី ពេញ ម៉ូលីកា ...........................................................................= ១០០០០៛

-ឧបាសក ហាង គិន (វត្តដើមអំពិល) ....................................................= ១០០០០៛

-លោក វ៉ា លីប៉ូ និងភរិយា .......................................................................= 3$

-លោក ស៊ីន ធឿន និងភរិយា ព្រមទាំងបុត្រ ..........................................= ៥០០០៛

-ឧបាសិកា ស៊ុន ហេង .........................................................................= ៥០០០៛

-លោកឡាយអៀងម៉េង និងឧបាសិកាលីតាំងគួយ(ហៅផល)ព្រមទាំងបុត្រ ....= ៥០០០៛

-អ្នកគ្រូ ជិប ប៊ុនម៉ារីដា ......................................................................= ៥០០០០៛

-កញ្ញា អាត សូលីណា ...........................................................................= 10$

-លោក ច័ន្ទ សុខខុន និងភរិយា ព្រមទាំងបុត្រ................................................= 5$

-យាយ គង់ ស៊ាន .................................................................................= 1$

-លោក ប៊ុន ឡាយ និងភរិយា ព្រមទាំងបុត្រ ....................................= ២០០០០៛

-លោក សេង និងភរិយា ព្រមទាំងបុត្រ .............................................=១០០០០៛

-ឧបាសិកា មុំ ទូច ...................................................................= ២០០០០៛

-ឧបាសិកា សុខ សុគន្ធ ព្រមទាំងស្វាមី និងបុត្រ ...................................= ៣០០០៛

-ឧបាសិកា សុខ អួន និងស្វាមី ព្រមទាំងបុត្រ .......................................= ២០០០៛

-ឧបាសិកា ណុប ទាវខេង និងមាតាបិតាព្រមទាំងបុត្រ ..............................= 20$

-ឧបាសិកា ប៉ាត់ សម្បត្តិ ព្រមទាំងបុត្រ ........................................................ ១០$

-លោក អ៊ុក គង់ និងភរិយាព្រមទាំងបុត្រ ..............................................១០០០០៛

-ឧបាសិកា គង់ ហុង................................................................................ ២០០០៛

-ឧបាសិកា សូរ ហៀក ...........................................................................៤០០០០៛

-កញ្ញា មួន ចម្រើន .................................................................................៨០០០៛

-ឧបាសិកា ឡេង.................................................................................... ៥$

-ឧបាសក ហេង ឡុង ...........................................................................២០០០០៛

-អ្នកស្រី ទាម ពោជ្ជនី ..... ..............................................................................៥$

-អ្នកស្រី ឯម ចាន់ណាត.......................................................................... ៥$

-អ្នកស្រី វ៉ែន គុណ្ណា.............................................................................. ៥$

-ឧបាសិកា នាង ....................................................................................៤០០០៛

-កញ្ញា លាវ សុវឌ្ឍនា .................................................. ១៥$ +១៦០០០៛

-ឧបាសិកា រស់ រ៉ែម .................................................. ៥០០០៛

-ឧបាសិកា ឡាង .................................................. ១០០០០៛

-ឧបាសក រឿន ខេមរា .................................................. ៥០០០៛

-អ្នកស្រី ម៉ា ភឿន .................................................. ១០០០០៛

-ឈើន ពៅ .................................................. ១០០០០៛

-ឧបាសក នូ ចន .................................................. ៦០០០៛

នាងខ្ញុំសូមថ្លែងអំណរគុណ ចំពោះព្រះគុណម្ចាស់គ្រប់ព្រះអង្គ និងពុទ្ធបរិស័ទ ដែលបានជួយឧបត្ថម្ភប្រាក់ ក្នុងការបោះពុម្ពសៀវភៅនេះ សូមឱ្យប្រយោជន៍ដែលកើតឡើង អំពីការខំប្រឹងប្រែងក្នុងការងារធម្មទាននេះ បានជាបច្ច័យនៃព្រះនិព្វានគ្រប់ៗព្រះអង្គ គ្រប់ៗគ្នា ។

**សុខោ បុញ្ញស្ស ឧច្ចយោ** *ការសន្សំបុណ្យនាំនូវសេចក្ដីសុខ*

**សព្វទានំ ធម្មទានំ ជិនាតិ** *ធម្មទានឈ្នះអស់ទានទាំងពួង ។*

# ពុំមានពន្លឺអ្វី ស្មើដោយពន្លឺ គឺប្រាជ្ញាឡើយ

**ព្រះអាទិត្យ** ភ្លឺបានតែនៅក្នុងពេលថ្ងៃ **ព្រះចន្ទ** ភ្លឺបានតែក្នុងពេលយប់ **ភ្លើង** អាចភ្លឺបានទាំងក្នុងពេលថ្ងៃ និងក្នុងពេលយប់ ក៏ប៉ុន្តែបើមានវត្ថុអ្វីមកបិទបាំង ភ្លើងមិនអាចភ្លឺធ្លុះបានទេ ។ ចំណែក **បញ្ញា** ភ្លឺថ្លាអស្ចារ្យណាស់ គឺភ្លឺបានទាំងក្នុងពេលថ្ងៃ ទាំងក្នុងពេលយប់ ទោះបីមានវត្ថុអ្វីមកបិទបាំងក៏ដោយ ក៏បញ្ញាអាចភ្លឺធ្លុះបានដែរ គ្មានពន្លឺអ្វីស្មើនឹងពន្លឺនៃបញ្ញាទេ ។ **បញ្ញា** សំខាន់ណាស់អាចបំភ្លឺយើងឱ្យដឹងអាក្រក់, ល្អ, ស, ខ្មៅ, បាប, បុណ្យ, គុណ, ទោស, ខុស, ត្រូវ, មានប្រយោជន៍, ឥតប្រយោជន៍ ។ ដោយសារបញ្ញាមនុស្សយើងអាចសាងវប្បធម៌បាន **ព្រះសម្មាសម្ពុទ្ធ** ទ្រង់ប្រាថ្នាចង់ ឱ្យយើងបានសុខចំរើន និងមានតម្លៃ ទើបទ្រង់ប្រៀនប្រដៅយើង ឱ្យរស់នៅជាមួយបញ្ញា ពីព្រោះការរស់នៅជាមួយបញ្ញាជាការរស់នៅរបស់មនុស្ស រីឯការរស់នៅប្រាសចាកបញ្ញា មិនមែនជាការរស់នៅរបស់មនុស្សឡើយ ។

**បញ្ញា** ជាថ្នាំសំរាប់កំចាត់នូវរោគទាំងឡាយ គឺអកុសល ។

**បញ្ញា** ជាទឹកសក្តិសិទ្ធិសំរាប់ជំរះគ្រឿងមន្ទិលសៅហ្មងគ្រប់យ៉ាង

**បញ្ញា** ជានាវាដ៏ប្រពៃ សំរាប់ឆ្លងកាត់ស្ទឹង គឺតណ្ហា ។

**បញ្ញា** ជាវាតៈ (ខ្យល់) ដែលអាចបក់ភ្លើង និងធូលីឱ្យរលត់បាន

**បញ្ញា** ជាឱសថទិព្វអាចចាក់ទម្លុះអរិយសច្ចៈ ។

ចូរភ្ញាក់ឡើង! ចូរក្រោកឡើង! ចូរកុំធ្វើអ្វីៗ ដោយប្រាសចាកបញ្ញា!។

**រត្នាសិទ្ធិ**